ខុមហ្វ្រែល COMFREL

# របាយការណ៍
# សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ






## របាយការណ៍ឆ្នាំទី៣ នីតិកាលទី៥ (វិច្ឆិកា ២០១៥ - តុលា ២០១៦)

2017

# របាយការណ៍
# សង្ខេបរដ្ឋសភា និងតំណាងរាស្ត្រ

**មតិក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងពីជំហររបស់ម្ចាស់ជំនួយ និងដៃគូរឡើយ។**

រូបថតក្របមុខៈ *យកចេញពីទំព័រ Facebook របស់រដ្ឋសភាជាតិ និងពី Internet។*

# មាតិកា


➢ **សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្រ្ត ឆ្នាំទី៣ នៃនីតិកាលទី៥ (ភាសាខ្មែរ)**

➢ **សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្រ្ត ឆ្នាំទី៣ នៃនីតិកាលទី៥ (ភាសាអង់គ្លេស)**

➢ **របាយការណ៍ស្តីពីលទ្ធផលនៃការសង្កេតរដ្ឋសភា និងតំណាងរាស្រ្ត**

I. សង្ខេបការរកឃើញ ........ ០១

II. ដំណើរការប្រជុំរបស់រដ្ឋសភា ........ ០៤

២.១ ការប្រជុំពេញអង្គរបស់រដ្ឋសភា ........ ០៥

២.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្រ្តក្នុងសម័យប្រជុំរដ្ឋសភា........ ០៥

២.១.២ ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្រ្តក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា........ ០៧

២.១.៣ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្រ្តធៀបនឹងរយៈពេលសរុបតាមគណបក្ស.. ០៧

២.១.៤ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្រ្តតាមគណបក្សទៅលើតួអង្គ ស្ថាប័ន និងចំណុចផ្សេងៗ ........ ០៨

២.១.៥ គុណភាពនៃការពិភាក្សា និងអនុម័តច្បាប់/របៀបវារៈ ........ ១០

III. សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភា........ ១៣

៣.១ ដំណើរការនៃការប្រជុំ/សួរដេញដោលក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា........ ១៤

៣.២ ការចុះបេសកកម្មគណៈកម្មការជំនាញនៃរដ្ឋសភា ........ ១៤

IV. ការចុះមូលដ្ឋានរបស់តំណាងរាស្រ្ត ........ ២០

៤.១ ចំនួនអ្នកតំណាងរាស្រ្ត និងចំនួនដងនៃការចុះមូលដ្ឋាន ........ ២១

៤.២ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្ត........ ២៣

៤.៣ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្តតាមគណបក្សនីមួយៗ ........ ២៤

៤.៥ ការិយាល័យតំណាងរាស្រ្តនៅតាមមណ្ឌលរាជធានី ខេត្ត ........ ២៦

V. កិច្ចអន្តរាគមន៍របស់តំណាងរាស្រ្ត និងរដ្ឋសភា ........ ២៧

៥.១ កិច្ចអន្តរាគមន៍របស់រដ្ឋសភា ........ ២៧

៥.២ លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្រ្ត ........ ២៨

VI. ករណី និងព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្រ្ត ........ ២៩

៦.១ ការចាប់ខ្លួនតំណាងរាស្រ្តមណ្ឌលខេត្តសៀមរាបឯកឧត្តម អ៊ុំ សំអាន ជាការរំលោភរដ្ឋធម្មនុញ្ញ? ..... ២៩

៦.២ បញ្ហាសុវត្ថិភាពគឺជាក្តីបារម្ភរបស់តំណាងរាស្រ្ត........ ៣០

៦.៣ ការរឹតត្បិតសកម្មភាពរបស់តំណាងរាស្ត្រពីគណបក្សប្រឆាំង ........................................ ៣១
៦.៤ ចំណាត់ការរបស់រដ្ឋសភា និងតុលាកាលើឯកឧត្តម កឹម សុខា ........................................ ៣១
៦.៥ ភាពចម្រូងចម្រាសក្នុងការធ្វើវិសោធនកម្មប្រការ៤៨ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា............ ៣២
VII. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ ........................................ ៣៣
➢ **ឧបសម្ព័ន្ធ**

# សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃនីតិកាលទី៥(ភាសាខ្មែរ)

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃនីតិកាលទី៥

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃរដ្ឋសភានីតិកាលទី៥ ក្នុងឆ្នាំ២០១៦ រកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានទម្លាក់ ពិសេសក្រុមមតិភាគច្រើនដែលកាន់អំណាចបានបំពារបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រគណបក្សប្រឆាំង និងបន្ថយតួនាទីរបស់តំណាងរាស្ត្រគណបក្សប្រឆាំង និងព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិច។ តំណាងរាស្ត្រគណបក្សកាន់អំណាចនៃរដ្ឋសភាបានបើកផ្លូវឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំង។ ជាមួយគ្នានេះ គណបក្សកាន់អំណាច ជាឯកបក្ស បានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាលុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់។ មានការលើកទឹកចិត្ត តម្លើងឋានន្តរសក្តិដល់អ្នកដៃដល់ដែលជាមន្ត្រីនៃកងកម្លាំងប្រដាប់អាវុធ កងអង្គរក្ស ដែលបានប្រើអំពើហិង្សាប្រឆាំងតំណាងរាស្ត្រគណបក្សមតិភាពតិច។

ដោយឡែក សកម្មភាពការងាររបស់គណៈកម្មការជំនាញនៃរដ្ឋសភាវិញ គឺមានការថយចុះ ប៉ុន្តែសកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង បើធៀបនឹងឆ្នាំទី២ (ឆ្នាំ២០១៥)។ នៅស្របពេលដែលចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិក្នុងការពិភាក្សា និងអនុម័តច្បាប់ និងបរិមាណនៃការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភាក៏មានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥។

រដ្ឋសភាដែលមានតែតំណាងរាស្ត្រពីគណបក្សកាន់អំណាច បានសម្រេចដោយអត្តនោម័តធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ប្រការ៤៨ថ្មី (បី) ដោយលុបចោលតួនាទីថ្នាក់ដឹកនាំតំណាងរាស្ត្រ និងតួនាទីប្រធានក្រុមមតិភាគតិចនៅក្នុងរដ្ឋសភា។

ជុំវិញការធ្វើវិសោធនកម្មច្បាប់នេះ លោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់ខុមហ្វ្រែល យល់ឃើញថា *«នៅកម្ពុជា ជាការត្រឹមត្រូវក្នុងប្រព័ន្ធសភានិយមត្រូវរក្សាឲ្យមានក្រុមមតិភាគតិច ឬគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ដែលទទួលស្គាល់ដោយច្បាប់។ ក្រុមភាគតិច ឬគណបក្សប្រឆាំងដែលមានប្រធានក្រុមទទួលស្គាល់ដោយបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៅកម្ពុជា ត្រូវមានអាសនៈយ៉ាងតិច២៥% ប៉ុន្តែនៅឥណ្ឌាត្រូវការតែ១០%។ ក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស គណបក្សមតិភាគច្រើនមានតួនាទីដឹកនាំ តែគណបក្សមតិភាគតិចមានសិទ្ធិក្នុងសភា (parliamentary majority rule while minority rights)។ សិទ្ធិរបស់ក្រុមមតិភាគតិចរួមមានៈ ការទទួលបានការការពារ ការទទួលព័ត៌មាន តំណាងពិភាក្សាជាមួយមតិភាគច្រើន និងការស្នើច្បាប់...។ល។»*

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា៖** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញចំនួន៣លើកដែលលើកទី១ គឺការបន្តសម័យប្រជុំលើកទី៥ក្នុងចន្លោះដើមខែវិច្ឆិកា ដល់ដើមខែកុម្ភៈឆ្នាំ២០១៦ លើកទី២គឺសម័យប្រជុំលើកទី៦ ពីខែមេសា ដល់ដើមខែកក្កដាឆ្នាំ២០១៦ និងលើកទី៣គឺសម័យប្រជុំលើកទី៧ ក្នុងខែតុលាឆ្នាំ២០១៦។

ក្នុងរយៈពេលនេះមានរបៀបវារៈចំនួន**៣២**ត្រូវលើកមកពិភាក្សា និងអនុម័តដែលរួមមាន៖ ព្រះរាជសាររបស់ព្រះមហាក្សត្រចំនួន**០២** របាយការណ៍សង្ខេបរបស់រដ្ឋសភានៅចន្លោះសម័យប្រជុំពេញអង្គចំនួន**០២** សេចក្តីព្រាង

ច្បាប់ចំនួន**២១** ការបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តចំនួន**០៤លើក** ការសម្រេចឲ្យអាជ្ញាធរមានសមត្ថកិច្ចមានចំណាត់ការលើករណីតំណាងរាស្ត្រចំនួន**០២លើក** និងការបំភ្លឺចំពោះមុខរដ្ឋសភាចំនួន**១លើក**។

របៀបវារៈសំខាន់ៗចំនួន២១ ត្រូវបានរដ្ឋសភាអនុម័តដោយសំឡេងឯកបក្សដែលក្នុងនោះរួមមាន សេចក្តីព្រាងច្បាប់ចំនួន១៦ ការបោះឆ្នោតជ្រើសតាំងចំនួន០២លើក ការអនុម័តសេចក្តីសម្រេចចំនួន០២លើក និងការឆ្លើយបំភ្លឺចំនួន០១លើក។ ជាមួយគ្នានេះក៏មានរបៀបវារៈចំនួន១១ ត្រូវបានអនុម័តដោយមិនមានការពិភាក្សាដេញដោលលើខ្លឹមសារច្បាប់ដោយអ្នកតំណាងរាស្ត្រ។ ការសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិ និងបរិមាណនៃការបញ្ចេញមតិមានការថយចុះបើធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំទី២ នៅស្របពេលដែលតំណាងរាស្ត្រភាគច្រើននៅតែមិនបានឡើងបញ្ចេញមតិពិភាក្សាលើខ្លឹមសារច្បាប់ ដោយស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់។ ចំពោះសកម្មភាពពិភាក្សាដេញដោលវិញ របៀបវារៈមួយចំនួនដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចូលរួមពិភាក្សា គឺមានការពិភាក្សាដេញដោលផុសផុលដូចនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី២។

ខុមហ្វ្រែលសង្កេតឃើញថា នៅបន្ទាប់ពីមានការធ្វើពហិការមិនចូលរួមកិច្ចប្រជុំក្នុងរដ្ឋសភាពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនៅពាក់កណ្តាលឆ្នាំ២០១៦ (នៅក្រោយការវាយដំអ្នកតំណាងរាស្ត្រខ្លួន២រូបនៅមុខរដ្ឋសភា) ការអនុម័តសេចក្តីព្រាងច្បាប់នានា គឺមិនមានការពិភាក្សាសួរដេញដោលផុសផុល ដូចនៅពេលមានការចូលរួមប្រជុំពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនោះទេ។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភា៖** នៅក្នុងឆ្នាំទី៣នេះ សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី២ (ឆ្នាំ២០១៥)។ ការសង្កេតរកឃើញថា គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន**៦០លើក** ខណៈដែរក្នុងឆ្នាំ២០១៥ គណៈកម្មការជំនាញនៃរដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន**១០៥លើក**។ ក្នុងចំណោមសកម្មភាពទាំងនេះ គណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន**៣១លើក** ហើយសកម្មភាពគណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានចំនួន**២៩លើក**។

សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាទាំងនោះរួមមានៈ ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ ការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច/និងប្រជាពលរដ្ឋ ដើម្បីពិនិត្យ និងស្វែងយល់ពីបញ្ហាកង្វល់នានាតាមមូលដ្ឋាន សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ ពិសេសបញ្ហាទំនាស់ដីធ្លី និងជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។

**សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងរយៈពេលនេះ សកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង ខណៈដែលគោលបំណងក្នុងការចុះមូលដ្ឋានភាគច្រើន ក្នុងគោលបំណងទាក់ទាញប្រជាប្រិយភាព និងការគាំទ្រមកលើគណបក្សនយោបាយរបស់ខ្លួន ព្រោះថាការបោះឆ្នោតខិតជិតមកដល់ក្នុងឆ្នាំ២០១៧។ មានសំណូមពរ និងសំណើជាច្រើន ត្រូវបានលើកឡើងក្នុងសកម្មភាពចុះមូលដ្ឋាននោះដែលសំណើមួយចំនួនទទួលបានការឆ្លើយតបភ្លាមៗនៅមូលដ្ឋាន និងមួយចំនួនទៀតត្រូវលើកយកមកពិនិត្យ និងសិក្សានៅរដ្ឋសភា។

ខុមហ្វ្រែលសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន**១០២រូប** នៃតំណាងរាស្ត្រសរុបចំនួន១២៣រូបបានចុះបេសកកម្មនៅមូលដ្ឋានចំនួន**១៨០១លើក** ដែលជាចំនួនច្រើនមិនធ្លាប់មាន ចាប់តាំងពីចាប់ផ្តើមដំណើរការរដ្ឋសភានីតិកាលទី៥នេះ។ ក្នុងចំណោមសកម្មភាពទាំងនោះ មានតំណាងរាស្ត្រចំនួន**៥៦រូប**ពីគណបកក្សគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានចំនួន**៦១៧លើក** ហើយមានតំណាងរាស្ត្រចំនួន**៤៥រូប**ពីគណបក្សសង្គ្រោះជាតិបានចុះមូលដ្ឋានសរុបចំនួន**១១៨៤លើក**។ សកម្មភាពទាំងនោះភាគច្រើន គឺផ្តោតលើការជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងការចុះពង្រឹងបណ្តាញផ្ទៃក្នុងរបស់គណបក្សនៅមូលដ្ឋាន។

**ការកោះហៅបំភ្លឺ៖** សកម្មភាពកោះហៅមកបំភ្លឺក្នុងរដ្ឋសភាមានការថយចុះជាងរយៈពេលដូចគ្នាក្នុងឆ្នាំទី២។ ក្នុងរយៈពេលនេះ មានការកោះអញ្ជើញរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងរដ្ឋសភាទាក់ទងនឹងការអនុវត្តវិស័យយុត្តិធម៌នៅកម្ពុជា។ ជាមួយគ្នានេះក៏មានការបំភ្លឺដោយផ្ទាល់មាត់ពីមន្ត្រីរាជរដ្ឋាភិបាលនៅក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា និងនៅតាមក្រសួងមន្ទីរមួយចំនួនផងដែរ។

**កិច្ចអន្តរាគមន៍របស់រដ្ឋសភា និងតំណាងរាស្ត្រ៖** ទាក់ទងនឹងកិច្ចអន្តរាគមន៍ក្នុងរយៈពេលនេះ ខុមហ្វ្រែលបានទទួលព័ត៌មានអំពីការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺនៅក្នុងរដ្ឋសភា ការទទួលបណ្តឹង និងអន្តរាគមន៍លើបណ្តឹងរបស់ប្រជាពលរដ្ឋ។ ការសង្កេតឃើញថា ការទទួលបណ្តឹងរបស់រដ្ឋសភាមានការថយចុះធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥។ ចំពោះការចេញលិខិតរបស់តំណាងរាស្ត្រវិញ គឺមានចំនួន២៤ច្បាប់ដែលក្នុងនោះមានថ្វាយព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងរដ្ឋសភាក្នុងគោលបំណងភាគច្រើនស្នើ ឬអំពាវនាវឲ្យចាត់វិធានការដើម្បីអន្តរាគមន៍រកដំណោះស្រាយបញ្ហានានា។

**តំណាងរាស្ត្រ១០រូប ដែលសកម្មជាងគេ៖** ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលទទួលព័ត៌មានថា មានតំណាងរាស្ត្រ **៧រូប** ពីគណបក្សសង្គ្រោះជាតិ និង**៣រូប** ពីគណបក្សប្រជាជនកម្ពុជា បានធ្វើសកម្មភាពច្រើនជាងគេ។ ដោយឡែកចំពោះការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាវិញ តំណាងរាស្ត្រដែលសកម្មភាពជាងគេរួមមាន **៥រូប** ពីគណបក្សប្រជាជនកម្ពុជា និង**៥រូប** ពីគណបក្សសង្គ្រោះជាតិ។

ជាសរុបសកម្មភាពរបស់អ្នកតំណាងរាស្ត្រទៅមូលដ្ឋានមានចំនួនច្រើន ប៉ុន្តែប្បដិវាទចុងក្រោយនៅរវាងគណបក្សទាំងពីរ ការប្រើអំពើហិង្សា ការប្រើប្រាស់ច្បាប់ និងការកែបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដើម្បីបង្ក្រាប កៀបសង្កត់ និងដកសិទ្ធិចំពោះអ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បាននាំមកនូវការធ្លាក់ចុះប្រសិទ្ធភាពរបស់រដ្ឋសភា និងការទាញទំលាក់ការអនុវត្តន៍គោលការណ៍ប្រជាធិបតេយ្យសេរី ពហុបក្ស និងនីតិរដ្ឋនៅកម្ពុជា។

ចំនួននៃការសន្ទនារបស់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិក៏បានធ្លាក់ចុះ ហើយការសន្ទនារវាងគណបក្សទាំងពីរនៅក្នុងរដ្ឋសភាក៏មិនបានពេញលេញ។ ការសន្ទនាគ្នានេះត្រូវបានមើលឃើញថាជា មធ្យោបាយមួយល្អក្នុងការដោះស្រាយការខ្វែងគំនិតគ្នារវាងគណបក្សទាំងពីរ និងបញ្ហាជាតិនានា។

**សម្រាប់ព័ត៌មានបន្ថែម៖**

| **ឈ្មោះ** | **លេខទូរស័ព្ទ** |
|---|---|
| • លោក គល់ បញ្ញា | ០១២ ៩៤២ ០១៩ |
| • លោក កន សាវាង្ស | ០១១ ៨៨៤ ៨៤០ |
| • លោក ស៊ិន ទិត្យសីហា | ០១២ ២៥២ ៦៦១ |

# សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃនីតិកាលទី៥ ( ភាសាអង់គ្លេស )

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ទស្សនវិស័យ ៖ សង្គមប្រជាធិបតេយ្យមួយ ដែលប្រជាធិបតេយ្យភាវូបនីយកម្ម ជាពិសេសការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ត្រូវបានលើកកម្ពស់ និងមានគុណភាព ដើម្បីផលប្រយោជន៍ប្រជាជន

Phnom Penh, February 20th, 2017

**Press Release**

**National Assembly and Parliamentary Watch for the 3rd Year of the 5th mandate**

The annual report on National Assembly (NA) and Parliamentary Watch in the third year of the 5th mandate, 2016, found out that the effectiveness of the assembly deteriorated. This was largely due to the aggravated manipulation by ruling party's members of parliaments (MPs), against members of the opposition. This included violation of MPs' immunity, reducing the role of opposition, MPs and eliminating leadership of MPs of each party and leader of Minority MPs. In the case of MP's immunity, those MPs belonging to the ruling party, who dominate the Steering Committees in the National Assembly, approved upon the request for the criminal prosecution against the opposition MPs. The ruling party's MPs with unilateral consent, passed the proposed amendment of the Internal Regulations of the NA with the aim to eliminate the minority MPs group leader constituted by law. However, those convicted for involvement in the brutal and violent attack on opposition MPs last year, known members of armed force and bodyguard unit, have just been promoted.

In the same period, the numbers of activities of expert commissions of the national assembly have decreased, whereas the activities of field visits rapidly increased compared to the previous report. It was found that the numbers of MPs who have had opportunities to express their opinions in the debates sessions of the drafted laws and national assembly's debate sessions decreased when compared to 2015.

The National Assembly, dominated by the ruling party's, has passed the amendment of Section 48 new (3), and the amendment dissolved the role of MPs' leadership of each party and leader of minority MPs in the National Assembly.

Referring to this amendment, Mr. Koul Panha, executive director of COMFREL, stated that: "*In a real parliamentary system, it needs minority groups or opposition party in National Assembly be recognized by law. In Cambodia, to be recognized as a minority group or opposition party leader by National assembly's internal rule, they must have at least 25% of seats of the entire National Assembly. However, in India only 10% of all seats of the lower house is needed. In a liberal democracy, the majority group has ruling power while minority group is granted their rights, including the rights of minority group, the right to protection, right to access information, dialogue partner with majority group and the right of proposed a draft laws, .*"

<u>The National Assembly's Plenary Sessions Processes:</u> In this period, the National Assembly ordinary plenary sessions were conducted three times; the first plenary session continued the 5th ordinary session, started from early November 2016 to early February 2016, second plenary session was the 6th ordinary session, started from April 2016 to early July 2016 and the third plenary session was the 7th ordinary session, started in October, 2016.

Within the year, there were thirty two (32) agendas brought up for debates and approved, including; two (2) opening plenary session's messages from the His Majesty, two (2) summarized reports of National Assembly's activities during vacation, twenty one (21) drafted laws submitted by government, four (4) times of voting on confidence on the proposed candidates submitted by government, two (2) decisions to permit the competent authorities to take action against Members of Parliament and one (1) time of summoning a minister for questions in plenary session.

Amongst all of these, 21 key agendas were approved by unilateral ruling party's MPs, including 16 drafted laws, 02 voting in confidence on proposed candidates, 02 decisions for approval and 01 plenary summoning for questions; whereas 11 key agendas were adopted without debate on the drafted laws' contents. The findings of this report show that the numbers of MPs who had expressed their opinions in plenary sessions decreased compared to the previous year, while a majority of lawmakers still remain silent. The debates in the plenary sessions, agendas discussed by opposition MPs were actively debated as was the case in the previous year.

COMFREL observed that after the boycott of the opposition MPs in mid-2016 in the days after the violation of MPs in front of National Assembly, the adoption of the drafted laws did little to foster debate about the content of those draft law as presented at the time by opposition party's MPs.

<u>The National Assembly's Specialized Commissions' Activities:</u> In this 3rd year of the fifth legislature, activities of the specialized commissions decreased compared to the previous year. The number of activities recorded was found to have decreased by 60 times in total whereas in 2015 the specialized commissions remarkably increased by 105 times. Amongst all activities, 31 were conducted by CNRP-lead specialized commissions, and 29 conducted by those led by the CPP. These activities included invitations to concerned ministers to answer questions before them and other concerned ministries, meeting with local authorities and citizens to observe and understand their concerns, receiving complaints, and reviews and visiting directly conflicted areas, especially land disputes, and meeting with local and international non-NGOs to discuss concerns.

<u>Parliamentarian constituency/field visits:</u> This year, parliamentarian's field visits were remarkably high, while the aims of their visits were focusing on attracting supports from citizens as the 2017 elections approach. Many suggestions, proposals and offers have been made by MPs, some of them responded and got feedback immediately and others are ongoing with a promise to review and check at National Assembly.

COMFREL found that 102 of 123 parliamentarians conducted 1801 field/constituency visits, recorded in the 5th mandate of legislature. 617 field visits were conducted by 56 CPP lawmakers and 1184 were conducted by only 45 CNRP lawmakers. The purposes of parliamentarians' field visits were largely meetings and greeting with local people, and strengthening the political party network.

<u>The Hearings:</u> The numbers of hearings when compared to last year's report, have fallen. In recent times, the Minister of Justice was summoned for questioning in the plenary session about justice enforcement and administration. Ministers have been seen in hearings to clarify at the NA's expert commissions and ministries.

<u>The National Assembly and Parliamentarians' Intervention:</u> Summoning ministers to questioning, receiving people's complaints for possible solution are defined as parliamentarians' interventions. The report doesn't find any decrease in terms of receiving petitions compared to 2015-report. 24 letters were issued and submitted to the government, the King, His Majesty and the National Assembly by parliamentarians seeking for possible solution.

Top 10 Active MPs who made fields visits and voiced expression in plenary session debates: Ten MPs have a high profile of their performance. 07 from CNRP and 03 from CPP were very active in field/constituency visits. However, in term of expression to the session debates, only five MPs from each party were recorded as always expressing opinion during the debates, longer than others.

In short, the MPs field/constituency visits had increased remarkably, but there were some controversial issues between CPP and CNRP in the cases of violation, legal harassment of opposition MPs, using legislation as a politically motivated tool, and amendment to the Internal Rules of the National Assembly to harass the right of the opposition PMs. This has led to an overall decline in the effective role and performance of the National Assembly, negatively effecting the principles of liberal democracy, pluralism and rule of law enshrined in the Cambodian constitution.

Political dialogue between CPP and CNRP has declined to the detriment of the political process, causing the National Assembly to dysfunction. Political dialogue is essential if outstanding and controversial issues between the two leading parties are to be resolved for the good of the nation's future development.

**For further information, please contact**


- Mr. Koul Panha 012 942 019
- Mr. Korn Savang 011 884 840
- Mr. Sin Tithseiha 012 252 661

# របាយការណ៍ស្ដីពីលទ្ធផលនៃការសង្កេត
# រដ្ឋសភា និងតំណាងរាស្ត្រ

# ១. សង្ខេបការរកឃើញ

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃរដ្ឋសភានីតិកាលទី៥ ក្នុងឆ្នាំ២០១៦ រកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានទម្លាក់ ពិសេសក្រុមមតិភាគច្រើនដែលកាន់អំណាចបានបំពារបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រគណបក្សប្រឆាំង និងបន្ថយតួនាទីរបស់តំណាងរាស្ត្រគណបក្សប្រឆាំង និងព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិច។ តំណាងរាស្ត្រគណបក្សកាន់អំណាចនៃរដ្ឋសភាបានបើកផ្លូវឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំង។ ជាមួយគ្នានេះ គណបក្សកាន់អំណាចជាឯកបក្ស បានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាលុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់។ មានការលើកទឹកចិត្ត តម្លើងឋានន្តរសក្តិដល់អ្នកដៃដល់ដែលជាមន្ត្រីនៃកងកម្លាំងប្រដាប់អាវុធ កងអង្គរក្ស ដែលបានប្រើអំពើហិង្សាប្រឆាំងតំណាងរាស្ត្រគណបក្សមិតិភាពតិច។

ដោយឡែក សកម្មភាពការងាររបស់គណៈកម្មការជំនាញនៃរដ្ឋសភាវិញ គឺមានការថយចុះ ប៉ុន្តែសកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង បើធៀបនឹងឆ្នាំទី២ (ឆ្នាំ២០១៥)។ នៅស្របពេលដែលចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិក្នុងការពិភាក្សា និងអនុម័តច្បាប់ និងបរិមាណនៃការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភាក៏មានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥។

ក្នុងរយៈពេលចុងក្រោយនេះ រដ្ឋសភាដែលមានតែតំណាងរាស្ត្រពីគណបក្សកាន់អំណាច បានសម្រេចដោយអត្តនោម័តធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ប្រការ៤៨ថ្មី (បី) ដោយលុបចោលតួនាទីថ្នាក់ដឹកនាំតំណាងរាស្ត្រ និងតួនាទីប្រធានក្រុមមតិភាគតិចនៅក្នុងរដ្ឋសភា។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា៖** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញចំនួន៣លើក ដែលលើកទី១គឺការបន្តសម័យប្រជុំលើកទី៥ក្នុងចន្លោះដើមខែវិច្ឆិកា ដល់ដើមខែកុម្ភៈឆ្នាំ២០១៦ លើកទី២គឺសម័យប្រជុំលើកទី៦ ពីខែមេសាដល់ដើមខែកក្កដាឆ្នាំ២០១៦ និងលើកទី៣គឺសម័យប្រជុំលើកទី៧ ក្នុងខែតុលាឆ្នាំ២០១៦។

ក្នុងរយៈពេលនេះមានរបៀបវារៈចំនួន៣២ត្រូវលើកមកពិភាក្សា និងអនុម័តដែលរួមមាន៖ ព្រះរាជសាររបស់ព្រះមហាក្សត្រចំនួន០២ របាយការណ៍សង្ខេបរបស់រដ្ឋសភានៅចន្លោះសម័យប្រជុំពេញអង្គចំនួន០២ សេចក្តីព្រាងច្បាប់ចំនួន២១ ការបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តចំនួន០៤លើក ការសម្រេចឲ្យអាជ្ញាធរមានសមត្ថកិច្ចមានចំណាត់ការលើករណីតំណាងរាស្ត្រចំនួន០២លើក និងការបំភ្លឺចំពោះមុខរដ្ឋសភាចំនួន១លើក។

របៀបវារៈសំខាន់ៗចំនួន២១ ត្រូវបានរដ្ឋសភាអនុម័តដោយសំឡេងឯកបក្សដែលក្នុងនោះរួមមាន សេចក្តីព្រាងច្បាប់ចំនួន១៦ ការបោះឆ្នោតជ្រើសតាំងចំនួន០២លើក ការអនុម័តសេចក្តីសម្រេចចំនួន០២លើក និងការឆ្លើយបំភ្លឺចំនួន០១លើក។ ជាមួយគ្នានេះក៏មានរបៀបវារៈចំនួន១១ ត្រូវបានអនុម័តដោយមិនមានការពិភាក្សាដេញដោលលើខ្លឹមសារច្បាប់ដោយអ្នកតំណាងរាស្ត្រ។ ការសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិ និងបរិមាណនៃការបញ្ចេញមតិមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំទី២ នៅស្របពេលដែលតំណាងរាស្ត្រភាគច្រើននៅតែមិនបានឡើងបញ្ចេញមតិពិភាក្សាលើខ្លឹមសារច្បាប់ ដោយស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់។ ចំពោះសកម្មភាពពិភាក្សាដេញដោលវិញ របៀបវារៈមួយចំនួនដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចូលរួមពិភាក្សា គឺមានការពិភាក្សាដេញដោលផុសផុលដូចនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី២។

ខុមហ្វ្រែលសង្កេតឃើញថា នៅបន្ទាប់ពីមានការធ្វើពហិការមិនចូលរួមកិច្ចប្រជុំក្នុងរដ្ឋសភាពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនៅពាក់កណ្តាលឆ្នាំ២០១៦ (នៅក្រោយការវាយដំអ្នកតំណាងរាស្ត្រខ្លួន២រូបនៅមុខរដ្ឋសភា) ការអនុម័តសេចក្តីព្រាងច្បាប់នានា គឺមិនមានការពិភាក្សាសួរដេញដោលផុសផុល ដូចនៅពេលមានការចូលរួមប្រជុំពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនោះទេ។

នៅសម័យប្រជុំលើកទី៦ គណបក្សនយោបាយទាំងពីរក្នុងរដ្ឋសភាមានការខ្វែងគំនិតគ្នាលើការបកស្រាយមាត្រាក្នុងរដ្ឋធម្មនុញ្ញទាក់ទងទៅនឹងអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ព្រោះតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា (ដែលមានសំឡេងភាគច្រើន) បានសម្រេចឲ្យមានការចោទប្រកាន់ ការចាប់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិទាំងមានអភ័យឯកសិទ្ធិសភា។ ជុំវិញករណីនេះ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានចោទប្រកាន់ថា រដ្ឋសភាបានរំលោភរដ្ឋធម្មនុញ្ញ ហើយការសម្រេចនេះជារឿងនយោបាយ និងជាការគំរាមកំហែងទៅលើការបំពេញការងាររបស់អ្នកតំណាងរាស្ត្រ។ ស្របពេលគ្នានេះ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានសម្រេចធ្វើពហិការមិនចូលរួមប្រជុំក្នុងរដ្ឋសភាផងដែរ។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភា៖** នៅក្នុងឆ្នាំទី៣នេះ សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី២ (ឆ្នាំ២០១៥)។ ការសង្កេតរកឃើញថា គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន៦០លើក ខណៈដែលក្នុងឆ្នាំ២០១៥ គណៈកម្មការជំនាញនៃរដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន១០៥លើក។ ក្នុងចំណោមសកម្មភាពទាំងនេះ គណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន៣១លើក ហើយសកម្មភាពគណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានចំនួន២៩លើក។

សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាទាំងនោះរួមមានៈ ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ ការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ចឬ/និងប្រជាពលរដ្ឋដើម្បីពិនិត្យ និងស្វែងយល់ពីបញ្ហាកង្វល់នានាតាមមូលដ្ឋាន សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ ពិសេសបញ្ហាទំនាស់ដីធ្លី និងជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។

**សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងរយៈពេលនេះ សកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង ខណៈដែលគោលបំណងក្នុងការចុះមូលដ្ឋានភាគច្រើនក្នុងគោលបំណងទាក់ទាញប្រជាប្រិយភាព និងការគាំទ្រមកលើគណបក្សនយោបាយរបស់ខ្លួន ព្រោះថា ការបោះឆ្នោតខិតជិតមកដល់ក្នុងឆ្នាំ២០១៧។ មានសំណូមពរ និងសំណើជាច្រើន ត្រូវបានលើកឡើងក្នុងសកម្មភាពចុះមូលដ្ឋាននោះ ដែលសំណើមួយចំនួនទទួលបានការឆ្លើយតបភ្លាមៗនៅមូលដ្ឋាន និងមួយចំនួនទៀតត្រូវលើកយកមកពិនិត្យ និងសិក្សានៅរដ្ឋសភា។

ខុមហ្វ្រែលសង្កេតឃើញថា សកម្មភាពចុះមូលដ្ឋានមានចំនួន១៨០១លើ ដែលធ្វើសកម្មភាពដោយតំណាងរាស្ត្រចំនួន១០២រូបនៃតំណាងរាស្ត្រសរុបចំនួន១២៣រូប។ ចំនួនសកម្មភាពនេះជាចំនួនច្រើនមិនធ្លាប់មាន ចាប់តាំងពីចាប់ផ្តើមដំណើរការរដ្ឋសភានីតិកាលទី៥នេះ។ ក្នុងចំណោមសកម្មភាពទាំងនោះ មានតំណាងរាស្ត្រចំនួន៥៦រូបពីគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានចំនួន៦១៧លើក ហើយមានតំណាងរាស្ត្រចំនួន៤៥រូបពីគណបក្សសង្គ្រោះជាតិបានចុះមូលដ្ឋានសរុបចំនួន១១៨៤លើក។ សកម្មភាពទាំងនោះភាគច្រើន គឺផ្តោតលើការជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងការចុះពង្រឹងបណ្តាញផ្ទៃក្នុងរបស់គណបក្សនៅមូលដ្ឋាន។

**ការកោះហៅបំភ្លឺ៖** សកម្មភាពកោះហៅមកបំភ្លឺក្នុងរដ្ឋសភាមានការថយចុះជាងរយៈពេលដូចគ្នាក្នុងឆ្នាំទី២។ ក្នុងរយៈពេលនេះ មានការកោះអញ្ជើញរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងរដ្ឋសភាទាក់ទងនឹងការអនុវត្តវិស័យយុត្តិធម៌នៅកម្ពុជា។ ជាមួយគ្នានេះក៏មានការបំភ្លឺដោយផ្ទាល់មាត់ពីមន្ត្រីរាជរដ្ឋាភិបាលនៅក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា និងនៅតាមក្រសួងមន្ទីរមួយចំនួនផងដែរ។

**កិច្ចអន្តរាគមន៍របស់រដ្ឋសភា និងតំណាងរាស្ត្រ៖** ទាក់ទងនឹងកិច្ចអន្តរាគមន៍ក្នុងរយៈពេលនេះ ខុមហ្វ្រែលបានទទួលព័ត៌មានអំពីការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺនៅក្នុងរដ្ឋសភា ការទទួលបណ្តឹង និងអន្តរាគមន៍លើបណ្តឹងរបស់ប្រជាពលរដ្ឋ។ ការសង្កេតឃើញថា ការទទួលបណ្តឹងរបស់រដ្ឋសភាមានការថយចុះធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥។ ចំពោះការចេញលិខិតរបស់តំណាងរាស្ត្រវិញ គឺមានចំនួន២៤ច្បាប់ដែលក្នុងនោះមានថ្វាយព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងរដ្ឋសភាក្នុងគោលបំណងភាគច្រើនស្នើ ឬអំពាវនាវឲ្យចាត់វិធានការដើម្បីអន្តរាគមន៍រកដំណោះស្រាយបញ្ហានានា។

**ចំនួនលិខិតអន្តរាគមន៍ និងដោះស្រាយ៖** មានការខិតខំរបស់អ្នកតំណាងរាស្ត្រក្នុងការចេញលិខិតអន្តរាគមន៍រហូតដល់២៤ច្បាប់ ភាគច្រើនជាលិខិតរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ដើម្បីស្នើឲ្យមានការពន្យល់ បកស្រាយពីសមាជិករាជរដ្ឋាភិបាល និងស្នើចាត់វិធានការពីស្ថាប័នពាក់ព័ន្ធ រួមទាំងថ្វាយព្រះមហាក្សត្រ ប៉ុន្តែក្នុងនោះមានតែ១៦លិខិតប៉ុណ្ណោះ ត្រូវបានឆ្លើយតប។

**តំណាងរាស្ត្រ១០រូប ដែលសកម្មជាងគេ៖** ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលទទួលព័ត៌មានថា មានតំណាងរាស្ត្រ ៧រូប ពីគណបក្សសង្គ្រោះជាតិរួមមាន ឯកឧត្តម ហេង ដាណារ៉ូ ឯកឧត្តម អេង ឆៃអ៊ាង លោកជំទាវ កែ សុវណ្ណរតន៍ ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ ឯកឧត្តម កែវ ភិរម្យ ឯកឧត្តម ហូរ វ៉ាន់ និងឯកឧត្តម គង់ បូរ៉ា និង៣រូប ពីគណបក្សប្រជាជនកម្ពុជា រួមមាន លោកជំទាវ នួម សុភ័ណ លោកជំទាវ កៃ ច័ន្ទមុនី និងលោកជំទាវ ឡោក ខេង បានធ្វើសកម្មភាពច្រើនជាងគេ។ ដោយឡែក ចំពោះការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាវិញ តំណាងរាស្ត្រដែលសកម្មភាពជាងគេរួមមាន ៥រូប ពីគណបក្សប្រជាជនកម្ពុជារួមមាន ឯកឧត្តម ឈាង វុន ឯកឧត្តម ហែម ខន ឯកឧត្តម ជាម យៀប ឯកឧត្តម ម៉ុម ជឹមហ៊ុយ និងសម្តេច ហ៊ុន សែន និង៥រូប ពីគណបក្សសង្គ្រោះជាតិ រួមមាន ឯកឧត្តម សុន ឆៃ ឯកឧត្តម យី វណ្ណដេត ឯកឧត្តម ឡុង ប៊ុន្នី ឯកឧត្តម យឹម សុវណ្ណ និងឯកឧត្តម លិម គិមយ៉ា។

ការប្រើអំពើហិង្សា ការប្រើច្បាប់ និងការប្រើតុលាការចំពោះអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងយ៉ាងហោចណាស់ចំនួន០៤ករណី ដូចជាការដកតំណែងអនុប្រធានទី១នៃរដ្ឋសភាពីឯកឧត្តម កឹម សុខា ការវាយដំតំណាងរាស្ត្រ ការបញ្ចប់សុពលភាពតំណាងរាស្ត្ររបស់ឯកឧត្តម សម រង្ស៊ី និងការបើកឲ្យមានចំណាត់ការដោយតុលាការ និងអាជ្ញាធរ កងកំលាំងប្រដាប់អាវុធលើតំណាងរាស្ត្រទាំងនៅមានអភ័យឯកសិទ្ធិ ដូចចំពោះឯកឧត្តម កឹម សុខាជាដើម។ មានការប្រើកងកម្លាំងប្រដាប់អាវុធឃាត់រថយន្តឯកឧត្តម កឹម សុខា និងព័ទ្ធទីស្នាក់ការគណបក្សសង្គ្រោះជាតិរហូតដល់ឯកឧត្តម កឹម សុខា ឃុំខ្លួនឯងនៅក្នុងស្នាក់ការគណបក្សអស់រយៈពេលជាង៦ខែ។

ចំនួននៃការសន្ទនារបស់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិក៏បានធ្លាក់ចុះដែលមានចំនួន០២លើកប៉ុណ្ណោះ ហើយការសន្ទនារវាងគណបក្សទាំងពីរនៅក្នុងរដ្ឋសភាក៏មិនបានពេញលេញ។ ការសន្ទនាគ្នានេះត្រូវបានមើលឃើញថា ជាមធ្យោបាយមួយល្អក្នុងការដោះស្រាយការខ្វែងគំនិតគ្នារវាងគណបក្សទាំងពីរ និងបញ្ហាជាតិនានា។

# អំពីរដ្ឋសភា និងតំណាងរាស្ត្រ

## ២. ដំណើរការប្រជុំរបស់រដ្ឋសភា

នៅចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ខែតុលា ឆ្នាំ២០១៦ រដ្ឋសភានីតិកាលទី៥បានបើកសម័យប្រជុំពេញអង្គសាមញ្ញចំនួន៣លើកដែលមានរបៀបវារៈសរុបចំនួន៣២។ សម័យប្រជុំទាំង៣លើកនោះរួមមាន លើកទី១ ការបន្តសម័យប្រជុំលើកទី៥ (គិតពីចុងខែវិច្ឆិកា ២០១៥ ដល់ដើមខែកុម្ភៈ ២០១៦) មានរបៀបវារៈចំនួន០៩ លើកទី២ សម័យប្រជុំលើកទី៦ (គិតពីខែមេសា ដល់ដើមខែកក្កដា២០១៦) មានរបៀបវារៈចំនួន១៥ និងលើកទី៣ សម័យប្រជុំលើកទី៧ (គិតពីខែតុលា ឆ្នាំ២០១៦) មានរបៀបវារៈចំនួន០៨។




របៀបវារៈទាំង៣២នោះរួមមានៈ ព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំរដ្ឋសភាចំនួន២លើកក្នុងសម័យប្រជុំលើកទី៦ និងសម័យប្រជុំលើកទី៧ របាយការណ៍សង្ខេបចន្លោះសម័យប្រជុំរបស់រដ្ឋសភាចំនួន២លើក គឺចន្លោះសម័យប្រជុំលើកទី៥ និងទី៦ និងចន្លោះសម័យប្រជុំលើកទី៦ និងទី៧ សេចក្តីព្រាងច្បាប់ចំនួន២១ ការបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តចំនួន៤លើក, ការបំភ្លឺដោយផ្ទាល់មាត់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចំនួន១លើក និងការអនុម័តសេចក្តីសម្រេចចំនួន២លើក។

សេចក្តីព្រាងច្បាប់ចំនួន២១ដែលត្រូវបានរដ្ឋសភាធ្វើការពិភាក្សា និងអនុម័តរួមមានៈ ១.)សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ២.)សេចក្តីព្រាងច្បាប់ ស្តីពីស្ថិតិ ៣.)សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ៤.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ១នៃកិច្ចព្រមពៀងម៉ារ៉ាកេស ៥.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន ៦.)សេចក្តីព្រាងច្បាប់ ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ៧.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមពៀង ស្តីពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ៨.)សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ៩.)សេចក្តីព្រាងច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម ១០.)សេចក្តីព្រាងច្បាប់ ស្តីពីសហជីព ១១.)សេចក្តីព្រាងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ១២.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលហុងគ្រីស្តីពីការជំរុញ និងការពារគ្នាទៅវិញទៅមកនៃវិនិយោគ ១៣.)សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ១៤.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្ត

កញ្ចប់កិច្ចសន្យាទី៧ និងទី៨ សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ១៥.) សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ៖ ១-កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។ ២-ពិធីសារទី១ ស្តីពីការមិនកំណត់សិទ្ធិហោះហើរ ទី៣ និងទី៤ រវាងចំណុចណាមួយនៅក្នុងទឹកដីបណ្តាភាគីចុះកិច្ចព្រមព្រៀង។ ៣- ពិធីសារទី២ ស្តីពីសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង។ ១៦.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ១៧.)សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ១៨.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ស្តីពីប្រព័ន្ធឆ្លងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ១៩.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៦នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ២០.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ និង២១.)សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជារតែមួយអាស៊ាន។

របៀបវារៈស្តីពីការបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តមានចំនួន៤លើក ដែលរដ្ឋសភាបានអនុម័តរួមមាន៖ ការបោះឆ្នោតជ្រើសតាំងលើសមាសភាពសមាជិករាជរដ្ឋាភិបាលដែលត្រូវកែសម្រួល និងបំពេញបន្ថែមចំនួន២៦រូប ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន១រូប និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន១រូប និងការបោះឆ្នោតទុកចិត្តអគ្គសវនករចំនួន០១រូប និងអគ្គសវនកររង០២រូប នៃអាជ្ញាធរសវនកម្មជាតិសម្រាប់បន្តអាណត្តិ៥ឆ្នាំ។

ចំពោះរបៀបវារៈស្តីពីសេចក្តីសម្រេចចំនួន២លើក ដែលរដ្ឋសភាបានប្រជុំសម្រេចដែលរួមមាន៖ ការប្រជុំសម្រេចលើករណីឯកឧត្តម អ៊ុំ សំអានតំណាងរាស្ត្រមណ្ឌលខេត្តសៀមរាបដែលក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន និងការប្រជុំសម្រេចលើករណីឯកឧត្តម គឹម សុខាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាមដែលក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់។

## ២.១ ការប្រជុំពេញអង្គរបស់រដ្ឋសភា

### ២.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា

ការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំក្នុងរយៈពេលនេះ មិនមានភាពផុសផុលដូចនឹងការបញ្ចេញមតិក្នុងកិច្ចប្រជុំក្នុងរយៈពេលដូចគ្នាក្នុងរបាយការណ៍ប្រចាំឆ្នាំលើកទី២ (ឆ្នាំ២០១៥)។ ការសង្កេតឃើញថា មានរបៀបវារៈខ្លះមិនមានការពិភាក្សាដេញដោល និងរបៀបវារៈខ្លះទៀត ការបញ្ចេញមតិរបស់តំណាងរាស្ត្រគឺគ្រាន់តែបង្ហាញនូវជំហរគាំទ្រ និងសរសើរពីសេចក្តីព្រាងច្បាប់ និងកិច្ចខិតខំរបស់រដ្ឋាភិបាល។ របៀបវារៈមួយចំនួនត្រូវបានអនុម័តដោយឯកបក្ស និងមិនមានការដេញដោលពិភាក្សាគ្នាក្នុងកិច្ចប្រជុំ។ ជាមួយគ្នានេះ ក៏មានការធ្វើពហិការមិនចូលរួមប្រជុំពិភាក្សាពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ខណៈដែលក្នុងឆ្នាំទី២ មិនមានការធ្វើពហិការនោះទេ។

បន្ថែមលើនេះ ការបញ្ចេញមតិរបស់តំណាងរាស្ត្រ ហាក់ដើរលើបន្ទាត់នយោបាយនៃគណបក្សរៀងៗខ្លួន។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សកាន់អំណាច ភាគច្រើននៃការឡើងបញ្ចេញមតិបង្ហាញនូវគោលជំហរក្នុងការគាំទ្រ និងលើកសរសើរពីសេចក្តីច្បាប់ដែលស្នើដោយរដ្ឋាភិបាល មិនសូវមានការជជែកអំពីខ្លឹមសារច្បាប់ ដោយតែងតែលើកហេតុផលថា ត្រូវបានពិនិត្យ និងជជែកដេញដោលក្នុងគណៈកម្មការជំនាញទទួលបន្ទុកសិក្សា និងពិនិត្យសេចក្តីព្រាងច្បាប់ទាំងនោះរួចរាល់ហើយ។ ជាងនេះទៅទៀត ខ្លឹមសារនៃការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រមួយចំនួនគឺលាយលំនឹងការរិះគន់លើតំណាងរាស្ត្រពីគណបក្សប្រឆាំងដែលថ្លែងរិះគន់ និងវាយប្រហារលើការអនុវត្តការងាររបស់រាជរដ្ឋាភិបាល។ គួរកត់សម្គាល់ថា

ការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សកាន់អំណាចនៃរយៈពេលសង្កេតក្នុងឆ្នាំទី១ និងឆ្នាំទី២ មានការជជែកដេញដោល លើកជាសំណើបំភ្លឺ និងស្នើបន្ថែមចំណុចមួយចំនួនលើសេចក្តីព្រាងច្បាប់ទៅតំណាងរាជរដ្ឋាភិបាលដែលមកការពារសេចក្តីព្រាងច្បាប់។

ជាក់ស្តែងកិច្ចប្រជុំពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញពីគណបក្សសង្គ្រោះជាតិ ទទួលរងការរិះគន់ពីប្រធានគណៈកម្មការជំនាញទី២នៃរដ្ឋសភា ឯកឧត្តម ជាម យៀប លើការលើកសំណួរសួរទៅកាន់រដ្ឋាភិបាលជុំវិញភាពមិនប្រក្រតីក្នុងការប្រើប្រាស់គម្រោងថវិកាចំណាយរបស់ក្រសួងមួយចំនួនថា ជាការមិនយកចិត្តទុកដាក់ក្នុងការពិនិត្យឯកសារដែលរដ្ឋសភាផ្ញើជូន និងថាសំណួរដែលបានលើកជាសំណួរដដែលៗដែលបានសួរ និងឆ្លើយតបពីតំណាងរាជរដ្ឋាភិបាលរួចហើយក្នុងពេលប្រជុំរបស់គណៈកម្មការ។

ខុមហ្វ្រែលសង្កេតឃើញថា អ្នកតំណាងរាស្ត្រដែលចូលរួមប្រជុំភាគច្រើន គឺបន្តរក្សាភាពស្ងៀមស្ងាត់មិនបានឡើងបញ្ចេញមតិដូចក្នុងឆ្នាំទី១ និងទី២ដែរ ខណៈដែលតំណាងរាស្ត្រឡើងបញ្ចេញមតិភាគច្រើនគឺសមាសភាពដដែលៗ។

ក្នុងអំឡុងពេលដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើពហិការមិនចូលរួមប្រជុំពិភាក្សា ការសង្កេតឃើញថាភាគច្រើននៃតំណាងរាស្ត្រឡើងបញ្ចេញមតិ គឺមិនបានផ្តោតលើខ្លឹមសារច្បាប់ ឬការបញ្ចេញមតិជជែកពិភាក្សាសួរដេញដោលទៅអ្នកការពារច្បាប់នោះទេ ដោយគ្រាន់តែឡើងមកគាំទ្រលើរបៀបវារៈ និងការលើកសរសើរកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ ជាក់ស្តែង សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គ មនុស្ស មានតំណាងរាស្ត្រ២រូបប៉ុណ្ណោះដែលបានឡើងបញ្ចេញមតិ។

*តារាងទី១. តារាងអ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងគេ ១០រូប (គិតជានាទី)*

| ល.រ | គោត្តនាម និងនាម | គណបក្ស | ចំនួននាទី | | | |
|---|---|---|---|---|---|---|
| | | | អព្យាក្រឹត | វិជ្ជមាន | អវិជ្ជមាន | សរុប |
| ១ | សុន ឆៃ | | ១០៥ | ០៤ | ០២ | ១១១ |
| ២ | ឈាង វុន | | ២៩ | ១៥ | ០២ | ៤៦ |
| ៣ | ហែម ខន | | ២៣ | ០៤ | ០០ | ២៧ |
| ៤ | ជាម យៀប | | ១៤ | ០៤ | ០២ | ៤៧ |
| ៥ | ម៉ុម ជឹមហ៊ុយ | | ១២ | ០៤ | ០០ | ១៦ |
| ៦ | ឃី វណ្ណដេត | | ១២ | ០២ | ០១ | ១៥ |
| ៧ | ហ៊ុន សែន | | ១៣ | ០០ | ០០ | ១៣ |
| ៨ | ឡុង បុរី | | ១១ | ០១ | ០១ | ១៣ |
| ៩ | យឹម សុវណ្ណ | | ១៣ | ០០ | ០០ | ១៣ |
| ១០ | លិម គិមយ៉ា | | ០៧ | ០២ | ០៤ | ១៣ |

ខុមប្រែ្វលសូមស្រង់មតិរបស់តំណាងរាស្ត្រពីររូប ក្នុងចំណោមតំណាងរាស្ត្រដែលបានបញ្ចេញមតិច្រើនជាងគេក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា។ ការបញ្ចេញមតិរបស់ឯកឧត្តម សុន ឆៃ នៅក្នុងកិច្ចពិភាក្សាច្បាប់ស្តីពីសហជីព មតិក្នុងន័យអព្យាក្រឹត្យ៖ «តាងនាមឲ្យគណបក្សសង្គ្រោះជាតិ ខ្ញុំសូមស្នើឲ្យការរៀបចំសេចក្តីព្រាងច្បាប់នេះ ធានាបាននូវសិទ្ធិទាំងឡាយរបស់កម្មករ... ចង់ឃើញសុខដុមរមនារវាងកម្មករ និងនិយោជក... ដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋខ្មែរ....»។ មតិក្នុងន័យវិជ្ជមាន៖ «ខ្ញុំសូមសម្តែងការកោតសរសើរចំពោះការបំពេញភារកិច្ចរបស់ក្រសួងក្នុងការកែទម្រង់កន្លងមកនេះ....»។ មតិក្នុងន័យអវិជ្ជមាន៖ «សេចក្តីព្រាងច្បាប់នេះមានលក្ខណៈមិនទាន់សមស្រប មិនអាចធានាឲ្យមានការគោរពអនុសញ្ញាទាំងឡាយ និងរដ្ឋធម្មនុញ្ញបានត្រឹមត្រូវ មិនទាន់ទទួលយកបាន...»។ ដោយឡែក ការបញ្ចេញមតិរបស់ឯកឧត្តម ឈាង វុន នៅក្នុងកិច្ចពិភាក្សាច្បាប់ស្តីពីសហជីពនេះដែរ មតិក្នុងន័យអព្យាក្រឹត្យ៖ «យើងជជែកគ្នាពីច្បាប់សហជីព យើងមិនមែនធ្វើការងារនូវសហជីពណាមួយនោះទេ... រដ្ឋាភិបាលត្រូវការពារទាំងកម្មករទាំងនិយោជក និងសម្របសម្រួលធ្វើយ៉ាងណាឲ្យកម្មកររស់ និយោជករស់ទាំងអស់គ្នា...»។ មតិក្នុងន័យវិជ្ជមាន៖ «ខ្ញុំសូមកោតសរសើរឯកឧត្តម អ៊ិត សំហេងក្នុងនាមសេនាធិការរដ្ឋាភិបាល ដែលបានរៀបចំច្បាប់នេះឡើង...»។

មតិក្នុងន័យអវិជ្ជមាន៖ ថ្លែងសំដៅលើតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ «ខ្ញុំមានការសោកស្តាយណាស់ ចំពោះសំណួរដែលលើកឡើង.... អ្វីដែលសោកស្តាយមែនទែននោះ...ម៉េចក៏មានស្តង់ដារពីរ ម៉េចមិនធ្វើស្តង់ដារតែមួយ...»។

### ២.១.២ ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា

ចំពោះការបញ្ចេញមតិជាបរិមាណរបស់តំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភាវិញ ការសង្កេតឃើញថា ហាក់មិនសូវផុសផុល បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី២ (ឆ្នាំ២០១៥)។ ការថយចុះនេះដោយហេតុថា មានការខ្វែងគំនិតគ្នារវាងគណបក្សទាំងពីរលើចំណាត់ការរបស់រដ្ឋសភាចំពោះតំណាងរាស្ត្រគណបក្សប្រឆាំង អំពើហិង្សាលើអ្នកតំណាងរាស្ត្រ និងការប្រើប្រាស់ស្ថាប័នតុលាការក្នុងចោទប្រកាន់ និងផ្តន្ទាទោសលើសកម្មជន និងមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ ដែលឈានដល់ការធ្វើពហិការមិនចូលរួមប្រជុំពីតំណាងរាស្ត្រនេះ។ ជាមួយគ្នានេះ របៀបវារៈខ្លះត្រូវបានអនុម័តតែឯកបក្ស និងមិនមានការពិភាក្សា។

ក្នុងរយៈពេលនេះមានតំណាងរាស្ត្រចំនួន១៨រូបប៉ុណ្ណោះបានឡើងបញ្ចេញមតិពិភាក្សាលើរបៀបវារៈទាំង៣២ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ មានតំណាងរាស្ត្រចំនួន៤៣រូបបានឡើងបញ្ចេញមតិពិភាក្សា។ គណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្រចំនួន០៨រូប (ក្នុងចំណោម៦៨រូប) បានឡើងបញ្ចេញមតិចំនួន១២ដង។ រីឯគណបក្សសង្គ្រោះជាតិដែលមានតំណាងរាស្ត្រ១០រូប (ក្នុងចំណោម៥៥រូប) បានឡើងបញ្ចេញមតិចំនួន២០ដង។ ជាការកត់សម្គាល់ បើទោះជាមានការធ្វើពហិការមិនចូលរួមប្រជុំ ប៉ុន្តែបរិមាណនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។

### ២.១.៣ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស

ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា ត្រូវបានវិភាគដោយបែងចែកជាបីសូរ(Tone)គឺ៖ អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន ចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។ ខ្លឹមសារអព្យាក្រឹត្យ គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។ ចំណែកឯវិជ្ជមានគឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់ គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។ រីឯអវិជ្ជមានវិញ គឺនិយាយពីគុណវិបត្តិរបស់សេចក្តីព្រាងច្បាប់ គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។

ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រទាំង ១៨រូប បានចំណាយរយៈពេលសរុបចំនួន ៣៤៦នាទី (ស្មើនឹង០៥ម៉ោង៤៦នាទី)។ តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន ០៨រូប បានឡើងបញ្ចេញមតិសរុបចំនួន ១៤៣នាទី (ស្មើនឹង០២ម៉ោង៣៨នាទី) រីឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន១០រូប បានឡើងបញ្ចេញមតិសរុបចំនួន ២០៣នាទី (ស្មើនឹង០៣ម៉ោង២៣នាទី)។




ចំពោះខ្លឹមសារនៃការបញ្ចេញមតិតំណាងរាស្ត្រនាពេលនេះ ខុមប្រែហ្វលសង្កេតឃើញថា ការបញ្ចេញមតិភាគច្រើនផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ និងវិជ្ជមាន។ ក្នុងនោះខ្លឹមសារបែបអព្យាក្រឹត្យបានចំនួន ៣១៣នាទី (ស្មើនឹង០៥ម៉ោង១៣នាទី) និងវិជ្ជមានបានចំនួន ២៥នាទី ចំណែកខ្លឹមសារអវិជ្ជមានបានចំនួន ០៨នាទីប៉ុណ្ណោះ។

### ២.១.៤ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សទៅលើតួអង្គ ស្ថាប័ន និងចំណុចផ្សេងៗ

តារាងខាងក្រោមនេះ បានបង្ហាញពីខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រ តាមគណបក្សទៅលើតួអង្គ ឬស្ថាប័ននានានៅក្នុងសម័យប្រជុំពេញអង្គទាំង១៨កិច្ចប្រជុំ។ អ្នកតំណាងរាស្ត្របានបញ្ចេញមតិក្នុងខ្លឹមសារបែបអព្យាក្រឹត្យ អវិជ្ជមាន និងវិជ្ជមាន។

*<u>ក្រាហ្វិកទី១៖ ចំនួននាទី និងភាគរយការបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា</u>*




ការសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជា បានឡើងបញ្ចេញមតិចំនួន១៤៣នាទីដែលក្នុងនោះអ្នកតំណាងរាស្ត្រ បានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យចំនួន៩៤នាទីស្មើនឹង៦៦%នៃការបញ្ចេញមតិសរុប។ ចំណែកឯការបញ្ចេញមតិក្នុងន័យវិជ្ជមានចំនួន៤៣នាទីស្មើនឹង៣០% នៃការបញ្ចេញមតិសរុប ខណៈដែរការបញ្ចេញមតិក្នុងន័យអវិជ្ជមាន មានចំនួន ០៦នាទី ស្មើនឹង ០៤%នៃការបញ្ចេញមតិសរុប។

*ក្រាហ្វិកទី២៖ ចំនួននាទី និងភាគរយការបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ*




ការសង្កេតឃើញថា គណបក្សសង្គ្រោះជាតិបានឡើងបញ្ចេញមតិចំនួន ២០៣នាទី ក្នុងនោះអ្នកតំណាងរាស្ត្របានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យចំនួន១៧៥នាទី ស្មើនឹង ៨៦%នៃការបញ្ចេញមតិសរុប។ ចំណែកឯការបញ្ចេញមតិក្នុងន័យវិជ្ជមានមានចំនួន១៦នាទី ស្មើនឹង ០៩%នៃការបញ្ចេញមតិសរុប ខណៈដែរការបញ្ចេញមតិក្នុងន័យអវិជ្ជមានមានចំនួន១២នាទីស្មើនឹង ៥%នៃការបញ្ចេញមតិសរុប។

*តារាងទី២៖ ខ្លឹមសារនៃការបញ្ចេញមតិទាំងបីចំណុចសំខាន់ៗរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស (គិតជានាទី)៖*

| ល.រ | ចំណុចដែលពាក់ព័ន្ធ | គណបក្សប្រជាជនកម្ពុជា | | | គណបក្សសង្គ្រោះជាតិ | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | (នាទី) |
| ១ | របៀបវារៈកំពុងពិភាក្សា | ៣៥ | ១៣ | ០ | ៨៤ | ០៨ | ០ | ១៤០ |
| ២ | នាយករដ្ឋមន្ត្រី | ០៤ | ០ | ០ | ០ | ០ | ០ | ០៤ |
| ៣ | រាជរដ្ឋាភិបាល | ២៣ | ២៥ | ០ | ២៧ | ០៨ | ១០ | ៩៣ |
| ៤ | ប្រធានរដ្ឋសភា | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | រដ្ឋសភា | ០៤ | ០ | ០ | ០១ | ០ | ០ | ០៥ |
| ៦ | គណៈកម្មការនានារបស់រដ្ឋសភា | ០៤ | ០ | ០ | ០ | ០ | ០ | ០៤ |
| ៧ | ប្រធានព្រឹទ្ធសភា | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | ស្ថាប័នព្រឹទ្ធសភា និងសមាជិក | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | គណបក្សខ្លួនគាត់ | ០ | ០ | ០ | ០១ | ០ | ០ | ០១ |
| ១០ | គណបក្សដទៃទៀត | ០១ | ០ | ០២ | ០ | ០ | ០ | ០៣ |
| ១១ | តំណាងរាស្ត្រខ្លួនឯង | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១២ | តំណាងរាស្ត្រដទៃទៀត | ០ | ០ | ០៤ | ០២ | ០ | ០ | ០៦ |
| ១៣ | មណ្ឌល (ខេត្ត/រាជធានី) របស់គាត់ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៤ | មណ្ឌល (ខេត្ត/រាជធានី) ផ្សេងទៀត | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៥ | តុលាការ | ០ | ០ | ០ | ០ | ០ | ០២ | ០២ |
| ១៦ | បញ្ហាស្ត្រី | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៧ | អនុសាសន៍លើច្បាប់កំពុងពិភាក្សា | ០២ | ០ | ០ | ១៨ | ០ | ០ | ២០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៨ | សំណួរ/សុំការបំភ្លឺលើច្បាប់កំពុងពិភាក្សា | ០៩ | ០៥ | ០ | ២៧ | ០ | ០ | ៤១ |
| ១៩ | យុវជន | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ២០ | បញ្ហាផ្សេងៗ | ១២ | ០ | ០ | ១៥ | ០ | ០ | ២៧ |
| សរុប | | ៩៤ | ៤៣ | ០៦ | ១៧៥ | ១៦ | ១២ | ៣៤៦ |
| | | ១៤៣ | | | ២០៣ | | | |

ការសង្កេតឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយទាំងពីរផ្តោតសំខាន់ទៅលើចំណុចពាក់ព័ន្ធចំនួន៣ ដែលបានចំណាយរយៈពេលច្រើនជាងគេក្នុងចំណោមតួអង្គ និងស្ថាប័នទាំង២០ចំណុចដែលបានកំណត់។ ចំណុចទាំង៣ នៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្របានផ្តោតខ្លាំងរួមមាន៖ ទី១.របៀបវារៈកំពុងពិភាក្សា ទី២.តួអង្គរាជរដ្ឋាភិបាល និងទី៣.សំណួរ/សុំការបំភ្លឺលើច្បាប់កំពុងពិភាក្សា ដែលអ្នកតំណាងរាស្ត្រចំណាយរយៈពេលសរុបចំនួន ២៧៤នាទី (០៤ម៉ោង៣៤នាទី) ស្មើនឹង៧៩% នៃរយៈពេលនៃការបញ្ចេញមតិសរុប។

ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រទាក់ទងនឹងការលើករបៀបវារៈកំពុងពិភាក្សា មានរយៈពេលចំនួន ១៤០នាទី ស្មើនឹង៤០% នៃចំនួនរយៈពេលការបញ្ចេញមតិសរុប រីឯការបញ្ចេញមតិជាខ្លឹមសារពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល គឺសំដៅទៅលើតួអង្គរាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាល ត្រូវបានតំណាងរាស្ត្រប្រើពេលបញ្ចេញមតិចំនួន ៩៣នាទី ស្មើនឹង ២៧% នៃចំនួនរយៈពេលការបញ្ចេញមតិសរុប និងការបញ្ចេញមតិជាខ្លឹមសារពាក់ព័ន្ធលើការដាក់សំណួរ/សុំការបំភ្លឺលើច្បាប់កំពុងពិភាក្សាមាន រយៈពេលចំនួន៤១នាទី ស្មើនឹង ១២%នៃចំនួនរយៈពេលការបញ្ចេញមតិសរុប។

ចំពោះសូរ(Tone) នៃការបញ្ចេញមតិរបស់តំណាងរាស្ត្រលើចំណុចដែលពាក់ព័ន្ធ ការសង្កេតឃើញថា តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យចំនួន ៩៤នាទី រីឯតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានបញ្ចេញមតិចំនួន ១៧៥នាទី។ រីឯការបញ្ចេញមតិក្នុងន័យវិជ្ជមាន តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិចំនួន ៤៣នាទី ខណៈតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំណាយពេលបញ្ចេញមតិចំនួន ១៦នាទី។ ចំណែកការបញ្ចេញមតិក្នុងន័យបែបអវិជ្ជមានវិញ តំណាងរាស្ត្រពីគណបក្សប្រជាកម្ពុជា ចំណាយពេលបញ្ចេញមតិចំនួន ០៦នាទី រីឯតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំណាយពេលបញ្ចេញមតិចំនួន ១២នាទី។

ការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ផ្តោតលើខ្លឹមសារអព្យាក្រឹត្យ និងវិជ្ជមាន ខណៈដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិផ្តោតលើខ្លឹមសារបែបអព្យាក្រឹត្យ។

### ២.១.៥ គុណភាពនៃការពិភាក្សា និងអនុម័តច្បាប់/របៀបវារៈ

ក្នុងរយៈពេលនេះ រដ្ឋសភានីតិកាលទី៥ បានអនុម័តសេចក្តីព្រាងច្បាប់ និងវិសោធនកម្មច្បាប់បានចំនួន២១ច្បាប់។ ការសង្កេតលើការអនុម័តច្បាប់ឃើញថា មានសេចក្តីព្រាងច្បាប់មួយចំនួនត្រូវបានអនុម័តដោយមានលក្ខណៈប្រញាប់ប្រញាល់ និងស្ទើរតែមិនមានការពិភាក្សាដេញដោលក្នុងកិច្ចប្រជុំ ខណៈមានសេចក្តីព្រាងច្បាប់មួយចំនួនទៀត ត្រូវអនុម័តដោយសំឡេងគាំទ្រឯកបក្ស។ ការផ្តល់អនុសាសន៍ និងមតិយោបល់មួយចំនួនរបស់អ្នកតំណាងរាស្ត្រក្នុងកិច្ចពិភាក្សាឲ្យដល់តំណាងរាជរដ្ឋាភិបាល (អ្នកការពារច្បាប់) ធ្វើការបន្ថែម ឬកែតម្រូវ និងស្នើឲ្យលុបមាត្រាមួយចំនួន ប៉ុន្តែសំណើទាំងនេះត្រូវបានបដិសេធ។

សេចក្តីព្រាងច្បាប់សំខាន់ៗដូចជា៖ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន សេចក្តីព្រាងច្បាប់ស្តីពីសហជីព ត្រូវបានរដ្ឋសភាអនុម័តដោយគ្មានសំឡេងគាំទ្រពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងធ្វើឡើងដោយប្រើរយៈពេលត្រឹមតែ១កិច្ចប្រជុំប៉ុណ្ណោះ (១ព្រឹក) ក្នុងការ

ពិភាក្សា និងអនុម័ត។ ខណៈដែលសេចក្តីព្រាងស្តីពីសហជីពត្រូវបានមជ្ឈដ្ឋានជាតិ និងអន្តរជាតិលើពីការព្រួយបារម្ភ និងទាមទារឲ្យមានការពន្យល់ និងដកមាត្រាមួយចំនួនដែលរឹតត្បិតដល់សិទ្ធិប្រមូលផ្តុំ និងការចូលរួមដោយសេរី។

នៅចុងសម័យប្រជុំពេញអង្គលើកទី៥ ការសង្កេតឃើញថា មានការបញ្ចេញមតិពិភាក្សា និងអនុម័តយ៉ាងផុសផុលពោលគឺ មានការបញ្ចេញមតិសួរដេញដោលទាំងពីតំណាងរាស្ត្រដែលមានសំឡេងភាគច្រើន និងសំឡេងភាគតិចនៅរដ្ឋសភា។ ទោះជាយ៉ាងណាសេចក្តីព្រាងច្បាប់ចំនួន០៣ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី សេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ គឺមានតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានឡើងបញ្ចេញមតិគាំទ្រ និងធ្វើការកោតសរសើរក្រុមការងារតាក់តែងច្បាប់ ប៉ុន្តែពុំមានការជជែកសួរដេញដោល និងថែមទាំងស្នើមិនឲ្យមានការពិភាក្សាទៀតផង ដោយអះអាងថាសេចក្តីព្រាងច្បាប់ទាំងនេះត្រូវបានពិនិត្យ និងពិគ្រោះយោបល់គ្នារវាងក្រុមការងារតាក់តែងច្បាប់ និងគណៈកម្មការជំនាញនៃរដ្ឋសភារួចរាល់អស់ហើយ។

ចំណែកឯសម័យប្រជុំលើកទី៦ នៃរដ្ឋសភា នីតិកាលទី៥ ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីសហជីព អនុសាសន៍ និងសំណូមពរមួយចំនួនរបស់តំណាងរាស្ត្រពីគណបក្សប្រឆាំងឡើងនៅក្នុងកិច្ចប្រជុំ ត្រូវបដិសេធមិនទទួលយកទៅពិចារណាពីតំណាងរាជរដ្ឋាភិបាល (អ្នកការពារច្បាប់)។ តំណាងរាស្ត្របានស្នើឲ្យកែប្រែពាក្យក្នុងមាត្រាមួយចំនួនដូចជាពាក្យ «ឡុកឡៀ» ទៅជាភាសាខ្មែរ និងបន្ថែមនូវសន្ទានុក្រមបកស្រាយពាក្យនៃមាត្រាក្នុងច្បាប់ ប៉ុន្តែត្រូវតំណាងរាជរដ្ឋាភិបាលបដិសេធ មិនទទួលសំណើទាំងនោះ ដោយបញ្ជាក់ហេតុផលថា ពាក្យខ្លះមានពន្យល់នៅក្នុងក្រមរដ្ឋប្បវេណី និងបានជម្រាបឲ្យវាគ្មិនតំណាងរាស្ត្រស្នើនោះទៅសាកសួរកម្មករ កម្មការនីពីពាក្យទាំងនេះ ដែលតំណាងរដ្ឋាភិបាលអះអាងថា ពួកគាត់គ្រប់គ្នាស្គាល់ពាក្យទាំងនេះអស់ហើយ និងច្បាស់ទៀតផង។

ខុមហ្វ្រែលសង្កេតឃើញថា អនុសាសន៍ និងសំណើភាគច្រើនដែលត្រូវបានលើកឡើងក្នុងកិច្ចប្រជុំដោយអ្នកតំណាងរាស្ត្រមិនត្រូវបានទទួលយកពីតំណាងរាជរដ្ឋាភិបាល (អ្នកការពារច្បាប់)ឡើយ។

*<u>តារាងទី៣៖ តារាងរបៀបវារៈដែលសភាអនុម័តដោយមិនមានវត្តមាន/សំឡេងគាំទ្រពីគណបក្សសង្គ្រោះជាតិ</u>*

| ល.រ | របៀបវារៈ | ថ្ងៃខែពិភាក្សា និងអនុម័ត | រយៈពេលពិភាក្សា | សំឡេងអនុម័ត | កំណត់សម្គាល់ |
|---|---|---|---|---|---|
| ១ | - ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦<br>- ច្បាប់ស្តីពី ស្ថិតិ<br>- ច្បាប់ស្តីពី ទូរគមនាគមន៍ | សម័យប្រជុំលើកទី៥ នីតិកាលទី៥ នៅថ្ងៃទី ៣០ វិច្ឆិកា ២០១៥ | ៣០៨ នាទី | ៦៦ សំឡេង | - ចូលរួមពីដោយគណបក្សទាំងពីរតែ គណបក្សសង្គ្រោះជាតិមិនចូលរួមក្នុងការអនុម័ត<br>- មានភាពមិនប្រក្រតីមួយចំនួនចំពោះការចំណាយ និងមិនមានឯកសារត្រឹមត្រូវ |
| ២ | - ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ២០១៥ | សម័យប្រជុំ លើកទី៥ នីតិកាលទី៥ នៅថ្ងៃទី ១៣ មករា ឆ្នាំ២០១៦ | ២៨៥ នាទី | ៦៦ សំឡេង | - ចូលរួមប្រជុំទាំងពីរគណបក្ស ប៉ុន្តែតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមិនចូលរួមក្នុងការអនុម័ត<br>- មានភាពមិនប្រក្រតីមួយចំនួនចំពោះការចំណាយ និងមិនមានឯកសារត្រឹមត្រូវ<br>- ឯកសារមិនទាន់គ្រប់គ្រាន់ និងយឺតយ៉ាវក្នុងការផ្ញើទៅសវនករដើម្បីធ្វើសវនកម្ម |

| | | | | | |
|---|---|---|---|---|---|
| ៣ | - ច្បាប់ស្តីពី សហជីព | សម័យប្រជុំរដ្ឋសភាពេញអង្គលើកទី៦ នីតិកាលទី៥ នៅថ្ងៃទី ១២ មេសា ឆ្នាំ២០១៦ | ៣៣២ នាទី | ៦៧ សំឡេង | - ចូលរួមប្រជុំទាំងពីរគណបក្ស ប៉ុន្តែតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមិនចូលរួមក្នុងការអនុម័ត<br>-អនុសាសន៍របស់ខ្លះតំណាងរាស្ត្រត្រូវបដិសេដមិនយកទៅពិនិត្យ និងកែប្រែ<br>- មានភាពចម្រូងចម្រាស់លើខ្លឹមសារនៃមាត្រាមួយចំនួនក្នុងច្បាប់នេះដែលតំណាងរាស្ត្រគណបក្ស និងក្រុមសហជីពស្នើឲ្យធ្វើការកែតម្រូវ |
| ៤ | ការសម្រេចករណី ឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលខេត្ត សៀមរាបដែលក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន | សម័យប្រជុំ លើកទី៦ នីតិកាលទី៥ ថ្ងៃទី១២ មេសា ឆ្នាំ២០១៦ | ២០នាទី | ៦៤ សំឡេង | - មិនមានវត្តមានតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចូលរួម ព្រោះមានការខ្វែងគំនិតគ្នារវាងគណបក្សទាំងពីរ<br>- ការអនុម័តចំណាយពេលប្រមាណ ២០ នាទី |
| ៥ | - ការសម្រេចករណី ឯកឧត្តម កឹម សុខា តំណាងរាស្ត្រមណ្ឌលកំពង់ចាម ដែល ត្រូវក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់។<br>- ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា<br>- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលហុងគ្រី ស្តីពីការជំរុញ និងការពារគ្នាទៅវិញទៅមក នៃវិនិយោគ | សម័យប្រជុំ លើកទី៦ នីតិកាលទី៥ ថ្ងៃទី ៣០ ឧសភា ឆ្នាំ២០១៦ | ២៣៣ នាទី | ៦៨ សំឡេង | - មិនមានវត្តមានគណបក្សសង្គ្រោះជាតិចូលរួម<br>- ចំណាយពេលកិច្ចប្រជុំ១ សម្រាប់អនុម័តរបៀបវារៈទាំងអស់នេះ |
| ៦ | ការឆ្លើយបំភ្លឺដោយផ្ទាល់មាត់ជូនរដ្ឋសភារបស់ ឯកឧត្តមអង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សម័យប្រជុំ លើកទី៦ នីតិកាលទី៥ ថ្ងៃទី ០៩ មិថុនា ឆ្នាំ២០១៦ | ៧៤នាទី | | - សំណួរហាក់ដូចជាត្រូវបានរៀបចំទុក<br>- អ្នកតំណាងរាស្ត្រ២រូបឡើងសួរជាសំណួរដល់រដ្ឋមន្ត្រី |
| ៧ | - ច្បាប់ស្តីពី ការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើៈ<br>១) កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។<br>២) ពិធីសារទី១ ស្តីពីការមិនកំណត់សិទ្ធិហោះហើរ ទី៣ និងទី៤ រវាងចំណុចណាមួយនៅក្នុងទឹកដីបណ្តាភាគីចុះកិច្ចព្រមព្រៀង | សម័យប្រជុំរដ្ឋសភាពេញអង្គលើកទី៦ នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៦ | ១៦៥នាទី | ៦៥ សំឡេង | - របៀបវារៈទាំងអស់នេះ ត្រូវបានអនុម័តដោយមិនមានវត្តមានគណបក្សសង្គ្រោះជាតិ<br>- ត្រូវបានអនុម័ត ប្រើពេល១កិច្ចប្រជុំប៉ុណ្ណោះ<br>- អ្នកតំណាងរាស្ត្រមតិសរសើរ និងគាំទ្រខ្លឹមសារនៃច្បាប់<br>- មិនមានការពិភាក្សាលើកខ្លឹមសារច្បាប់ដោយគ្រាន់តែការកោតសរសើរ និងគាំទ្រសេចក្តីព្រាងច្បាប់ទាំងនេះ ចំពោះការបញ្ចេញមតិរបស់តំណាងរាស្ត្រ |

| | | | | | |
|---|---|---|---|---|---|
| | ៣) ពិធីសារទី២ ស្តីពីសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង។<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។ | | | | |
| ៨ | - ការបោះឆ្នោតទុកចិត្តអគ្គសវនករ និងអគ្គសវនកររង០៣ នៃអជ្ញាធរសវនកម្មជាតិ សម្រាប់បន្តអាណត្តិ៥ឆ្នាំ រួមមាន លោក ជំទាវសោម គឹមសួគ៌ ឯកឧត្តមសួនសិទ្ធី ឯកឧត្តម អ៊ុក សារាវុធ។<br>- ច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៧ស្តីពីប្រព័ន្ធឆ្លងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវា<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣<br>- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជាតែមួយអាស៊ាន | សម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៥ នៅថ្ងៃទី៧ តុលា ឆ្នាំ២០១៦ | ៣០០ នាទី | ៦៧ សំឡេង | - មិនមានវត្តមានគណបក្សសង្គ្រោះជាតិចូលរួមប្រជុំ<br>- ច្បាប់អនុម័តមានការប្រញាប់ប្រញាល់ត្រូវបានអនុម័ត ដោយប្រើពេល១កិច្ចប្រជុំប៉ុណ្ណោះ |

## ៣. សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភា

ខុមហ្វ្រែលសង្កេតឃើញថា សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍សង្កេតឆ្នាំទី២របស់ខុមហ្វ្រែល។ ក្នុងរយៈពេលនេះ គណៈកម្មការជំនាញនៃរដ្ឋសភាធ្វើសកម្មភាពសរុបចំនួន៦០លើក[1] ដែលក្នុងនោះគណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា មានសកម្មភាពច្រើនជាងគណៈកម្មការជំនាញដឹកនាំដោយគណបក្សសង្គ្រោះជាតិ។ គណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានសកម្មភាពចំនួន៣១លើក ចំណែកឯគណៈកម្មការជំនាញដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន២៩លើក។

សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាទាំងនោះរួមមានៈ ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ ការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ចឬ/និងប្រជាពលរដ្ឋ

[1] សកម្មភាពសង្កេតទាំងនេះ មិនរាប់បញ្ចូលនូវសកម្មភាពប្រជុំផ្ទៃក្នុង ឬប្រជុំលើសេចក្តីព្រាងច្បាប់ និងសកម្មភាពក្រៅប្រទេស ឬសកម្មភាពជួបភ្ញៀវឡើយ។

ដើម្បីពិនិត្យ និងស្វែងយល់ពីបញ្ហាកង្វល់នានាតាមមូលដ្ឋាន សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ ពិសេសបញ្ហាទំនាស់ដីធ្លី និងជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិផងដែរ។

### ៣.១ ដំណើរការនៃការប្រជុំ/សួរដេញដោលក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា

នៅក្នុងរយៈពេលនេះ មានរដ្ឋមន្រ្តីតែ ១រូបប៉ុណ្ណោះ ត្រូវបានកោះហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការនៃជំនាញរដ្ឋសភា។ នៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ បានចូលបំភ្លឺ ចំពោះមុខគណៈកម្មការជំនាញរដ្ឋសភា អំពីការអនុវត្តច្បាប់របស់តុលាការនាពេលបច្ចុប្បន្ន តាមលិខិតកោះអញ្ជើញរបស់គណៈកម្មការទី១នៃរដ្ឋសភា។ ករណីមួយចំនួនដែលទាក់ទងដល់ការអនុវត្តច្បាប់របស់តុលាការរួមមានៈ ការចាប់ ការឃុំខ្លួន និងការផ្តន្ទាទោសអនីតិជន ការឃុំខ្លួនលើសនីតិវិធី កំណត់កំហុសនៃការអនុវត្តនីតិវិធី និងការមិនអនុវត្តតួនាទីរបស់ចៅក្រម និងព្រះរាជអាជ្ញាជុំវិញករណីវិវាទដីធ្លី និងវិវាទផ្សេងទៀត និងឯករាជ្យភាពរបស់តុលាការ និងការជ្រៀតជ្រែកជាដើម ត្រូវបានលើកមកជជែកពិភាក្សា និងស្នើឲ្យមានការបំភ្លឺ។ មានការឆ្លើយតបជាវិជ្ជមានក្នុងកិច្ចពិភាក្សានោះ ដោយឯកឧត្តមរដ្ឋមន្រ្តីសន្យានឹងបញ្ជូនកង្វល់នៃរបាយការណ៍ដែលគណៈកម្មការជំនាញរដ្ឋសភាជូនទៅស្ថាប័នតុលាការដើម្បីពិនិត្យ និងធ្វើការសិក្សាលើអនុសាសន៍ទាំងអស់នេះ។ ចំណែកឯរឿងអនីតិជនវិញ ឯកឧត្តមរដ្ឋមន្រ្តីក្រសួងយុត្តិធម៌បញ្ជាក់ថា ក្រសួងយុត្តិធម៌មានកិច្ចការជាច្រើនបានកំពុងបំពេញ និងស្ថិតនៅក្នុងផែនការ ដើម្បីលើកកម្ពស់វិស័យយុត្តិធម៌សម្រាប់យុវជននេះ ដោយនៅពេលនេះ ក្រសួងកំពុងតាក់តែងច្បាប់មួយស្តីពីយុត្តិធម៌អនីតិជន។ ច្បាប់យុត្តិធម៌អនីតិជននេះមានសារៈសំខាន់ណាស់ក្នុងការការពារសិទ្ធិកុមារ ហើយដើម្បីឲ្យដំណើរការនៃការប្រព្រឹត្តទៅរបស់តុលាការឲ្យដំណើរបានរលូន យន្តការមួយ គឺការដាក់ឲ្យមានរដ្ឋបាលសម្រាប់តុលាការដែលគ្រោងនឹងរៀបចំឡើងក្នុងពេលអនាគតនេះដែរ។ ចំពោះការចាប់ខ្លួនវិញ ឯកឧត្តមរដ្ឋមន្រ្តី និងសហការី បានគូសបញ្ជាក់ថា ចាប់ពីពេលនេះទៅក្រសួងយុត្តិធម៌នឹងខិតខំជំរុញដល់តុលាការមិនឲ្យមានការឃុំខ្លួនលើប្រជាជលរដ្ឋក្នុងករណីទំនាស់ដីធ្លីជាសមូហភាពទៀតនោះទេ។

### ៣.២ ការចុះបេសកកម្មគណៈកម្មការជំនាញនៃរដ្ឋសភា

ក្នុងរយៈពេលនេះ ខុមហ្វ្រែលសង្កេតឃើញថា គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភាបានចុះបេសកកម្មតាមបណ្តាស្ថាប័ន ឬមន្ទីរក្នុងរាជធានី/ខេត្ត ដោយផ្តោតសំខាន់ទៅលើ ទី១.ការតាមដានត្រួតពិនិត្យ និងសិក្សាស្វែងយល់ការអនុវត្តការងាររបស់មន្ទីរនានា ដែលស្ថិតនៅក្រោមវិស័យទទួលខុសត្រូវរបស់គណៈកម្មការជំនាញនីមួយៗ ទី២. បញ្ហាប្រឈមនានាដែលមន្ទីរជំនាញជួបប្រទះក្នុងដែនកិច្ចការទទួលបន្ទុកនៃគណៈកម្មការ និងទី៣.ការចុះជួបសំណេះសំណាលប្រជាពលរដ្ឋដោយផ្ទាល់។




ការធ្វើសកម្មភាព/បេសកកម្មរបស់គណៈកម្មការជំនាញនៃរដ្ឋសភា តាមវិស័យទទួលបន្ទុកនីមួយៗ មានការថយចុះជាង រយៈពេលសង្កេតដូចគ្នានេះក្នុងឆ្នាំ២០១៥។ គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភា បានធ្វើសកម្មភាពសរុបចំនួន៦០សកម្មភាព ខណៈដែលក្នុងឆ្នាំ២០១៥ គណៈកម្មការជំនាញទាំង១០នៃ

រដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន១០៥សកម្មភាព។

ខុមហ្វ្រែលសង្កេតឃើញថា ការថយនៃចំនួនការចុះធ្វើសកម្មភាពនេះអាចបណ្តាលមកពីរដ្ឋសភាជាតិកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះក្នុងការបើកកិច្ចប្រជុំសភាអាស៊ី (APA) និងការកើនឡើងនៃកម្តៅនយោបាយដោយមានការខ្វែងគំនិតគ្នារវាងគណបក្សទាំងពីរនៅពាក់កណ្តាលឆ្នាំ២០១៦ ដែលបណ្តាលឲ្យមានការធ្វើពហិការមិនចូលបំពេញការងាររដ្ឋសភាពីគណបក្សសង្គ្រោះជាតិរយៈពេលជិត៣ខែ។

គណៈកម្មការជំនាញនៃរដ្ឋសភា បានធ្វើសកម្មភាពការងារតាមវិស័យទទួលបន្ទុកខ្លួនមានចំនួន៦០សកម្មភាព។ ក្នុងនោះគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានសកម្មភាពចំនួន៣១ ចំណែកឯគណៈកម្មការជំនាញដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន២៩សកម្មភាព។ ក្នុងចំណោមសកម្មភាពទាំងនោះ គណៈកម្មការជំនាញទី១ មានសកម្មភាពចំនួន០៨លើក គណៈកម្មការជំនាញទី២ មានសកម្មភាពចំនួន០៨លើក គណៈកម្មការជំនាញទី៣ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៤ មានសកម្មភាពចំនួន០៥លើក គណៈកម្មការជំនាញទី៥ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៦ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៧ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៨ មានសកម្មភាពចំនួន០៨លើក គណៈកម្មការជំនាញទី៩ មានសកម្មភាពចំនួន០៦លើក និងគណៈកម្មការជំនាញទី១០ មានសកម្មភាពចំនួន០១លើក។

*ខាងក្រោមនេះជាព័ត៌មានសង្ខេបស្តីពីសកម្មភាពបេសកម្មរបស់គណៈកម្មការជំនាញនៃរដ្ឋសភាក្នុងការបំពេញបេសកម្មតាមវិស័យជំនាញនៃការទទួលខុសត្រូវ៖*

**គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា (គណៈកម្មការទី១)** មានសកម្មភាពចំនួន ០៨សកម្មភាពរួមមាន៖ សកម្មភាពទទួលពាក្យបណ្តឹង សកម្មភាពចុះធ្វើពិនិត្យដល់ទំនាស់ដីធ្លីផ្ទាល់, ជួបប្រជុំជាមួយតំណាងរាស្ត្រសង្គមស៊ីវិល និងការទទួលទស្សនកិច្ចសិក្សារបស់ក្រុមនិស្សិតមកពីសាកលវិទ្យាល័យនៅខេត្តបាត់ដំបង។

គណៈកម្មការទី១នៃរដ្ឋសភា បានជួបពិភាក្សាការងារជាមួយតំណាងអង្គការសង្គមស៊ីវិល និងអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ នៅរសៀលថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការបានជួបពិភាក្សាការងារជាមួយតំណាងអង្គការសង្គមស៊ីវិលមួយចំនួនដឹកនាំដោយលោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) ពិភាក្សាជុំវិញប្រធានបទទាក់ទងនឹងបញ្ហាទំនាស់ដីធ្លី បញ្ហាធនធានធម្មជាតិ និងសិទ្ធិមនុស្សជាដើម នៅវិមានរដ្ឋសភា។ ជាមួយគ្នានេះដែរ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការបានជួបពិភាក្សាការងារជាមួយលោកស្រី រ៉ូណា ស្ម៊ីត អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាដើម្បីបង្ហាញពីនីតិវិធីដាក់ពាក្យបណ្តឹង ប្រភេទនៃពាក្យបណ្តឹង និងកិច្ចអន្តរាគមន៍របស់គណៈកម្មការទី១នៅរដ្ឋសភា។

ចំណែកឯសកម្មភាពអន្តរាគមន៍រឿងដីធ្លីវិញ គណៈកម្មការជំនាញទី១ បានដឹកនាំគណៈប្រតិភូចុះបំពេញបេសកកម្មសិក្សាស្វែងយល់ពីបញ្ហាទំនាស់ដីធ្លី និងជួបដោយផ្ទាល់ជាមួយគ្រួសាររងគ្រោះក្នុងទំនាស់ដីធ្លីផងដែរ។ តួយ៉ាង នៅរសៀលថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ គណៈកម្មការទី១នៃរដ្ឋសភា បានជួបពិភាក្សាជាមួយប្រជាពលរដ្ឋចំនួន១៦គ្រួសាររស់នៅភូមិឡពាង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនKDC នៅវិមានរដ្ឋសភា។ ជំនួបនោះធ្វើឡើងដើម្បីចង់ដឹងពីគោលជំហរ និងបំណងរបស់ប្រជាពលរដ្ឋក្នុងការដោះស្រាយជាមួយក្រុមហ៊ុនដែលឈានទៅរកវិធីសាស្ត្រធ្វើការសម្របសម្រួលរកដំណោះស្រាយសម្រាប់ភាគីទាំងពីរ។ គណៈកម្មការបានបញ្ជាក់ជំហរថា ប្រសិនបើការដោះស្រាយដោយយន្តការសភាមិនទទួលបានជោគជ័យទេនោះ រដ្ឋសភានឹងបញ្ជូនសំណុំឯកសារទាំងអស់នេះទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបន្តជួយដោះស្រាយជូនប្រជាពលរដ្ឋ។

ជាងនេះទៅទៀត រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការទី១ បានចុះបំពេញបេសកកម្មក្នុងខេត្តបាត់ដំបងដើម្បីសិក្សាស្វែងយល់ពីករណីទំនាស់ដីធ្លីនានាក្នុងខេត្ត និងធ្វើការអង្កេតស្រាវជ្រាវ ប្រមូលព័ត៌មានពីភាគីពាក់ព័ន្ធ និងព្រមទាំងស្តាប់ការបំភ្លឺពីអាជ្ញាធរខេត្តពីការដោះស្រាយករណីទំនាស់ដីធ្លីកើតមាននៅក្នុងខេត្ត ដូចជាបញ្ហាទំនាស់ដីធ្លីក្នុងឃុំបឹងប្រាំ និងតំបន់ផ្សេងៗទៀតជាដើម។

អាជ្ញាធរខេត្តបាត់ដំបងបានរាយការណ៍ជូនគណៈប្រតិភូនៃគណៈកម្មការជំនាញអំពីបញ្ហាទំនាស់ដីធ្លីដែលកើតមានក្នុងខេត្តសរុបចំនួន៤២០ករណី ដែលក្នុងនោះអាជ្ញាធរខេត្តបានធ្វើការដោះស្រាយចប់សព្វគ្រប់បានចំនួន១៧៩ករណី ច្រានចោលចំនួន១១១ករណី ដកពាក្យបណ្តឹងចំនួន៤០ករណី បញ្ជូនទៅថ្នាក់ជាតិជួយដោះស្រាយចំនួន៥០ករណី និងកំពុងបន្តដោះស្រាយចំនួន៤០ករណី។ ករណីទំនាស់នេះ គឺមិនទាន់គិតទំនាស់ស្ថិតនៅក្នុងគម្រោងចុះបញ្ជីជាប្រព័ន្ធ និងបទបញ្ជាលេខ០១របស់រាជរដ្ឋាភិបាលនោះទេ។

**គណៈកម្មការគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា(គណៈកម្មការទី២)** មានសកម្មភាពចំនួន ០៨ សកម្មភាពរួមមាន៖ ការចុះសិក្សាស្វែងយល់ពីការប្រតិបត្តិប្រមូលចំណូលថវិកាជាតិ និងបញ្ហាប្រឈមនានា ការចូលរួមសិក្ខាសាលា និងការសួរសុខទុក្ខប្រជាពលរដ្ឋ។

ជាក់ស្តែងឯកឧត្តមជាម យៀប ដែលជាប្រធាន និងមានការចូលរួមពីឯកឧត្តម ស្នួង ម៉េងគាំ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ បានចុះសិក្សាស្វែងយល់ពីការប្រតិបត្តិការប្រមូលចំណូលថវិកាជាតិរបស់ខេត្តព្រះសីហនុ។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការទី២ និងមានការចូលរួមពី ឯកឧត្តម ស ថេង អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ បានចុះបំពេញបេសកកម្មសិក្សាស្វែងយល់ពីប្រតិបត្តិការប្រមូលចំណូលថវិកាជាតិ និងបញ្ហាប្រឈមរបស់ខេត្តស្វាយរៀង។ នៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការទី២ រួមជាមួយឯកឧត្តម វង់ សណ្តាប់ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ បានចុះសិក្សាស្វែងយល់ពីកិច្ចប្រតិបត្តិការប្រមូលចំណូលថវិកាជាតិនៅខេត្តបន្ទាយមានជ័យ។

**គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹកនៃរដ្ឋសភា (គណកម្មការទី៣)** មានសកម្មភាពចំនួន០៦សកម្មភាពរួមមាន៖ ការចុះជួបពិភាក្សាជាមួយអាជ្ញាធរមន្ត្រីមូលដ្ឋាន ការចុះស្វែងយល់នៅតំបន់សេដ្ឋកិច្ចពិសេស ការជួបពិភាក្សារឿងអភិវឌ្ឍន៍ជនបទ ការការពារបរិស្ថាន និងធនធានធម្មជាតិជាមួយអាជ្ញាធរខេត្តនៅបណ្តាភាគឥសាននៃប្រទេសកម្ពុជា។

ជាក់ស្តែងប្រតិភូមគណៈកម្មការជំនាញទី៣ ដឹកនាំដោយឯកឧត្តម ប៉ុល ហំម កាលថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ បានដឹកនាំសមាជិក សមាជិកាចុះសិក្សាស្វែងយល់ការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញដោយមាន ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អមដំណើរនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ គណៈកម្មការជំនាញដដែលនេះ បានចុះបំពេញបេសកកម្មសិក្សាស្វែងយល់វិស័យការងារដែលទាក់ទងនឹងការទទួលខុសត្រូវរបស់គណៈកម្មការនៅក្នុងខេត្តប៉ៃលិន។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៣នៃរដ្ឋសភា បានចុះបេសកកម្មនៅខេត្តរតនៈគីរីដើម្បីស្វែងយល់វិស័យពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការពិសេសបញ្ហាកសិកម្ម បរិស្ថាន និងការអភិវឌ្ឍន៍ជនបទ។

បន្ទាប់ពីបេសកកម្មនៅខេត្តរតនៈគីរីរួចមក នៅថ្ងៃទី១៧ និង១៨ ខែសីហា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៣ បានបន្តចុះបេសកម្មជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តមណ្ឌលគីរី និងក្រចេះជុំវិញលទ្ធផលនៃការសម្រេចការងារ និង

បញ្ហាប្រឈមរបស់ខេត្តទាំងពីរទាក់ទងនឹងវិស័យការងារទទួលបន្ទុករបស់គណៈកម្មការ ពិសេសស្តីពីកិច្ចការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិនៅក្នុងខេត្ត។

**គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា (គណកម្មការទី៤)** មានសកម្មភាពចំនួន០៥សកម្មភាពរួមមាន៖ ធ្វើការស្វែងយល់ និងពិនិត្យការអនុវត្តការងាររបស់អាជ្ញាធរក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ការចុះពិនិត្យ និងសិក្សាការងារសន្តិសុខជាដើម។

កាលពីអំឡុងពេលពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៤នៃរដ្ឋសភាដឹកនាំដោយ ឯកឧត្តម ហ៊ុន ណេង បានចុះបំពេញបេសកកម្មនៅតាមបណ្តាខេត្តភាគខាងលិចនៃប្រទេសរួមមានៈ ខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីជួបពិភាក្សា និងស្វែងយល់អំពីការងារមួយចំនួនជាមួយអាជ្ញាធរខេត្ត ក៏ដូចជាមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ។ ប្រធានបទនៃការពិភាក្សារួមមាន សុខទុក្ខរបស់ប្រជាពលរដ្ឋ កិច្ចការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខនៅតាមព្រំដែន បញ្ហាចំណាកស្រុក ការគ្រប់គ្រងជនអន្តោប្រវេសន៍ ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការអនុវត្តន៍កិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ការផ្តល់សេវាសាធារណៈ និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ ព្រមទាំងបញ្ហាផ្សេងៗទៀតទាក់ទងនឹងការរីកចម្រើន និងបញ្ហាប្រឈមដែលខេត្តបានជួបប្រទះនាពេលកន្លងមក។

នៅថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៤នៃរដ្ឋសភា បានចុះបេសកកម្មនៅខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុងដើម្បីស្វែងយល់ពីផលប៉ះពាល់ និងបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ កិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព កិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិព្រមទាំងសេចក្តីណែនាំ ឬលិខិតបទដ្ឋានថ្មីៗលើការអនុវត្តវេទិកាសាធារណៈ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាចំណាកស្រុក ពីស្ថានភាពសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពក្នុងមូលដ្ឋានខេត្ត និងការគ្រប់គ្រងជនអន្តោប្រវេសន៍ជាដើម។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៤ បានបន្តចុះបេសកកម្មនៅខេត្តស្វាយរៀង និងខេត្តព្រៃវែងដើម្បីពិនិត្យមើលការផ្តល់សេវាសាធារណៈនានាដល់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរខេត្តទាំងពីរ។

**គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភាសភា (គណៈកម្មការទី៥)** មានសកម្មភាពចំនួន០៦សកម្មភាពរួមមាន៖ ការផ្សព្វផ្សាយតួនាទីរដ្ឋសភាដល់និស្សិត និងការជួបពិភាក្សាការងារជាមួយមន្ត្រីទូតជុំវិញការពង្រឹងការពង្រីកចំណងមិត្តភាពជាដើម។

ជាក់ស្តែង នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម ឈាង វុនបានចូលរួមជាអធិបតី និងបានធ្វើបទបង្ហាញពីតួនាទី និងដំណើរការរបស់រដ្ឋសភាដល់និស្សិតនៅសាកលវិទ្យាល័យបាត់ដំបង ដែលមាននិស្សិតចូលរួមប្រមាណជាង៤០០នាក់។

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៥នៃរដ្ឋសភាដឹកនាំដោយឯកឧត្តម ឈាង វុន បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងស្ថាប័នសំខាន់ៗរបស់ប្រទេសថៃដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងដើម្បីស្វែងរកកិច្ចអន្តរាគមន៍ពីអាជ្ញាធរប្រទេសថៃ ដើម្បីជួយការពារតាមផ្លូវច្បាប់ដល់ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ។

**គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា (គណៈកម្មការទី៦)** មានសកម្មភាពចំនួន០៦សកម្មភាពរួមមាន៖ ការជួបសំណេះសំណាលជាមួយមន្ត្រីរាជការ ការជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងការផ្សព្វផ្សាយច្បាប់ដែលរដ្ឋសភាបានអនុម័ត។

គណៈកម្មការជំនាញទី៦នៃរដ្ឋសភា បានជួបសំណេះសំណាលដាច់ដោយឡែកជាមួយសិស្សទាហាន និងកងរាជអាវុធហត្ថដែលបានមកធ្វើការសិក្សាស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់រដ្ឋសភានៅវិមានរដ្ឋសភា។

កាលពីថ្ងៃទី២៩ ខែកុម្ភៈដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៦នៃរដ្ឋសភា ដឹកនាំដោយឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា បានចុះបំពេញបេសកកម្មនៅតាមខេត្តស្ថិតក្នុងភូមិភាគពាយព្យប្រទេសរួមមាន ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ដើម្បីសិក្សាស្វែងយល់ពីការអនុវត្តច្បាប់លើកិច្ចការពាក់ព័ន្ធវិស័យទទួលខុសត្រូវរបស់គណៈកម្មការ ពិសេសវិស័យយុត្តិធម៌។

នៅថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៦នៃរដ្ឋសភាបានចុះបេសកកម្មការងារនៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ដើម្បីសិក្សាស្វែងយល់ពីវិស័យការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការ។

**គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនាវប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា (គណៈកម្មការទី៧)**មានសកម្មភាពចំនួន០៦សកម្មភាពដែលរួមមានដូចជាៈ

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ប្រតិភូគណៈកម្មការជំនាញទី៧នៃរដ្ឋសភា ដឹកនាំដោយ ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ បានចុះបេសកកម្មបំពេញការងារនៅខេត្តកំពង់ចាម ដើម្បីសិក្សាស្វែងយល់ពីវិស័យនានាដែលទាក់ទងពីការទទួលខុសត្រូវរបស់គណៈកម្មការ ពិសេសវិស័យអប់រំ។ នៅក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូបានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការជុំវិញខេត្ត និងបានអញ្ជើញទៅសិក្សាស្វែងយល់ដោយផ្ទាល់នៅសាលាវិក្រឹតការខេត្ត និងវិទ្យាល័យហ៊ុនសែនកំពង់ចាម។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ នៅវិមានរដ្ឋសភា គណៈកម្មការទី៧ បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយតំណាងយុវជននៃអង្គការសភាយុវជនខ្មែរមានចំនួន៧០រូប ដែលមកធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់រដ្ឋសភា។ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការដដែលបានចុះបំពេញបេសកកម្មនៅខេត្តពោធិ៍សាត់ ដើម្បីសិក្សាស្វែងយល់ពីការងារមួយចំនួនទាក់ទងនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ។ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការបានបន្តជួបភិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តបាត់ដំបងដើម្បីសិក្សាស្វែងយល់ពីការងារលើវិស័យដែលគណៈកម្មការទទួលខុសត្រូវ និងចុះទស្សនកិច្ច និងត្រួតពិនិត្យមើលនៅទីកន្លែងសំខាន់នានាដូចជា រមណីយដ្ឋានប្រាសាទឯកភ្នំ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគបាត់ដំបងជាដើម។

**គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃរដ្ឋសភា (គណៈកម្មការទី៨)** មានសកម្មភាពចំនួន០៨សកម្មភាពរួមមាន៖ សកម្មភាពចុះស្វែងសិក្សាយល់ការងារ និងពិភាក្សាការងារជាមួយមន្ត្រីពាក់ពន្ធធ្វើការលើវិស័យទទួកបន្ទុកក្នុងបណ្តាខេត្តមួយចំនួន និងសកម្មភាពជួបពិភាក្សាការងារជាមួយអង្គការសង្គមស៊ីវិល លើបញ្ហាប្រឈមទាក់ទងនឹងវិស័យទទួលបន្ទុក។

ជាក់ស្តែង នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ប្រតិភូរបស់គណៈកម្មការបានចុះបំពេញបេសកកម្មនៅខេត្តព្រះសីហនុ ដើម្បីជួបសំណេះសំណាលជាមួយអាជ្ញាធរខេត្តអំពីការត្រួតពិនិត្យការលក់ឱសថនៅតាមគ្លីនីកឯកជន និងតាមដានត្រួតពិនិត្យ

ការអនុវត្តច្បាប់របស់មន្ទីរជំនាញនានាដែលស្ថិតនៅក្រោមវិស័យទទួលខុសត្រូវរបស់គណៈកម្មការ និងចង់ដឹងពីបញ្ហាប្រឈមនានាដែលមន្ទីរជំនាញបានជួបប្រទះ។

លោកជំទាវ កែ សុវណ្ណរតន៍ បានដឹកនាំប្រតិភូចុះទៅសិក្សាស្វែងយល់ការងារមួយចំនួន ពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការនៅខេត្តចំនួនបួនគឺ ខេត្តមណ្ឌលគិរី ខេត្តរតនៈគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦។ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការទី០៨ និងសមាជិកគណៈកម្មការជំនាញមួយចំនួនទៀត បានជួបពិភាក្សាការងារជាមួយលោក ស្ទេសហ្វ ផ្លេមម៉ា(Steffer Flema ) តំណាងអង្គការGIZ ដើម្បីពិនិត្យសិក្សាធ្វើយ៉ាងណាជួយជំរុញសកម្មភាពមូលនិធិសមធម៌ឲ្យកាន់តែទូលំទូលាយ ជួយប្រជាពលរដ្ឋឲ្យទទួលបានសេវាសុខភាពកាន់តែច្រើនឡើង។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ គណៈកម្មការបានចុះបំពេញបេសកកម្មនៅខេត្តកំពង់ស្ពឺ ដើម្បីស្វែងយល់វិស័យការងារមួយចំនួនដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ដូចជាវិស័យសុខាភិបាល សង្គមកិច្ចជាដើម និងបានចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺផងដែរ។ បន្ទាប់ពីបញ្ចប់បេសកកម្មនៅខេត្តកំពង់ស្ពឺ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ គណៈកម្មការទី៨ បានជួបពិភាក្សាការងារជាមួយមន្ត្រីអាជ្ញាធរខេត្តអំពីការយកចិត្តទុកដាក់ត្រួតពិនិត្យការលក់ឱសថនៅតាមគ្លីនិកឯកជន និងតាមដានត្រួតពិនិត្យលើការអនុវត្តច្បាប់របស់មន្ទីរជំនាញនានាដែលស្ថិតក្រោមវិស័យទទួលខុសត្រូវរបស់គណៈកម្មការ និងបញ្ហាប្រឈមនានាដែលមន្ទីរជំនាញបានជួបប្រទះនាពេលកន្លងមក។

**គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃរដ្ឋសភា (គណៈកម្មការទី០៩)** មានសកម្មភាពចំនួន០៦សកម្មភាពដែលរួមមានៈ ចុះសិក្សាស្វែងយល់ពីការរីកចម្រើន និងបញ្ហាប្រឈមរបស់បណ្តាខេត្តភាគឦសាននៃប្រទេស និងស្វែងយល់ពីវិស័យការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការនៅខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង។

ជាក់ស្តែង នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈប្រតិភូគណៈកម្មការទី៩នៃរដ្ឋសភា អមដំណើរដោយឯកឧត្តម ចាន់ តារា អគ្គនាយកក្រសួងសាធារណការ និងដឹកជញ្ជូន បានអញ្ជើញចុះសិក្សាស្វែងយល់ពីការអនុវត្តតួនាទីភារកិច្ច របស់អាជ្ញាធរខេត្តរតនៈគីរីដែលរួមបញ្ចូលមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការអំពីសមិទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈមទិសដៅភារកិច្ចដែលត្រូវអនុវត្តន៍បន្ត ប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់នានាដែលរដ្ឋសភាបានអនុម័តនាពេលកន្លងមក ពិសេសគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការរបស់រាជរដ្ឋាភិបាលថាតើបានប្រព្រឹត្តទៅមានភាពងាយស្រួលឬជួបឧបសគ្គ អ្វីខ្លះក្នុងខេត្ត។

ដោយឡែក នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈប្រតិភូគណៈកម្មការទី៩នៃរដ្ឋសភា អមដំណើរដោយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានអញ្ជើញចុះពិនិត្យជាក់ស្តែង នៅការដ្ឋានអណ្តូងរ៉ែមាសរបស់ក្រុមហ៊ុន មេស្កូហ្គោល Mesco Gold ជាក្រុមហ៊ុនដែលបានសុំអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាលក្នុងការធ្វើអាជីវកម្មរ៉ែមាសនៅភូមិពាក់ ឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ ខេត្តរតនគីរី។

នៅក្នុងដំណើរបំពេញបេសកកម្មតាមបណ្តាខេត្តភាគឦសាននៃប្រទេស គណៈប្រតិភូរបស់គណៈកម្មការ រួមដំណើរដោយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលបានបន្តដំណើរមកកាន់ខេត្តស្ទឹងត្រែង ដើម្បីចុះពិនិត្យមើលជាក់ស្តែងនៅទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២ និងសិក្សាស្វែងយល់ពីការអភិវឌ្ឍន៍ និងបញ្ហាប្រឈមរបស់ខេត្តនេះ នៅព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។

គណៈប្រតិភូគណៈកម្មការទី៩ បានចុះបំពេញបេសកកម្មការងារនៅខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ពីថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦នេះ ដើម្បីសិក្សាស្វែងយល់ពីវិស័យការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ច ទទួលខុសត្រូវរបស់គណៈកម្មការ។

**គណៈកម្មការ អង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយនៃរដ្ឋសភា (គណៈកម្មការទី១០)** មានសកម្មភាពចំនួន០១សកម្មភាព។ កាលពីព្រឹកថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម អាយ ខន ប្រធានស្តីពីគណៈកម្មការ បានដឹកនាំសមាជិកចុះសិក្សាស្វែងយល់ពីវឌ្ឍនភាពនៃការទប់ស្កាត់ការប្រឆាំងអំពើពុករលួយ និងការអនុវត្តកម្មវិធីកំណែទម្រង់នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងជំនួបនោះ ក៏ជជែកអំពីការទប់ស្កាត់អំពើពុករលួយ និងការកៀងគរប្រមូលថវិកា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិផងដែរ។

## ៤. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តំណាងរាស្ត្រដែលជាប់ឆ្នោត ដោយការបោះឆ្នោតជ្រើសតាំងពីប្រជាពលរដ្ឋ ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងរាស្ត្រប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។[2] តំណាងរាស្ត្រមានតួនាទីក្នុងការប្រជុំអនុម័តច្បាប់ផ្សេងៗ តាមដានការអនុវត្តច្បាប់របស់រដ្ឋាភិបាល និងទទួលពាក្យបណ្តឹង/សំណូមពរ លើបញ្ហាវិវាទនានារវាងប្រជាពលរដ្ឋ និងឈ្មួញ/អ្នកមានអំណាចដើម្បីអន្តរាគមន៍ទៅរដ្ឋាភិបាលដើម្បីរកដំណោះស្រាយ។ រដ្ឋសភាបើកប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ។[3] ក្នុងចន្លោះសម័យប្រជុំ ជារយៈពេលវិស្សមកាលរបស់តំណាងរាស្ត្រ តំណាងរាស្ត្របានយកពេលនេះសម្រាប់ចុះធ្វើសកម្មភាពចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល ទទួលព័ត៌មាន/សំណូមពរ និងដោះស្រាយបញ្ហានានារបស់ដែលប្រជាពលរដ្ឋជួបប្រទះ។




តាមទិន្នន័យដែលខុមហ្វ្រែលទទួលបានអំពីសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមរយៈការសង្កេតផ្ទាល់នៃពីបណ្តាញខុមហ្វ្រែល ពីប្រព័ន្ធផ្សព្វផ្សាយ ពីបណ្តាញសង្គម ពីការិយាល័យតំណាងរាស្ត្រតាមរាជធានី ខេត្ត ពីស្នាក់ការគណបក្សនយោបាយ និងពីរដ្ឋសភាឃើញថា នៅក្នុងរយៈពេលនេះ មានតំណាងរាស្ត្រចំនួន១០២រូប ចុះធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន១៨០១លើក។ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី២ (ឆ្នាំ២០១៥) ចំនួនតំណាងរាស្ត្រ និងចំនួនសកម្មភាព មានការកើនឡើង ដោយក្នុងរយៈពេលនោះ ខុមហ្វ្រែលរកឃើញថា មានតំណាងរាស្ត្រតែ ៩១រូប ប៉ុណ្ណោះ បានធ្វើសកម្មភាពនៅមូលដ្ឋានចំនួន១០០៤លើក។

ការកើនឡើងនៃចំនួនតំណាងរាស្ត្រ និងចំនួនសកម្មភាពចុះមូលដ្ឋានក្នុងឆ្នាំនេះ គឺអាចបណ្តាលមកពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ បានខិតជិតមកដល់ ហើយចំណុចមួយទៀតការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់តំណាងរាស្ត្រមានភាពទូលំទូលាយជាងរយៈពេលកន្លងមក

[2] មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[3] ប្រការ ១ នៃបញ្ញាផ្ទៃក្នុងរដ្ឋសភា

ដែលបានបង្កលក្ខណៈងាយស្រួលក្នុងការប្រមូលព័ត៌មាន ពិសេសតាមរយៈបណ្ដាញសង្គម (Facebook) និងប្រព័ន្ធផ្សព្វផ្សាយនានា ។

## ៤.១ ចំនួនអ្នកតំណាងរាស្ត្រ និងចំនួនដងនៃការចុះមូលដ្ឋាន

ក្នុងរបាយការណ៍ប្រចាំឆ្នាំលើទី៣នៃនីតិកាលទី៥នេះ ខុមហ្វ្រែលសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន១០២រូប នៃតំណាងរាស្ត្រសរុបចំនួន១២៣រូប បានធ្វើសកម្មភាពចុះមូលដ្ឋានសរុបចំនួន១៨០១លើក។ បើធៀបនឹងការអង្កេតរយៈពេលដូចគ្នាក្នុងឆ្នាំទី២វិញឃើញថា ឆ្នាំទី៣នេះចំនួននៃអ្នកតំណាងរាស្ត្រចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងចំនួនសកម្មភាព មានការកើនឡើងជាងឆ្នាំទី២ ដោយក្នុងរយៈពេលនោះមានតំណាងរាស្ត្រតែចំនួន៩១រូបបានចុះមូលដ្ឋាន និងធ្វើសកម្មភាពចំនួន១០០៤លើកប៉ុណ្ណោះ។

*ក្រាភិច៣៖ ចំនួនតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងចុះមូលដ្ឋានសរុប*

ខុមហ្វ្រែលសង្កេតឃើញថា ចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះមូលដ្ឋានច្រើនជាងចំនួនតំណាងរាស្ត្រតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ ពោលគឺគណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្រចំនួន៥៦រូប ស្មើនឹង ៥៥% នៃចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប។ រីឯគណបក្សសង្គ្រោះជាតិមានតំណាងរាស្ត្រចំនួន៤៦រូបស្មើនឹង៤៥%នៃចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប។




*ក្រាភិច៤៖ ភាគរយនៃអាសនៈរដ្ឋសភា និងភាគរយនៃអ្នកតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងតំណាងរាស្ត្រចុះមូលដ្ឋានសរុប*




ក្រាភិចនេះបង្ហាញពីចំនួន អសនៈក្នុងរដ្ឋសភាធៀបនឹងការចុះមូលដ្ឋាននៃគណបក្សទាំងពីរគិតជាភាគរយ។ គណបក្សប្រជាជនកម្ពុជាមាន៦៨អាសនៈ ស្មើនឹង៥៥% នៃចំនួនអាសនៈសរុបក្នុងរដ្ឋសភា មានតំណារាស្ត្រ៥៦រូប ស្មើនឹង៥៥% នៃចំនួនតំណាងរាស្ត្របានចុះមូលដ្ឋានសរុបចំនួន១០២រូប។ រីឯគណបក្សសង្គ្រោះជាតិមាន៥៥អាសនៈ ស្មើនឹង៤៥% នៃចំនួនអាសនៈសរុបក្នុងរដ្ឋសភា មានតំណាងរាស្ត្រ ៤៦រូប ស្មើនឹង ៤៥% នៃតំណាងរាស្ត្រចុះមូលដ្ឋានសរុបចំនួន១០២រូប ។

***ក្រាភិច៥៖ ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន***




ក្រាភិចនេះ បង្ហាញពីតំណាងរាស្ត្រចុះមូលដ្ឋាន ធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្ស (គិតជាភាគរយ)។ ការសង្កេត ឃើញថា គណបក្សប្រជាជនកម្ពុជា មានតំណាងរាស្ត្រកើនឡើង ក្នុងការចុះបំពេញបេសកកម្មតាមមូលដ្ឋានចំនួន៥៦រូប ស្មើនឹង ៨២% នៃចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្ស ខណៈតំណាងរាស្ត្រចំនួន១២រូប ទៀតស្មើនឹង ១៨%នៃចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្ស ខុមប្រែ្វលមិនបានទទួលពីសកម្មភាពចុះមូលដ្ឋាននោះទេ។

ចំណែកឯការចុះបំពេញបេសកម្មរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិវិញ ក្នុងរយៈពេលនេះមានការថយចុះដោយមានតំណាងរាស្ត្រ៤៦រូប ស្មើនឹង៨៤% នៃចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សបានចុះបំពេញបេសកកម្ម ខណៈតំណាងរាស្ត្រចំនួន០៩រូប ស្មើនឹង ១៦% នៃចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្ស ខុមប្រែ្វលមិនទទួលបានព័ត៌មានពីការចុះមូលដ្ឋាននោះទេ។

***ក្រាភិច៦៖ ចំនួនតំណាងរាស្ត្រចុះមូលដ្ឋាន និងចំនួនសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុបតាមគណបក្ស***




ក្រាភិចនេះបង្ហាញពីចំនួនតំណាងរាស្ត្រចុះមូលដ្ឋាន និងសកម្មភាពមូលដ្ឋានសរុបនៃគណបក្សមានអាសនៈក្នុងរដ្ឋសភា។ ខុមប្រែ្វលសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជា មានចំនួនតំណាងរាស្ត្រចុះធ្វើសកម្មភាពក្នុងមូលដ្ឋានច្រើនជាង ចំនួនតំណាងរាស្ត្រចុះមូលដ្ឋានពីគណបក្សសង្គ្រោះជាតិ។ ប៉ុន្តែបើសង្កេតពីចំនួនសកម្មភាពមូលដ្ឋានវិញឃើញថា តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ មានចំនួនសកម្មភាពនៅមូលដ្ឋានច្រើនជាង តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។

ការសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្រចំនួន៥៦រូប ធ្វើសកម្មភាពចំនួន៦១៧លើក រីឯគណបក្សសង្គ្រោះជាតិមានតំណាងរាស្ត្រចំនួន៤៦រូបធ្វើសកម្មភាពចំនួន ១១៨៤លើក។

ខុមប្រែ្វលសង្កេតឃើញថា កត្តាដែលអាចនាំឲ្យសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិច្រើនជាងសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា គឺដោយសារតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមិនសូវមានការងារចំពោះកិច្ចនៅក្នុងរដ្ឋសភា ក៏ដូចជាក្នុងរដ្ឋាភិបាល។ មួយវិញទៀត តំណាងរាស្ត្រពីគណបក្សនេះបានធ្វើពហិការមិនចូលកិច្ចប្រជុំមួយចំនួនដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋាន។ ចំណែកឯតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាវិញ គឺមានការងារចំពោះកិច្ចច្រើននៅរដ្ឋសភា ហើយការមិនសូវចុះមូលដ្ឋានធ្វើសកម្មភាព ព្រោះយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះបានធ្វើសកម្មភាពច្រើនហើយ។

*តារាងទី៤៖ សកម្មភាពរបស់អ្នកតំណាងរាស្ត្រចុះមូលដ្ឋានច្រើនជាងគេ១០រូប*

| ល.រ | គោត្តនាម និងនាម | គណ | សរុប (គិ | គោលបំណងនៃសកម្មភាពចុះមូលដ្ឋាន (គិតជាលើក) | | | | |
|---|---|---|---|---|---|---|---|---|
| | | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងគណបក្ស | វេទិកា | អមដំណើរថ្នាក់ដឹងនាំ |
| ១ | ហេង ដាណារ៉ូ | | ១៧៨ | ០៤ | ៥៧ | ៩៥ | ០ | ២២ |
| ២ | អេង ឆៃអ៊ាង | | ១៣២ | ០៦ | ១៧ | ៩៨ | ០២ | ០៩ |
| ៣ | កែ សុវណ្ណរតន៍ | | ១១៤ | ០២ | ៦៩ | ៤០ | ០៣ | ០ |
| ៤ | អ៊ូ ច័ន្ទឫទ្ធិ | | ៩៤ | ០៣ | ៣០ | ៦១ | ០ | ០ |
| ៥ | កែវ ភិរម្យ | | ៧២ | ០៥ | ០៣ | ៥៣ | ០៣ | ០៨ |
| ៦ | នួម សុភ័ណ | | ៦២ | ០ | ៤៨ | ០៨ | ០១ | ០៥ |
| ៧ | ហូរ វ៉ាន់ | | ៤៩ | ០១ | ១៤ | ៣០ | ០១ | ០៣ |
| ៨ | គង់ បូរ៉ា | | ៤៧ | ០១ | ២៣ | ១៦ | ០ | ០៧ |
| ៩ | កែ ច័ន្ទមុនី | | ៤៦ | ០ | ៣៨ | ០៦ | ០ | ០២ |
| ១០ | ឡោក ខេង | | ៤៣ | ៦ | ២០ | ១០ | ០៤ | ០៣ |

## ៤.២ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

ខុមហ្វ្រែលបានកំណត់រយៈពេលនៃការឃ្លាំមើលសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងឆ្នាំទី៣នេះ គិតចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ រហូតដល់ខែតុលា ឆ្នាំ២០១៦ និងកំណត់គោលបំណងសំខាន់ៗនៃសកម្មភាពចុះមូលដ្ឋានចំនួន០៥ គោលបំណងរួមមាន៖ ១.ការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ដោះស្រាយបញ្ហានានានៅតាមមូលដ្ឋាន (អន្តរាគមន៍) ២.ការចុះមូលដ្ឋានក្នុងគោលបំណងសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា (សួរសុខទុក្ខ) ៣.ការចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងបណ្តាញផ្ទៃក្នុងគណបក្ស (ពង្រឹងគណបក្ស) ៤.ការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកាសាធារណៈ (វេទិកាសាធារណៈ) និង ៥.ការចុះមូលដ្ឋានក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ (អមដំណើរ)។




ខុមហ្វ្រែលអង្កេតឃើញថា គោលបំណងនៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រទាំង២គណបក្ស គឺផ្តោតសំខាន់លើគោលបំណង ចុះជួបសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន៤៥% នៃសកម្មភាពចុះមូលដ្ឋានសរុប។ ខណៈដែលគោលបំណងក្នុងការចុះពង្រឹងផ្ទៃក្នុងគណបក្សមាន៣៨% រីឯគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំមាន១៩% គោលបំណងការចុះដោះស្រាយ និងអន្តរាគមន៍មាន៥% និងសកម្មភាពក្នុងគោលបំណងចូលវេទិកាសាធារណៈមាន

១% នៃសកម្មភាពចុះមូលដ្ឋានសរុប។

ជារួម ការចុះមូលដ្ឋាននៃគណបក្សទាំងពីរ គឺផ្តោតសំខាន់តែការចុះសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផល ការចុះអន្តរាគមន៍ និងចុះពង្រឹងគណបក្ស ខណៈសកម្មភាពចូលរួមក្នុងវេទិកាសាធារណៈនៅតែមិនសូវមាននៅឡើយ។

### ៤.៣ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនីមួយៗ

ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ខែតុលា ឆ្នាំ២០១៦ បើតាមទិន្នន័យដែលខុមហ្វ្រែលទទួលបានពីនានាឃើញថា មានអ្នកតំណាងរាស្ត្រចំនួន៥៦រូប ពីគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានចំនួន៦១៧លើក។ ចំណែកឯគណបក្សសង្គ្រោះជាតិមានអ្នកតំណាងរាស្ត្រចំនួន៤៦រូប បានចុះមូលដ្ឋានចំនួន១១៨៤លើក។

***<u>តារាងទី៥៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស</u>***

| គោលបំណងនៃការចុះមូលដ្ឋានទាំងរបស់តំណាងរាស្ត្រគណបក្ស | គណបក្សនយោបាយ | | សរុប (លើក) |
|---|---|---|---|
| | ៥៦ រូប | ៤៦រូប | |
| ការចុះសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ៣៧៧ | ៤៣៦ | ៨១៣ |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១០៥ | ៥៧៦ | ៦៨១ |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៩៦ | ១២៤ | ២២០ |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | ៣០ | ៣៨ | ៦៨ |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០៩ | ១០ | ១៩ |
| **សរុបគោលបំណងតាមគណបក្ស** | **៦១៧** | **១១៨៤** | **១៨០១** |

តារាងខាងលើបង្ហាញអំពីចំនួននៃសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ទៅតាមគោលបំណងនីមួយៗនៃគណបក្សទាំងពីរ។ គោលបំណងទី១នៃការចុះមូលដ្ឋាន គឺផ្តោតទៅលើការជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសមិទ្ធិផលនានាមានចំនួន៨១៣លើកនៃការចុះមូលដ្ឋានសរុប។ ចំពោះគោលបំណងទី២នៃការចុះមូលដ្ឋាន គឺផ្តោតលើការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមានចំនួន៦៨១លើក គោលបំណងទី៣ គឺផ្តោតលើការអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនមានចំនួន២២០លើក គោលបំណងទី៤នៃការចុះមូលដ្ឋាន គឺផ្តោតលើការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន៦៨លើក និងគោលបំណងទី៥នៃការចុះមូលដ្ឋាន គឺផ្តោតលើការចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានចំនួន១៩លើកនៃការចុះមូលដ្ឋានសរុប។

គួរបញ្ជាក់ដែរថា សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងគោលបំណងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋក្នុងរយៈពេលនេះ មានការកើនឡើងជាងក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥។ មូលហេតុចំបងៗនៃការកើនឡើងមានដូចជា ទី១.កម្ពុជាជួបប្រទេះនឹងគ្រោះរាំងស្ងួត ដែលបណ្តាលឲ្យអ្នកតំណាងរាស្ត្រ ពិសេសតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា រួមជាមួយអាជ្ញាធរមានសមត្ថកិច្ចចុះជួយអន្តរាគមន៍ចែកទឹកស្អាតដល់ប្រជាពលរដ្ឋ និងទី២.បញ្ហាទំនាស់ដីធ្លីនៅតែបន្តដែលធ្វើឲ្យអ្នកតំណាងរាស្ត្របន្តចុះអន្តរាគមន៍បញ្ហានេះ។ ប៉ុន្តែទោះជាយ៉ាងណា ភាគច្រើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតតែទៅលើការចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ដោយមិនសូវមានសកម្មភាព

អន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋនោះទេ។

*ដ្យាក្រាម១៖ ការប្រៀបធៀបចំនួននៃការចុះមូលដ្ឋានតាមគោលបំណងរវាងតំណាងស្ត្រីគណបក្សប្រជាជនកម្ពុជា និង តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ*




ដ្យាក្រាមនេះ បង្ហាញពីការប្រៀបធៀបចំនួនសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមគោលបំណងនីមួយៗរវាងគណបក្សនយោបាយទាំងពីរ។

ភាគច្រើនការចុះមូលដ្ឋាននៃអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា គឺផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ សមិទ្ធិផលនានា ដែលមានតំណាងរាស្ត្រចុះធ្វើសកម្មភាពចំនួន៣៧៧លើក (ស្មើនឹង៦១%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស) ខណៈដែលការចុះមូលដ្ឋាន ក្នុងគោលបំណង ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្សមានចំនួន១០៥លើក (ស្មើនឹង១៧%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។ រីឯការចុះមូលដ្ឋាន ក្នុងគោលបំណងផ្តោតលើការអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនមានចំនួន៩៦លើក (ស្មើនឹង១៦%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។ ដោយឡែក ការចុះមូលដ្ឋានផ្តោតលើសកម្មភាពអន្តរាគមន៍មានចំនួន៣០លើក (ស្មើនឹង០៥%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស) និងវេទិកាសាធារណៈមានចំនួន០៩លើក (ស្មើនឹង០១%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។

ចំណែកឯការចុះមូលដ្ឋាននៃតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិវិញ ភាគច្រើន គឺផ្តោតទៅលើការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សដែលមានសកម្មភាពចំនួន៥៧៦លើក (ស្មើនឹង៤៩%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។ ខណៈដែលការចុះមូលដ្ឋានក្នុងគោលបំណងសំណេះសំណាល សុខទុក្ខមានចំនួន៤៣៦លើក (ស្មើនឹង៣៧%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។ រីឯការចុះមូលដ្ឋានក្នុងគោលបំណងផ្តោតលើការអមដំណើរថ្នាក់ដឹកនាំគណបក្សមានចំនួន១២៤លើក (ស្មើនឹង២០%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។ ដោយឡែក ការចុះមូលដ្ឋានផ្តោតលើសកម្មភាពអន្តរាគមន៍មានចំនួន៣៨លើក (ស្មើនឹង០៣%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស) និងសកម្មភាពចូលរួមវេទិកាសាធារណៈមានចំនួន០៩លើក (ស្មើនឹង០១%នៃសកម្មភាពចុះមូលដ្ឋានសរុបក្នុងបក្ស)។

ជាសរុប សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាភាគច្រើនផ្តោតទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ចែកអំណោយ សម្ពោធសមិទ្ធិផល ខណៈដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិផ្តោតលើការជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងចុះពង្រឹងបណ្តាញគណបក្ស។ ចំពោះសកម្មភាពចូលរួមវេទិកាសាធារណៈ និងអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ គឺមិនសូវមានសកម្មភាពទេ។

**ខាងក្រោមនេះគឺជាករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សទាំងពីរៈ**

នេះជាករណីចុះមូលដ្ឋានខ្លះៗរបស់តំណាងរាស្ត្រពីគណបក្សនយោបាយទាំងពីរ។ ខុមហ្វ្រែលសូមលើកយកសកម្មភាពរបស់តំណាងរាស្ត្រចំនួន៣រូបដែលបានចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រដែលចុះមូលដ្ឋានពីគណបក្សទាំងពីរ។

នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៦ លោកជំទាវ នួម សុភ័ណ តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យពីគណបក្សប្រជាជនកម្ពុជា បានចុះសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងបាននាំយកស័ង្កសីចំនួន១០០សន្លឹក មី១០កេស ទឹកស៊ីអ៊ីវ១០យួរ ទឹកត្រី១០យួរ និងថវិកា២០ម៉ឺនរៀលជូនប្រជាពលរដ្ឋដែលមានផ្ទះប្រក់ស្បូវចំនួន១០គ្រួសារ នៅភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ និងជួបសំណេះសំណាលជាមួយអាជ្ញាធរភូមិ ដោយឧបត្ថម្ភថវិកា១០ម៉ឺនរៀល។ នៅថ្ងៃដដែល លោកជំទាវ បានជួបសំណេះសំណាលជាមួយលោក អ៊ិន ទៀងលី អតីតយុទ្ធជនមានជំងឺប្រចាំកាយនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ និងឧបត្ថម្ភថវិកា១០ម៉ឺនរៀល ផងដែរ។

នៅរសៀលថ្ងៃទីទី០៨ មេសា ឆ្នាំ២០១៦ ឯកឧត្តម ប៉ាល់ សំអឿន តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យពីគណបក្សប្រជាជនកម្ពុជា បានចុះសំណេះសំណាល និងប្រគល់ផ្ទះស័ង្កសីជូនប្រជាពលរដ្ឋក្រីក្រនៅឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យចំនួន២៣៦ខ្នងផ្ទះ។ នៅថ្ងៃដដែលឯកឧត្តម បានចូលរួមបាយសាមគ្គីនៅសាលាខេត្តបន្ទាយមានជ័យ ជាមួយមន្ត្រីរាជការ មន្ត្រីរាជការចូលនិវត្តន៍ និងអង្គការនានាក្នុងខេត្ត។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ សម្តេច គង់ សំអុល តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ឆ្នាំង បានចុះចែកអំណោយរបស់សម្តេចម៉ែ និងអំណោយរបស់ព្រះមហាក្សត្រ នៅឃុំស្វាយ ស្រុកសាមគ្គីមានជ័យ និងឃុំលង្វែក ស្រុកកំពង់ត្រឡាច ដល់អ្នករងគ្រោះដោយធម្មជាតិចំនួន១៩៦គ្រួសារ។

ចំណែកឯតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិវិញ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តម គង់ បូរ៉ា តំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែងបានចុះលើកស្លាកគណបក្សសង្គ្រោះជាតិ នៅភូមិបារាយណ៍លិច សង្កាត់បារាយណ៍ ក្រុងព្រៃវែង និងជួបសំណេះសំណាលជួបជាមួយក្រុមដឹកនាំគណបក្សប្រចាំមូលដ្ឋាន និងប្រជាពលរដ្ឋអ្នកគាំទ្រគណបក្ស។

ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ តំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង បានចុះទៅជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំថ្នាក់មូលដ្ឋានរបស់គណបក្ស ប្រចាំនៅស្រុកពាមរក៍ និងប្រជាពលរដ្ឋដែលមានចំនួនប្រមាណជិត១០០០នាក់។

ឯកឧត្តម យន្ត ថារូ តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦ បានជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាខេត្ត ស្រុក/ក្រុង សង្កាត់/ឃុំ នៅទីស្នាក់គណបក្សខេត្ត ក្នុងសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

### ៤.៤ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី/ខេត្ត

ការិយាល័យតំណាងរាស្ត្រ ជាទីកន្លែងទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងជាកន្លែងធ្វើការងាររបស់អ្នកតំណាងរាស្ត្រពេលចុះមូលដ្ឋាន។ លើសពីនេះទៀត ការិយាល័យតំណាងរាស្ត្រក៏ជាទីកន្លែងមួយដែលសម្រាប់បម្រើដល់ផលប្រយោជន៍ប្រជាពលរដ្ឋដោយមិនប្រកាន់ពីគណបក្សនយោបាយ និងជាកន្លែងសម្រាប់ទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋជូនទៅតំណាងរាស្ត្រដែលជាអ្នកតំណាងរបស់ខ្លួនដើម្បីធ្វើការដោះស្រាយ។

ការសង្កេតរបស់បណ្តាញខុមហ្វ្រែលប្រចាំក្នុងរាជធានី ខេត្តឃើញថា ការិយាល័យតំណាងរាស្ត្រនៅតាមបណ្តាខេត្តមួយចំនួនមានដំណើរការល្អប្រសើរក្នុងការបំពេញការងារ ដោយមានការបើកដំណើរការការិយាល័យ និងការបំពេញតួនាទីការងារ

របស់មន្ត្រីការិយាល័យពេញលេញតាមម៉ោងកំណត់។ ទោះជាយ៉ាងក៏ដោយការសង្កេតឃើញថា នៅតែមានការិយាល័យតំណាងរាស្ត្រមួយចំនួនបន្តមានបញ្ហាអសកម្មដដែលដូចជា ការបើក/បិទដំណើរការការិយាល័យមិនត្រឹមត្រូវម៉ោងកំណត់ និងការបំពេញការងារមន្ត្រីប្រចាំនៅតាមការិយាល័យទាំងនោះមិនពេញលេញជាដើម។

រាជធានី ខេត្តដែលមានការិយាល័យតំណាងរាស្ត្រ ហើយបានបើកដំណើរការ និងបំពេញតួនាទីរបស់ខ្លួននោះរួមមានៈ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តរតនៈគីរី ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ និងរាជធានីភ្នំពេញ។ ទោះជាយ៉ាងណា ខុមហ្វ្រែលទទួលបានព័ត៌មានថា ការិយាល័យមួយចំនួនមិនបានបំពេញការងាររបស់ខ្លួនពេញលេញនោះទេ ព្រោះមន្ត្រីប្រចាំការបានបើកយឺតឬ/និងបិទទ្វារមុនម៉ោង និងខ្លះបើកដំណើរការមិនទៀងទាត់ជាដើម។

ជាមួយគ្នានេះការិយាល័យប្រចាំនៅខេត្តកំពត ខេត្តកែប ខេត្តកណ្តាល ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ មានបញ្ហាអសកម្មមួយចំនួនដូចជាៈ ការិយាល័យខ្លះបានបើកដំណើរការតែមួយពេល (ពេលព្រឹក) ខ្លះទៀតបើក/បិទដំណើរការការិយាល័យមិនតាមម៉ោងរដ្ឋបាល។ ចំណែកមន្ត្រីបម្រើការនៅតាមការិយាល័យវិញ មិនសូវបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រពេញលេញនោះទេ ដោយអះអាងថា អ្នកតំណាងរាស្ត្រភាគច្រើនមិនបានផ្តល់ព័ត៌មានអំពីការចុះបេសកកម្មរបស់ខ្លួនទេ។ មន្ត្រីខ្លះបានយកព័ត៌មានអំពីការធ្វើសកម្មភាពរបស់តំណាងរាស្ត្រពីគណបក្សនយោបាយទៅវិញ។

ដោយឡែកនៅក្នុងខេត្តត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យមិនទាន់មានការិយាល័យតំណាងរាស្ត្រនៅឡើយទេ។

# ៥កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា .

## ៥.១ កិច្ចអន្តរាគមន៍របស់រដ្ឋសភា

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។[4] អ្នកតំណាងរាស្ត្រមានតួនាទីក្នុងការតាក់តែង អនុម័តច្បាប់ និងតាមដានការអនុវត្តការងាររបស់រដ្ឋាភិបាល។ ក្រៅតែពីសកម្មភាពប្រជុំពិភាក្សាអនុម័តច្បាប់ រដ្ឋសភាបានធ្វើសកម្មភាពអន្តរាគមន៍មួយចំនួនដូចជាៈ ការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺនៅរដ្ឋសភាជុំវិញបញ្ហាមិនប្រក្រតីមួយចំនួន ការទទួល និងអន្តរាគមន៍ដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋជាដើម។

អំឡុងពេលនេះ រដ្ឋសភាបានកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងកិច្ចប្រជុំរដ្ឋសភាពេញអង្គចំនួន១លើក និងនៅក្នុងកិច្ចប្រជុំគណៈកម្មការជំនាញចំនួន២លើក និងសកម្មភាពចុះពិនិត្យ និងស្តាប់ការបកស្រាយការងារនៅតាមក្រសួង។

ជាក់ស្តែង នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ រដ្ឋសភាបានកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺដោយផ្ទាល់ជុំវិញការអនុវត្តច្បាប់កន្លងមក។ នេះជាលើកទី២ហើយដែលរដ្ឋមន្ត្រីត្រូវបានកោះហៅមកបំភ្លឺផ្ទាល់មាត់ដោយរដ្ឋសភា ដែលលើកទី១រដ្ឋសភាបានកោះហៅរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលមកបំភ្លឺលើបញ្ហាទំនប់វារីអគ្គិសនីសេសានក្រោម២ កាលពីឆ្នាំ២០១៤។ ការឆ្លើយបំភ្លឺក្នុងកិច្ចប្រជុំរដ្ឋសភារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នេះ គឺប្រើថេរវេលាតែ២០នាទីប៉ុណ្ណោះ ហើយមានតែ២សំណួរប៉ុណ្ណោះត្រូវបានចោទសួរទៅរដ្ឋមន្ត្រី។ គួរបញ្ជាក់ថា ការឆ្លើយបំភ្លឺនេះគឺមិនមានវត្តមានតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចូលរួមនោះទេ។ ការកោះហៅបំភ្លឺនេះ គឺធ្វើឡើងដោយក្រុមតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ នៅស្របពេលដែលមានការរិះគន់យ៉ាងខ្លាំងពីសាធារណជន ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធវិស័យសិទ្ធិមនុស្ស និងយុត្តិធម៌ ជុំវិញការអនុវត្តច្បាប់នៅកម្ពុជាលើការចាប់ខ្លួន ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រ និងសកម្មជនគណបក្សនយោបាយ និងសកម្មជន

[4] មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញ

សិទ្ធិមនុស្សនៃអង្គការសង្គមស៊ីវិល។

ជុំវិញករណីបណ្តឹងវិញ ខុមហ្វ្រែលទទួលបានព័ត៌មាន និងសង្កេតឃើញថា ឆ្នាំនេះរដ្ឋសភាជាតិ មានសកម្មភាពទទួលបណ្តឹងដោយផ្ទាល់នៅរដ្ឋសភា និងតាមមូលដ្ឋានមានចំនួន២១បណ្តឹង។ បើធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី២ សកម្មភាពទទួលពាក្យបណ្តឹងមានការថយចុះ ដែលក្នុងរយៈពេលនោះ រដ្ឋសភាទទួលពាក្យបណ្តឹងដោយផ្ទាល់ពីប្រជាពលរដ្ឋចំនួន២៥បណ្តឹង។ ភាគច្រើននៃបណ្តឹងរបស់ប្រជាពលរដ្ឋ គឺស្នើសុំកិច្ចអន្តរាគមន៍ពីរដ្ឋសភា និងអ្នកតំណាងរាស្ត្រឲ្យជួយដោះស្រាយវិវាទនានាពិសេស គឺវិវាទដីធ្លី និងវិវាទការងារ។

ជាការឆ្លើយតបនឹងបណ្តឹងប្រជាពលរដ្ឋដែលបានដាក់មកស្ថាប័នកំពូលរបស់ជាតិមួយនេះ គណៈកម្មការជំនាញទី១នៃរដ្ឋសភាដែលជាសេនាធិការទទួលបន្ទុកកិច្ចការនេះ បានធ្វើការអន្តរាគមន៍ការចុះផ្ទាល់ទៅកន្លែងទំនាស់ដើម្បីសិក្សាស្រាវជ្រាវ និងស្វែងយល់ពីមូលហេតុនៃវិវាទ និងធ្វើកិច្ចអន្តរាគមន៍ ដោយកោះអញ្ជើញរដ្ឋមន្ត្រីពាក់ព័ន្ធមកបំភ្លឺនៅគណៈកម្មការ និងជួបជាមួយមន្ទីរពាក់ព័ន្ធនៅតាមខេត្តជាដើម។ លើសពីនេះ បន្ទាប់ពីទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ រដ្ឋសភាបានអន្តរាគមន៍លើបណ្តឹងទាំងនោះតាមយន្តការដោះស្រាយរបស់រដ្ឋសភា។ ខុមហ្វ្រែលទទួលបានព័ត៌មានថា បញ្ហាទំនាស់ដីធ្លីចំនួន០៧ករណី ត្រូវបានស្ថាប័នរដ្ឋសភាអន្តរាគមន៍ភ្លាមៗ និងបានបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការសិក្សា និងដោះស្រាយបញ្ហាទាំងនោះ។

### ៥.២ លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ

ក្នុងរយៈពេលនេះ ខុមហ្វ្រែលទទួលព័ត៌មានអំពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រចំនួន២៤ច្បាប់។ លិខិតទាំងនោះបានថ្វាយ និងផ្ញើជូនព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងរដ្ឋសភា។ ភាគច្រើននៃលិខិតជាលិខិតធ្វើឡើងដោយក្រុមអ្នកតំណាងរាស្ត្រ ក្នុងគោលបំណងដើម្បីស្នើសុំការអន្តរាគមន៍ ការស្នើ ឬអំពាវនាវចាត់វិធានការពីស្ថាប័នពាក់ព័ន្ធដើម្បីដំណោះស្រាយបញ្ហានានា។ ក្នុងចំណោមលិខិតទាំងនោះ លិខិតចំនួន២៣ច្បាប់ ធ្វើឡើងដោយតំណាងរាស្ត្រ/ក្រុមតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ និងលិខិតចំនួន០១ច្បាប់ ធ្វើឡើងដោយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។

លិខិតក្នុងគោលបំណងអន្តរាគមន៍ចំនួន០៥ច្បាប់ ក្នុងគោលបំណង អំពាវនាវ/ស្នើសុំចាត់វិធានការមានចំនួន១៦ច្បាប់ ក្នុងគោលបំណងកោះហៅមន្ត្រីរដ្ឋាភិបាលមកបំភ្លឺនៅរដ្ឋសភា និងគណៈកម្មការជំនាញនៃរដ្ឋសភាមានចំនួន០២ច្បាប់ និងក្នុងគោលបំណងសុំការឆ្លើយតបពីអាជ្ញាធរមានសមត្ថកិច្ចចំនួន០១ច្បាប់។

ជាលទ្ធផល លិខិតមួយចំនួនទទួលបានការឆ្លើយតបពីស្ថាប័នដែលពាក់ព័ន្ធ។ ខុមហ្វ្រែលទទួលព័ត៌មានថា មានលិខិតចំនួន១៦ច្បាប់ប៉ុណ្ណោះ មានការឆ្លើយតបពីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ដែលក្នុងនោះការឆ្លើយតបទៅនឹងលិខិតបំណងអំពាវនាវ/ស្នើចាត់វិធានការមានចំនួន១១ច្បាប់ លិខិតកោះហៅរដ្ឋមន្ត្រីរដ្ឋាភិបាលមមកបំភ្លឺនៅក្នុងកិច្ចប្រជុំសភា និងគណៈកម្មការជំនាញនៃរដ្ឋសភាមានចំនួន០២ច្បាប់ និងលិខិតថ្វាយព្រះមហាក្សត្រមានចំនួន០២ច្បាប់ និងលិខិតឆ្លើយតបពីអាជ្ញាធរមានសមត្ថកិច្ចចំនួន១ច្បាប់។

គួរបញ្ជាក់ផងដែរ លិខិតចំនួន២ច្បាប់ ពីក្រុមអ្នកតំណារាស្ត្រគណបក្សសង្គ្រោះជាតិ បានស្នើសុំឲ្យព្រះមហាក្សត្រអន្តរាគមន៍ឲ្យមានការដោះលែងឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ដែលត្រូវអាជ្ញាធរមានសមត្ថកិច្ចចាប់ និងឃុំខ្លួន និងស្នើសុំព្រះអង្គជាអាជ្ញាកណ្តាលដើម្បីធានាការប្រព្រឹត្តនៃអំណាចសាធារណៈ។ លិខិតទាំងពីរនេះធ្វើឡើងក្រោយពីមានការចាប់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមណ្ឌលខេត្តសៀមរាបឯកឧត្តម អ៊ុំ សំអាន និងចំណាត់ការនានារបស់អាជ្ញាធមានសមត្ថកិច្ចមកលើក្រុមគណបក្សប្រឆាំងដែលគណបក្សនេះយល់ឃើញថា ជាការគៀបសង្កត់មកលើគណបក្សខ្លួន។ ជាលទ្ធផល ព្រះមហាក្សត្រ បានបញ្ជូនសំណើនេះទៅរដ្ឋាភិបាលដើម្បីពិនិត្យបន្ត ប៉ុន្តែត្រូវបានប្រមុខរដ្ឋាភិ

បាលធ្វើការបដិសេធសំណើសុំដោះលែងនោះ ដោយអះអាងថា ជាការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ព្រោះតំណាងរាស្ត្រនោះបានប្រព្រឹត្តបទល្មើស។

លិខិតមួយចំនួនទៀតធ្វើឡើងដោយ សម្តេចប្រធានរដ្ឋសភា ក្នុងគោលបំណងឆ្លើយតបដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការសម្រេចអនុញ្ញាតឲ្យបន្តនីតិវិធីចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន ឯកឧត្តម អ៊ុំ សំអានតំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប។

## ៦. ករណី និងព្រឹត្តិការណ៍ទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ

### ៦.១ ការចាប់ខ្លួនតំណាងរាស្ត្រមណ្ឌលខេត្តសៀមរាបឯកឧត្តម អ៊ុំ សំអាន ជាការរំលោភរដ្ឋធម្មនុញ្ញ?

ឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលសៀមរាបពីគណបក្សសង្គ្រោះជាតិ ត្រូវបាននគរបាលខេត្តសៀមរាបឃាត់ខ្លួននៅវេលាម៉ោងជិត១ រំលងអធ្រាត្រ ឈានចូលថ្ងៃទីថ្ងៃ១១ ខែមេសា ឆ្នាំ២០១៦ នៅពេលឯកឧត្តមកំពុងដកប្រាក់ពីទូអេធីអឹម ស្ថិតនៅក្នុងក្រុងសៀមរាប។ ការឃាត់ខ្លួននេះ នៅខណៈដែលឯកឧត្តមទើបតែត្រឡប់មកពីសហរដ្ឋអាមេរិកកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៦ តាមជើងយន្តហោះមួយដែលចុះចតនៅព្រលានយន្តហោះខេត្តសៀមរាប។

បន្ទាប់ពីចាប់ខ្លួន នគរបាលខេត្តសៀមរាបបានបញ្ជូនឯកឧត្តមមកកាន់ក្រសួងមហាផ្ទៃដើម្បីសាកសួរ។ នៅបន្ទាប់ពីសាកសួររួច ប៉ូលិសក្រសួងមហាផ្ទៃបានបញ្ជូនឯកឧត្តម មកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីឲ្យព្រះរាជអាជ្ញា និងចៅក្រមសាកសួរនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦។ នៅព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តម អ៊ុំ សំអាន ត្រូវបានតុលាការចោទប្រកាន់ចំនួនពីរបទល្មើស គឺទី១.ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងទី២.ញុះញង់ឲ្យមានការរើសអើង។ នៅស្របពេលគ្នានេះដែរ នៅសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៦៣រូប បានលើកដៃអនុម័តយល់ព្រមឲ្យក្រសួងមានសមត្ថកិច្ចបន្តនីតិវិធីចោទប្រកាន់ ឃាត់ខ្លួន ឯកឧត្តម អ៊ុំ សំអាន។

ចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ច និងរដ្ឋសភាខាងលើ ក៏ព្រោះតែមានការចោទប្រកាន់ថា ឯកឧត្តម អ៊ុំ សំអាន បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ដោយយោងទៅលើសំដីនៃការបញ្ចេញមតិ ដែលសួរដោយអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីក្នុងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៦។ ផ្អែកតាមខ្លឹមសារសំដី ឬយោបល់ដែលឯកឧត្តម អ៊ុំ សំអាន ក្នុងពេលសម្ភាសន៍ឆ្លងឆ្លើយគ្នាជាមួយអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី ការសំដែងមតិនោះ មិនគួរត្រូវបានចាត់ទុកជាបទល្មើសឡើយ ខណៈដែលការបញ្ចេញមតិរបស់ឯកឧត្តមគ្មានការឃោសនា ឬអំពាវនាវឲ្យមានការក្រោកប្រឆាំងតវ៉ានឹងការបោះបង្គោលព្រំដែនរបស់រដ្ឋាភិបាល ឬតវ៉ាប្រឆាំងនឹងការប្រើប្រាស់ផែនទីដែលកំណត់យកដោយរដ្ឋាភិបាលកម្ពុជានោះទេ។ ការបញ្ចេញមតិ ឬទស្សនៈផ្ទាល់ខ្លួនដោយផ្អែកលើហេតុផលសមរម្យមួយក្នុងនាមជាអ្នកតំណាងរាស្ត្រម្នាក់ អំពើនោះមិនគួរត្រូវបានចាត់ទុកថាមានចរិកជាបទល្មើសព្រហ្មទណ្ឌឡើយ។ មួយវិញទៀត សកម្មភាព និងការបញ្ចេញមតិរបស់ឯកឧត្តម អ៊ុំ សំអាន ក៏មិនមានធាតុផ្សំគ្រប់គ្រាន់ថា ជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែងនោះដែរ។

យោងតាមមាត្រា៨០ នៃរដ្ឋធម្មនុញ្ញ បានចែងថា តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ហើយតំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។

មាត្រាដដែលបញ្ជាក់ថា៖ «សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួនការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល»។

គួរបញ្ជាក់ថា ឯកឧត្តម អ៊ុំ សំអាន ជាអ្នកតស៊ូមតិក្នុងបញ្ហាព្រំដែនដ៏ចម្រូងចម្រាសរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ឯកឧត្តមបានធ្វើសកម្មភាពជាច្រើនទាក់ទងបញ្ហានេះដូចជា ការចុះពិនិត្យនៅតាមបន្ទាត់ព្រំដែន ការដាក់លិខិតទៅរាជរដ្ឋាភិបាលស្នើបំភ្លឺពាក់ព័ន្ធនឹងការប្រើប្រាស់ផែនទី ការចោទប្រកាន់របស់ប្រជាពលរដ្ឋអំពីការរំលោភបូរណភាពទឹកដី និងការធ្វើទុក្ខបុកម្នេញមកលើប្រជាពលរដ្ឋរស់នៅតាមបន្ទាត់ព្រំដែនពីភាគីវៀតណាមជាដើម។ ការសង្កេតមើលឃើញថា ការចោទប្រកាន់អំពីការប្រើប្រាស់ផែនទី គឺជាចំណុចរសើបខ្លាំងដែលប្រមុខដឹកនាំ និងមន្ត្រីរាជរដ្ឋាភិបាលបានសម្ដែងប្រតិកម្មខ្លាំងៗទៅលើការចោទប្រកាន់នេះ។

### ៦.២ បញ្ហាសុវត្ថិភាពគឺជាក្ដីបារម្ភរបស់តំណាងរាស្ត្រ

បន្ទាប់ពីការប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរទៅលើអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ បញ្ហាអសន្តិសុខ/ភាពងាយរងគ្រោះ ត្រូវបានមើលឃើញថា មានគ្រប់ពេល និងគ្រប់ទីកន្លែង មិនថាចំពោះប្រជាពលរដ្ឋសាមញ្ញទេ ប៉ុន្តែសូម្បីតែអ្នកតំណាងរាស្ត្រ ដែលការពារដោយអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពិសេសមួយចំនួនមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ បញ្ហានេះត្រូវបានមើលឃើញថា វាប៉ះពាល់ដល់ប្រសិទ្ធភាពការងារបម្រើម្ចាស់ឆ្នោតរបស់អ្នកតំណាងរាស្ត្រ។

ដោយយោងលើបញ្ហាអសន្តិសុខនេះ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានសម្រេចមិនចូលរួមប្រជុំពេញអង្គនៃរដ្ឋសភា ក្នុងសម័យប្រជុំពេញអង្គលើកទី៧ ក្នុងអំឡុងខែតុលា ឆ្នាំ២០១៦។ ក្រុមអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានអះអាងថា ពួកគាត់អាចនឹងត្រូវមនុស្សមួយក្រុមដែលគេរៀបចំទុក បង្កអំពើហិង្សាដូចអ្នកតំណាងរាស្ត្រ២រូបដែលទទួលរងអំពើហិង្សាពីក្រុមបាតុករទាមទារទម្លាក់តំណែងឯកឧត្តម កឹម សុខា កាលពីអំឡុងចុងខែតុលា ឆ្នាំ២០១៥។ ការអះអាងនេះ គឺនៅស្របពេលដែលមានបាតុកម្មប្រឆាំងនឹងវត្តមានរបស់ឯកឧត្តម ហ៊ុន ម៉ាណែត ដែលបំពេញទស្សនកិច្ចនៅក្រៅប្រទេស ហើយមានការចោទប្រកាន់ថា គណបក្សសង្គ្រោះជាតិនៅពីក្រោយបាតុកម្មនោះ។

គួរបញ្ជាក់ថា បាតុកម្មទម្លាក់តំណែងឯកឧត្តម កឹម សុខា ពីអនុប្រធានទី១នៃរដ្ឋសភា ហើយឈានទៅដល់ការប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរលើអ្នកតំណាងរាស្ត្រនាពេលនោះ គឺនៅស្របពេលដែលមានបាតុកម្មប្រឆាំងនឹងដំណើរទស្សនកិច្ចរបស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្រៅប្រទេស។

សូមរំលឹកថា អំពើហិង្សាលើអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងកន្លងមក គឺកើតឡើងនៅមុខរដ្ឋសភា នៅពេលដែលអ្នកតំណាងរាស្ត្រនោះចេញពីប្រជុំពេញអង្គរដ្ឋសភា។ ការសង្កេតឃើញថា មុនកើតអំពើហិង្សា មិនមានកំលាំងសមត្ថកិច្ចចេញមុខការពារ រក្សាសណ្ដាប់ធ្នាប់ និងបំបែកការតវ៉ាទាមទារទម្លាក់តំណែងឯកឧត្តម កឹម សុខា របស់ក្រុមបាតុករ ដូចសព្វដងនោះទេ ហើយកម្លាំងសន្តិសុខរបស់រដ្ឋសភាក៏មិនបានចេញមកធ្វើអន្តរាគមន៍ឲ្យបានទាន់ពេលវេលាបញ្ឈប់អំពើហិង្សានោះដែរ។

ទាក់ទងនឹងបញ្ហានេះដែរ នៅថ្ងៃទី៣១ ខែសីហា និងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ មានការចល័តកងកម្លាំងប្រដាប់អាវុធតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសនៅក្បែរទីស្នាក់ការកណ្ដាលរបស់គណបក្សសង្គ្រោះជាតិ។ ការចល័តកងកម្លាំងនេះត្រូវបានមន្ត្រីជាន់ខ្ពស់នៃកងយុទ្ធពលខេមរភូមិន្ទអះអាងថា ដើម្បីពង្រឹងរក្សាសណ្ដាប់ធ្នាប់ និងសន្តិភាព តែមិនមែនដើម្បីគំរាមកំហែងគណបក្សប្រឆាំងនោះទេ ប៉ុន្តែគណបក្សឆាំងបានចាត់ទុកការចល័តកងកម្លាំងប្រដាប់អាវុធនេះថា ជាការបំភ័យដល់ថ្នាក់ដឹកនាំ និងសមាជិកគណបក្សសង្គ្រោះជាតិ ហើយសកម្មភាពនេះមិនត្រឹមតែជាការគំរាមកំហែងដល់អ្នកនយោ

បាយ និងសកម្មជនបក្សប្រឆាំងប៉ុណ្ណោះទេ តែថែមទាំងបង្កឲ្យមានការភ័យខ្លាចដល់ប្រជាពលរដ្ឋទៀតផង។ គណបក្សប្រឆាំងបានអំពាវនាវដល់រដ្ឋាភិបាលឲ្យបញ្ឈប់នូវសកម្មភាពគំរាមកំហែងបែបនេះ និងស្នើឲ្យមានដំណោះស្រាយរួម ដើម្បីធានាស្ថេរភាព សន្តិភាព និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ រួមទាំងធានាបរិយាកាសនយោបាយឲ្យបានល្អប្រសើរសម្រាប់ដំណើរការបោះឆ្នោតនាពេលខាងមុខ។

### ៦.៣ ការរឹតត្បិតសកម្មភាពរបស់តំណាងរាស្ត្រពីគណបក្សប្រឆាំង

នៅស្របពេលដែលមានការខ្វែងគំនិតគ្នា រវាងគណបក្សនយោបាយទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា ហើយកំដៅនយោបាយក៏មានការកើតឡើង សកម្មភាពមួយចំនួនរបស់តំណាងរាស្ត្រគណបក្សប្រឆាំងត្រូវបានរឹតត្បិតពីអាជ្ញាធរមានសមត្ថកិច្ច។ ជាស្ដែងនៅព្រឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ អាជ្ញាធររាជធានីភ្នំពេញ បានដាក់កងកម្លាំងបិទផ្លូវជាតិលេខ២ ត្រង់ចំណុចស្ពានអាកាសក្បាលថ្នល់ និងនៅមុំអនុវិទ្យាល័យចាក់អង្រែលើ ដើម្បីរាំងការហែញត្តិរបស់ក្រុមតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិទៅដាក់នៅតាមបណ្ដាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាក្រុងបារីស ដើម្បីជម្រុញឲ្យមានការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីឲ្យបានពេញលេញនៅកម្ពុជា។ ក្រុមតំណាងរាស្ត្រគណបក្សប្រឆាំងបានចាត់ទុកទង្វើរបស់អាជ្ញាធរនេះថា ជាការគំរាមកំហែង ប៉ះពាល់ដល់សេរីភាពក្នុងការដើរហើររបស់ប្រជាពលរដ្ឋ និងសកម្មភាពសំដែងមតិរបស់អ្នកតំណាងរាស្ត្រ។

ដោយឡែក ចំពោះរដ្ឋសភាដែលដឹកនាំដោយគណបក្សកាន់អំណាចក៏មិននៅស្ងៀមដែរ ដោយបានធ្វើសេចក្ដីសម្រេចស្ដីពីការអនុវត្តវិន័យរបស់តំណាងរាស្ត្រ។ នៅក្នុងសេចក្ដីសម្រេចនោះ គឺមានគោលបំណងកំណត់បែបបទ និងនីតិវិធីក្នុងការអនុវត្តវិន័យរបស់តំណាងរាស្ត្រទាំងអស់ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា សមាជិកគណៈកម្មការនានានៃរដ្ឋសភាដែលខានមកប្រជុំ ដោយមូលហេតុមិនអាចយកជាការបាន និងគោលបំណងផ្សេងទៀត។ ការសង្កេតឃើញថា សេចក្ដីសម្រេចនេះ គឺជាការដាក់សម្ពាធមួយបន្ថែមទៀតដល់តំណាងរាស្ត្រគណបក្សប្រឆាំងដែលធ្វើពហិការមិនចូលរួមប្រជុំក្នុងរដ្ឋសភា ដោយហេតុផលសុវត្ថិភាព និងការធ្វើទុកបុកម្នេញមកលើថ្នាក់ដឹកនាំ និងតំណាងរាស្ត្រគណបក្សខ្លួន។ បញ្ហានេះត្រូវបានមើលឃើញថា ការធ្វើពហិការមិនចូលសភារបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនេះ គឺផ្ដើមចេញពីទំនាស់នយោបាយពោលគឺ មិនមែនផ្ដើមចេញពីការមិនគោរពវិន័យសុទ្ធសាធនោះទេ។ ដូច្នេះគណបក្សកាន់អំណាចគួរតែបង្ហាញភាពចាស់ទុំរបស់ខ្លួនក្នុងការអត់ឱន អធ្យាស្រ័យ និងផ្សះផ្សាជម្លោះនយោបាយ ដើម្បីឲ្យរដ្ឋសភាដំណើរការធម្មតា។

### ៦.៤ ចំណាត់ការរបស់រដ្ឋសភា និងតុលាការលើឯកឧត្តម កឹម សុខា

នៅបន្ទាប់ពីតំណាងរាស្ត្រគណបក្សកាន់អំណាចសម្រេចបោះឆ្នោតដកឯកឧត្តម កឹម សុខា ចេញពីតំណែងអនុប្រធានទី១នៃរដ្ឋសភាកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ឯកឧត្តមក៏ត្រូវបានតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាសម្រេចឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦បន្ថែមទៀត។ ឯកឧត្តម កឹម សុខា ត្រូវបានអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទបដិសេធក្នុងការចូលខ្លួនក្នុងនាមជាសាក្សី នៅក្នុងសំណុំរឿងស្នេហាមួយ។

ក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម កឹម សុខា ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៥ខែ និងពិន័យជាប្រាក់ចំនួន៨សែនរៀលលើបទចោទប្រកាន់ខាងលើ។ ឯកឧត្តមត្រូវបានព្រះមហាក្សត្រព្រះរាជទានលើកលែងទោស នៅថ្ងៃទី២ ខែធ្នូ ឆ្នាំង២០១៦ បន្ទាប់ពីមានការស្នើសុំពីសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។

ជាមួយគ្នានេះដែរ នៅមុន និងក្រោយការសំរេចសេចក្ដីរបស់តុលាការ ឯកឧត្តម កឹម សុខា ក៏ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់កងកម្លាំងប្រដាប់អាវុធឃាត់រថយន្ត និងព័ទ្ធទីស្នាក់ការគណបក្សសង្គ្រោះជាតិរហូតដល់ឯកឧត្តមឃុំខ្លួនឯងនៅក្នុងស្នាក់ការគណបក្សអស់រយៈពេលជាង៦ខែ។ ជាងនេះទៅទៀត ឯកឧត្តមក៏ត្រូវបានក្រុមយុវជនមួយក្រុមធ្វើការតវ៉ា

ទាមទារឲ្យបកស្រាយលើខ្សែអាត់សំឡេងរឿងស្នេហាមួយ ដែលគេចោទប្រកាន់ថា ជាការសន្ទនារបស់ឯកឧត្តម។ ការតវ៉ាទាមទារនេះ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ រហូតដល់មានចំណាត់ការពីរដ្ឋសភា និងអង្គភាពប្រឆាំងអំពើពុករលួយ។ រដ្ឋសភាបានស្នើឲ្យឯកឧត្តមឆ្លើយបំភ្លឺទៅក្រុមយុវជន រីឯអង្គភាពប្រឆាំងអំពើពុករលួយបានប្រកាសបើកការស៊ើបអង្កេត និងបើកស្រោមសំបុត្រប្រកាសទ្រព្យសម្បត្តិរបស់ឯកឧត្តម កឹម សុខា តាមពាក្យបណ្ដឹងរបស់ក្រុមយុវជននោះ និងក៏បានប្រកាសថាខ្សែអាត់សំឡេងនោះ គឺជាសំឡេងពិតរបស់ឯកឧត្តម កឹម សុខា និងអ្នកនាងខុម ចាន់តារាទី ហៅស្រីមុំទៀតផង។

ចំណាត់ការរបស់រដ្ឋសភា និងតុលាការមកលើឯកឧត្តម កឹម សុខា នេះ ត្រូវបានមើលឃើញថា វាមានលក្ខណៈនយោបាយ និងរំលោភរដ្ឋធម្មនុញ្ញ មាត្រា៨០ ដែលចែងអំពីអភ័យឯកសិទ្ធិសភា។ លើសពីនេះទៀត វាជាការរារាំងការធ្វើសកម្មភាពនៅមូលដ្ឋានរបស់ថ្នាក់ដឹកនាំគណបក្សរូបនេះ និងជាការបំបាក់ស្មារតីថ្នាក់ដឹកនាំ និងសកម្មជនគណបក្សប្រឆាំងដែលនៅបន្តធ្វើការរិះគន់ថ្នាក់ដឹកនាំរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥នេះ។

### ៦.៥ ភាពចម្រូងចម្រាសក្នុងការធ្វើវិសោធនកម្មប្រការ៤៨ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន៥០រូប បានស្នើវិសោធនកម្មប្រការ៤៨ថ្មី (៣) ដោយលុបចោលតួនាទីថ្នាក់ដឹកនាំតំណាងរាស្ត្រ និងតួនាទីប្រធានក្រុមមតិភាគតិចនៅក្នុងរដ្ឋសភា ពោលគឺខ្លឹមសារនៃវិសោធនកម្មថ្មីនេះបានវិលទៅដូចប្រការ៤៨ថ្មី (ពីរ)វិញ។ ការស្នើវិសោធនកម្មនេះធ្វើឡើងនៅបន្ទាប់ពីសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងអំពីបំណងនេះតាមរយៈសារព័ត៌មានមួយ ដោយសម្ដេចបានបញ្ជាក់ថា «បើយន្តការដែលបង្កើតឡើងតាមរយៈប្រការ៤៨ថ្មី (បី) វាពិបាកធ្វើការដោយរួមទាំងការប៉ុនប៉ងប្រើប្រាស់វា ដើម្បីចរចាដោះលែងអ្នកទោសដែលបំពានដល់អំណាចតុលាការផងនោះ យើងត្រូវតែធ្វើវិសោធនកម្មប្រការ៤៨ថ្មី (បី) ហើយវិលទៅប្រើប្រការ ៤៨ (ពីរ)នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាវិញ»។

ឆ្លើយតបភ្លាមៗនឹងសំណើរបស់តំណាងរាស្ត្រគណបក្សកាន់អំណាច នៅព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រជុំពិនិត្យលើស្នើវិសោធនកម្មប្រការ៤៨ថ្មី (៣)នេះ និងបានអនុម័តប្រគល់ឲ្យគណៈកម្មការនីតិកម្មសិក្សា មុននឹងដាក់ក្នុងរបៀបវារៈក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា ខណៈពេលសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ពីគណបក្សសង្គ្រោះជាតិ មិនយល់ស្រប ចំពោះការស្នើវិសោធនកម្មនេះឡើយ។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាភាគីគណបក្សប្រជាជនកម្ពុជា បានលើកហេតុផលនៃការស្នើវិសោធនកម្ម ដូចទៅនឹងអ្វីដែសម្ដេចនាយករដ្ឋមន្ត្រីបានថ្លែង និងបញ្ជាក់បន្ថែមថា គណបក្សសង្គ្រោះជាតិមិនមានភាពស្មោះត្រង់ក្នុងការសន្ទនា។ ដោយឡែក ភាគីគណបក្សសង្គ្រោះជាតិបានហៅការធ្វើវិសោធនកម្មនេះជាការដើរថយក្រោយ និងបញ្ជាក់ថា វានឹងមានការលំបាក ដើម្បីនាំទៅរកការចរចារវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងលើបញ្ហាខ្វែងគំនិតគ្នា និងបញ្ហាជាតិ ហើយគណបក្សមតិភាគច្រើន និងភាគតិចលែងមានការទទួលដោយច្បាប់បន្តទៀត។

នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ រដ្ឋសភាបានអនុម័តសេចក្ដីស្នើវិសោធនកម្មនេះដោយឯកបក្ស ពោលគឺមិនមានសំឡេងគាំទ្រពីគណបក្សប្រឆាំង។ ជុំវិញបញ្ហានេះ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ បានលើកឡើងថា ការធ្វើវិសោធនកម្មដោយផ្អែកលើបញ្ហាបុគ្គល គឺមិនអាចទទួលយកបានទេ។ តំណាងរាស្ត្រគណបក្សប្រឆាំងមិនចូលរួមអនុម័ត ក៏ព្រោះមិនចង់ក្លាយជាចំណែកនៃការសម្រេចចិត្តដែលប៉ះពាល់ប្រយោជន៍ប្រជាពលរដ្ឋ និងជាតិ។ វិសោធនកម្មនេះមិនមែនគ្រាន់តែជាការដកតំណែងតែបុគ្គលនោះឡើយ ប៉ុន្តែវាជាការលុបបំបាត់តួនាទីជាថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិចដែលទទួលស្គាល់ដោយច្បាប់។

គួរបញ្ជាក់ថា វិសោធនកម្មប្រការ ៤៨ថ្មី (ពីរ) ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ នៅបន្ទាប់ពីកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីនៅថ្ងៃទី២២ ខែ

កក្កដា ឆ្នាំ២០១៤ ក្នុងគោលបំណងដើម្បីឱ្យស្ថាប័ននេះអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធភាព ក្នុងនោះលើកកំពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ស្រប តាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនេះមានភារកិច្ចដឹកនាំតំណាងរាស្ត្រ របស់គណបក្ស ដើម្បីធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅស្របតាមកម្មវិធីនយោបាយ និងគោលការណ៍នានារបស់ គណបក្ស និងធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បី ធ្វើឱ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅដោយរលូន និងធានាបាននូវផលប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋ។ ដោយឡែកការបង្កើតប្រធានក្រុមភាគតិច គឺដើម្បីចូលរួមលើកកម្ពស់តួនាទីគណបក្សប្រឆាំង ឬគណបក្សនយោបាយក្រៅរដ្ឋា ភិបាល និងបង្កើតវប្បធម៌សន្ទនារវាងថ្នាក់ដឹកគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា។

## ៧. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ

- ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ គណៈកម្មការអចិន្ត្រៃយ៍សភាបើកកិច្ចប្រជុំពិភាក្សាស្តីពី៖
  - o ប្រជុំអនុម័ត លើសេចក្តីសម្រេចស្តីពី ការបង្កើតអ្នកនាំពាក្យរដ្ឋសភា
  - o បញ្ចូលរបៀបវារៈនៃសម័យប្រជុំរដ្ឋសភាលើកទី៥ ។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៣៖
  - o ការពិភាក្សានិងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។
  - o ការពិភាក្សានិងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ស្ថិតិ។
  - o ការពិភាក្សានិងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ទូរគនាគមន៍។
- ថ្ងៃទី០៩-១១ ខែធ្នូ ឆ្នាំ២០១៥ ពិធីបើកជាផ្លូវការនៃកិច្ចប្រជុំមហាសន្និបាតសភាតំបន់អាស៊ី (APA) លើកទី៨ ដែលសភានៃព្រះរាជាណាចក្រកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះរៀបចំនៃកិច្ចប្រជុំ។
- ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយឯកឧត្តម ស ខេង និងឯកឧត្តម កឹម សុខានៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំពិភាក្សាអំពីការពង្រឹង និងបន្តវប្បធម៌សន្ទនារវាងគណបក្សទាំងពីរជួបប្រជុំគ្នានៅវិមានរដ្ឋសភាជាតិ។ ជាលទ្ធផលនៃជំនួបគណបក្សទាំងពីរបានចេញសេចក្តីថ្លែងការណ៍រួមគ្នា ព្រមព្រៀងគ្នាចំនួន ៤ចំនុច៖១. បង្កើតគណៈកម្មការចំពោះកិច្ចដែលចូលរួមដោយគណបក្សទាំងពីរ ដើម្បីពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីសហជីព។ ២. គណបក្សទាំងពីរបានសន្យាថា នឹងខិតខំលើកតម្កើងវប្បធម៌សន្ទនា និងប្រសិទ្ធភាពការងាររបស់រដ្ឋសភា។ ៣. គណបក្សទាំងពីរបានឯកភាពថា ពង្រឹងរបៀបរបបការងារ និងទំនាក់ទំនងការងារ ព្រមទាំងការផ្តល់មធ្យោបាយសម្រាប់ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយក្នុងរដ្ឋសភា សំដៅរួមគ្នាលើកកម្ពស់ប្រសិទ្ធភាពនៃស្ថាប័នរដ្ឋសភា។ ៤. គណបក្សទាំងពីរ បានឯកភាពថា បន្តដោះស្រាយបញ្ហានានាដែលនៅសេសសល់ ដោយឈរលើស្មារតី បង្រួមបង្រួមជាតិ ផ្សះផ្សាជាតិ និងឯកភាពជាតិ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងនីតិរដ្ឋ។
- ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៣៖
  - o សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកដើម្បីបញ្ចូលកិច្ចព្រមព្រៀង ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ១កនៃកិច្ចព្រមព្រៀងម៉ារ៉ាកេស។
  - o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន។
  - o សេចក្តីព្រាងច្បាប់ ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។
- ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋសភាបានរៀបចំពិធីបំពាក់គ្រឿងឥស្សរយសលើកទី១ ជូនសមាជិកសមាជិការដ្ឋសភានីតិកាលទី៥។
- ថ្ងៃទី០៥-០៦ ខែមករា ឆ្នាំ២០១៦ សម្តេចហេង សំរិន ប្រធានរដ្ឋសភាកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាចូលរួមពិធីរំលឹកខួបទី៧០ នៃការបោះឆ្នោតសកលលើកដំបូង និងការបង្កើតរដ្ឋសភារបស់ប្រទេសវៀតណាមនៅទីក្រុងហាណូយ សាធារណរដ្ឋ

សង្គមនិយមវៀតណាម។

- ថ្ងៃទី០៤,១៤,១៩ ខែមករា ឆ្នាំ២០១៦ ក្រុមការងារចំពោះកិច្ចដឹកនាំដោយឯកឧត្តម ប៉ែន បញ្ញា និងឯកឧត្តម សុន ឆ័យ បានដឹកនាំកិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យ សិក្សា ផ្ដល់យោបល់ លើសេចក្ដីព្រាងច្បាប់ស្ដីពី សហជីព៖
    - ជំនួបលើកទី១ ថ្ងៃទី០៤ មករាឆ្នាំ២០១៦ ជាជំនួបលើកដំបូង ក្រុមការងារចំពោះកិច្ចបានសម្រេចលទ្ធផលចំនួន ២ចំណុច ក្នុងចំណោម ២១ចំណុច ដែលស្នើឡើងដោយសហជីព និងភាគីពាក់ព័ន្ធ។
    - ជំនួបលើកទី២ ថ្ងៃទី១៤ មករា ឆ្នាំ២០១៦៖ ជាលទ្ធផល ក្រុមការងារចំពោះកិច្ច បានសម្រេចលទ្ធផល ៧ចំណុច ហើយបូកទាំងកិច្ចប្រជុំលើកទី១ គឺក្រុមការងារចំពោះកិច្ចបានសម្រេចលទ្ធផលបាន ០៩ចំណុចក្នុងចំណោម ២១ចំនុច។
    - ជំនួបលើកទី៣ ថ្ងៃទី១៩ មករា ឆ្នាំ២០១៦៖ ជាលទ្ធផលក្រុមការងារចំពោះកិច្ច បានសម្រេចបញ្ចប់សំណើរដែលស្នើដោយភាគីពាក់ព័ន្ធ និងក្រុមការងារចំពោះកិច្ច គ្រោងនឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងច្បាប់នេះ នាពេលខាងមុខបន្ថែមទៀត។
- ថ្ងៃទី១៣-១៤ ខែមករា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៣៖
    - សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។
    - សេចក្ដីព្រាងច្បាប់ ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ២០១៥។
    - សេចក្ដីព្រាងច្បាប់ ស្ដីពីគណនេយ្យ និងសវនកម្ម។
- ថ្ងៃទី២៨ ដល់៣០ ខែមករា ឆ្នាំ២០១៦ សភាកម្ពុជា រៀបចំកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍សភានិយាយភាសាបារាំងនៅខេត្តសៀមរាប។
- ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ រដ្ឋសភា រៀបចំអបអរសាទរទិវានារីអន្តរជាតិលើកទី១០៥ ស្ដីពី «វិនិយោគលើសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍន៍ដោយចិរភាព» នៅវិមានរដ្ឋសភា។
- ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ រដ្ឋសភា រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី សហជីព នៅវិមានរដ្ឋសភា។
- ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការទី២នៃរដ្ឋសភា ចុះសិក្សាស្វែងយល់វិស័យការងារទាក់ទង នឹងការទទួលខុសត្រូវរបស់គណៈកម្មការក្នុងខេត្តស្វាយរៀង។
- ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ប្រធានរដ្ឋសភាជាតិ ដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាពនៅប្រទេសអូស្ត្រាលី។
- ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ គណៈកម្មការទី១នៃរដ្ឋសភា កោះអញ្ជើញឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការីមកឆ្លើយបំភ្លឺលើករណីមួយចំនួន៖
    - ដែលទាក់ទងដល់ការអនុវត្តច្បាប់របស់តុលាការ ក្នុងនោះមានការចាប់ ការឃុំខ្លួន និងការផ្ដន្ទាទោសអនីតិជន ការឃុំខ្លួនលើសនីតិវិធី កំណត់ កំហុសនៃការអនុវត្តនីតិវិធី និង
    - ការមិនអនុវត្តតួនាទីរបស់ចៅក្រម និងព្រះរាជអាជ្ញាជុំវិញករណីវិវាទដីធ្លី និងវិវាទផ្សេងទៀត និងឯករាជ្យភាពរបស់តុលាការ និងការជ្រៀតជ្រែក
- ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ រដ្ឋសភា រៀបចំពិធីប្រគល់ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍន៍ជូនសម្ដេច ហេង សំរិន ដោយសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ាន នៅវិមានរដ្ឋសភា។
- ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា បើកកិច្ចប្រជុំដើម្បីពិភាក្សា និងអនុម័តរបៀបវារៈមួយចំនួន និងកំណត់កាលបរិច្ឆេទបើកសម័យប្រជុំរដ្ឋភាលើកទី៦។
- ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សានិងអនុម័តលើរបៀបវារៈចំនួន ០៥៖
    - ព្រះរាជសារព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជូនសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៥។
    - របាយការណ៍ស្ដីពីសកម្មភាពរបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៥ និងលើកទី៦ នីតិកាលទី៥។

- o ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត លើសមាសភាពសមាជិករាជរដ្ឋាភិបាលដែលត្រូវកែសម្រួល និងបំពេញបន្ថែមចំនួន ២៦ រូប។
- o ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន ១រូប។
- o ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីសហជីព។

- ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ តំណាងកម្មកររោងចក្រកាត់ដេរ អ៊ែផ្សាយល៍ស្វេតចឺ(ខេមបូឌា) ខូអិលធីឌី ដែលមានទីតាំងស្ថិតនៅភូមិតាអោង សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ធ្វើដំណើរមកកាន់រដ្ឋសភាដើម្បីដាក់លិខិតសុំអន្តរាគមន៍ ជូនសម្តេចហេង សំរិន ជួយដោះស្រាយបញ្ហាចំនួន ០៩ ចំណុច។
- ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ លោកអ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាបត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅផ្ទះសំណាក់ខេត្តសៀមរាប និងបញ្ជូនខ្លួនទៅតុលាការក្រុងភ្នំពេញ។
- ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០១៖
  - o ការសម្រេចករណី ឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាបដែលក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់ចាប់ខ្លួន ឃុំខ្លួន។
- ថ្ងៃទី២០ ខែមេសាឆ្នាំ២០១៦ រដ្ឋសភាប្រកាសបិទសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៥។ ជាលទ្ធផលរយៈពេល ៣ខែនេះ រដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់ចំនួន ១២ សេចក្តីស្នើច្បាប់ចំនួន ១ សេចក្តីស្នើវិសោធនកម្ម ប្រការ ៣ថ្មី, ៧ថ្មី, ៨, ១០ថ្មី(ពីរ), ១៤ថ្មី,១៨ថ្មី, ២០,២១,២២ថ្មី,៣១ថ្មី(ពីរ), ៣៣ថ្មី, ៣៤, ៣៦ថ្មី,៣៨ថ្មី,៤០ថ្មី និងប្រការ៤៧ថ្មី(បី)នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។
- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៤៖
  - o ការសម្រេចករណី ឯកឧត្តម គឹម សុខា តំណាងរាស្ត្រមណ្ឌលកំពង់ចាម ដែលត្រូវក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់។
  - o ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
  - o សេចក្តីព្រាងច្បាប់ស្តីពី យុត្តិធម៌អនីតិជន ។
  - o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលហុងគ្រី ស្តីពីការជំរុញ និងការពារគ្នាទៅវិញទៅមក នៃវិនិយោគ។
- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០១៖
  - o ការឆ្លើយបំភ្លឺដោយផ្ទាល់មាត់ជូនរដ្ឋសភារបស់ឯកឧត្តម វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ រដ្ឋសភាបើកសិក្ខាសាលាដើម្បីស្វែងយល់ពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧នៅវិមានរដ្ឋសភាជាតិ។
- ថ្ងៃទី៣០ ខែមិនថុនា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៤៖
  - o សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។
  - o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។
  - o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ៖
    - ▪ កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។
    - ▪ ពិធីសារទី១ ស្តីពីការមិនកំណត់សិទ្ធិហោះហើរ ទី៣ និងទី៤ រវាងចំណុចណាមួយនៅក្នុងទឹកដីបណ្តាភាគីចុះកិច្ចព្រមព្រៀង។
    - ▪ ពិធីសារទី២ ស្តីពីសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង។
  - o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារវិសោនធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

- ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ អាជ្ញាធរសមត្ថកិច្ច បិទកំណាត់ផ្លូវជាតិលេខ២ ក្នុងសង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ ស្របពេលដែលគណបក្សសង្គ្រោះជាតិគ្រោងរៀបចំ ការហែដាក់ញត្តិទៅកាន់ស្ថានទូតចំនួន១៥ប្រទេស ជាប្រទេសហត្ថលេខានៃសន្ធិសញ្ញាទីក្រុងបារីសដើម្បីអោយជួយអន្តរាគមន៍ឲ្យរាជរដ្ឋាភិបាលគោរពសន្ធិសញ្ញាទីក្រុងបារីស។

- ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ តុលាការសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការជំនុំជម្រះ លើសំណុំរឿងក្តីឯកឧត្តម កឹម សុខា ពាក់ពន្ធ័ករណីបដិសេធមិនចូលខ្លួនបំភ្លឺជាសាក្សីក្នុងសំណុំរឿងពាក់ព័ន្ធនឹងអ្នកនាងខុម ចាន់ដារ៉ាទី (ហៅស្រីមុំ) នៅសាលាដំបូងរាជធានីភ្នំពេញ។

- ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦ រដ្ឋសភាបើកសម័យប្រជុំពេញអង្គពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៦៖
    - ព្រះរាជសារព្រះមហាក្សត្រ ជូនសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥
    - របាយការណ៍ ស្តីពីសកម្មភាពរបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៦ និងលើកទី៧ នីតិកាលទី៥
    - ការបោះឆ្នោតទុកចិត្តអគ្គសវនករ និងអគ្គសវនកររង០៣ នៃអជ្ញាធរសវនកម្មជាតិសម្រាប់បន្តអាណត្តិ៥ឆ្នាំ រួមមាន លោកជំទាវ សោម គឹមសួគ៌ ឯកឧត្តម សួន សិទ្ធី និងឯកឧត្តម អ៊ុក សារាវុធ។
    - សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល។
    - សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ស្តីពីប្រព័ន្ធឆ្លងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ។
    - សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវា។
    - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣
    - សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ ស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជាតែមួយអាស៊ាន។

- ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីទីស្នាក់ការរដ្ឋសភាមណ្ឌលរាជធានី-ខេត្តក្នុងការផ្តល់សេវាជូនតំណាងរាស្ត្រ និងប្រជាពលរដ្ឋ" នៅវិមានរដ្ឋសភា។

# ឧបសម្ព័ន្ធ

## ការចុះផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយ

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រនេះ ត្រូវបានចុះផ្សាយនៅក្នុងបណ្តាសារព័ត៌មានមួយចំនួន ដូចជាៈ សារព័ត៌មាន VOD, សារព័ត៌មាន FRESHNEWSASIA, សារព័ត៌មាន THMEYTHMEY, វិទ្យុអាស៊ីសេរី (RFA), វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) , វិទ្យុបារាំងអន្តរជាតិ (FRI) , សារព័ត៌មានភ្នំពេញប៉ុស្តិ៍, មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC), សារព័ត៌មាន KhmerTimes។

### អ្នកឃ្លាំមើលៈ ប្រសិទ្ធភាពរដ្ឋសភាធ្លាក់ចុះ តែការយាយីបក្សប្រឆាំងកើនឡើង

http://vodhotnews.com/21/02/2017/effective-congress-dropped-the-increasing-harassment-of-opposition/

ដោយ លោក ញឹម សុខន। ថ្ងៃអង្គារ ទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ម៉ោង 5:08 PM। សិទ្ធិមនុស្ស। 0। 2558

អង្គការឃ្លាំមើលការបោះឆ្នោតបង្ហាញថា មួយរយៈចុងក្រោយនេះ រដ្ឋសភាបានធ្លាក់ដៃក្នុងការពង្រឹងយន្តការប្រជាធិបតេយ្យបែបនីតិរដ្ឋ តែបង្កឲ្យមានការយាយីកាន់តែខ្លាំងទៅលើសិទ្ធិធ្វើនយោបាយរបស់បក្សប្រឆាំង ហើយថាបានប៉ះពាល់ដល់ការអនុវត្តគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស។

ក្នុងកិច្ចពិភាក្សាស្តីពីរបាយការណ៍អង្កេតរដ្ឋសភានិងតំណាងរាស្ត្រឆ្នាំទី៣ នីតិកាលទី៥ ដែលធ្វើឡើងនាថ្ងៃទី២១ កុម្ភៈនេះ នាយកប្រតិបត្តិអង្គការ ខុមហ្វែល លោក គល់ បញ្ញា បានលើកឡើងថា តាមរបាយការណ៍អង្កេតពីដំណើរការសភាសម្រាប់ឆ្នាំ២០១៦រកឃើញថា ប្រសិទ្ធភាពការងារសភាបានធ្លាក់ចុះ។

លោក គល់ បញ្ញា ឲ្យដឹងទៀតថា ការធ្លាក់ចុះនោះ ដោយសារតែក្រុមមតិភាគច្រើនដែលកាន់អំណាច បានបំពាបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្របក្សប្រឆាំង ការលុបចោលតំណែងប្រធានក្រុមមតិភាគតិចក្នុងសភា បើកផ្លូវឲ្យអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនតំណាងរាស្ត្រទាំងមានអភ័យឯកសិទ្ធិ ការដកតំណែងលោក កឹម សុខា ចេញពីអនុប្រធានទី១នៃរដ្ឋសភា ការប្រើហិង្សាវាយតំណាងរាស្ត្របក្សប្រឆាំង និងការដំឡើងឋានៈ ដល់អ្នកវាយតំណាងរាស្ត្រជាដើម។

បើតាមកលោក គល់ បញ្ញា ការបាត់បង់អំណាចរបស់តំណាងរាស្ត្របក្សប្រឆាំង រួមទាំងវិវាទនយោបាយចុងក្រោយដែលឈានទៅប្រើហិង្សាលើអ្នកតំណាងរាស្ត្រ ការប្រើប្រាស់ច្បាប់ និងការកែបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីបង្ក្រាបនិងដកសិទ្ធិតំណាងរាស្ត្របក្សប្រឆាំង លោកថាបាននាំមកនូវការធ្លាក់ចុះប្រសិទ្ធភាពរបស់រដ្ឋសភា និងការទាញទម្លាក់ការអនុវត្តគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុកបក្ស និងនីតិរដ្ឋនៅកម្ពុជា។

លោកថា៖ «*កន្លងមកមានការផ្លាស់ប្តូរបទបញ្ជាផ្ទៃក្នុងបង្កើនតួនាទីរបស់បក្សប្រឆាំង ដូចជាមានប្រធានក្រុមតិភាគចិត ដូចជាមានថ្នាក់ដឹកនាំ របស់រដ្ឋសភា [លោក កឹម សុខា អនុប្រធានទី១នៃរដ្ឋសភា]ចែកអំណាច បក្សប្រឆាំងទៅលើគណៈកម្មការបច្ចេកទេសរដ្ឋសភាមួយចំនួនហ្នឹង ធ្វើឲ្យសកម្មភាពបច្ចេកទេសនៃរដ្ឋសភាហ្នឹងមានសកម្មខ្លាំង បើ*

*ធៀបទៅនឹងដំណើរការរដ្ឋសភាពីអាណត្តិមុន។ អានេះដែលយើងមើលឃើញ។ ប៉ុន្តែដល់ពេលចាប់ផ្ដើមដក មិនទទួលស្គាល់តួនាទីហ្នឹង សភាមានសកម្មភាពធ្លាក់ចុះ*»។

អ្នកនាំពាក្យរដ្ឋសភា លោក ឡេង ប៉េងឡុង បានច្រានចោលរបាយការណ៍នេះនិងបានចាត់ទុកថា ជារបាយការណ៍លំអៀង ដោយលោកអះអាងថាការដែលតំណាងរាស្ត្របក្សកាន់អំណាចដែលមានមានសំឡេងភាគច្រើន អនុម័តច្បាប់គ្មានការចូលរួមពីតំណាងរាស្ត្របក្សប្រឆាំង លោកថាបក្សប្រឆាំងខ្លួនឯងធ្វើពហិកា ដែលលោកថាដើម្បីកេងចំណេញនយោបាយ។

លោក ឡេង ប៉េងឡុង លើកឡើងថា ដើម្បីឲ្យសភាធ្វើការមូលមាត់គ្នា មានតែតំណាងរាស្ត្របក្សប្រឆាំង ឈប់ធ្វើពហិកា វិលចូលធ្វើការក្នុងសភាវិញ ហើយបង្កើនវប្បធម៌ជជែកគ្នា។

លោកថា៖ «*គណបក្សកាន់អំណាចដូចអត់មានគំរាមកំហែងស្អីសោះ គាត់ចូលមកគ្មាននរណាធ្វើស្អី ដល់គាត់ គាត់ថា មិនចូលមកទេ មានគេគំរាមកំហែង វាអត់មាននរណាគំរាមកំហែងអីទេ បើខុមប្រែលនិយាយអញ្ចឹង មានន័យថាគាត់លំអៀងទៅរកបក្សប្រឆាំងហើយ*»។

សមាជិកសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត លោកមេធាវី សុក សំអឿន លើកឡើងដែរថា បើពិនិត្យពីប្រព័ន្ធបោះឆ្នោតនៅកម្ពុជា លោកថាគេពិបាកជឿថាតំណាងរាស្ត្រធ្វើការដោយមិនគិតផលប្រយោជន៍បក្ស ដោយថាការបោះឆ្នោតជាសមាមាត្រ បានផ្ដល់អំណាចខ្លាំងឲ្យមេដឹកនាំនយោបាយជាអ្នកចាត់តាំងបេក្ខភាពតំណាងរាស្ត្រ ឲ្យទៅអង្គុយកៅអីក្នុងរដ្ឋសភា។

លោក សុក សំអឿន លើកឡើងថា រដ្ឋសភាគួរធ្វើបទបញ្ជាផ្ទៃក្នុងដោយចែងថា កិច្ចប្រជុំសភាត្រូវមានពហុបក្សទើបអាចប្រជុំបាន ហើយការអនុម័តច្បាប់ត្រូវមានសំឡេងភាគតិចចូលរួម ទើបអនុម័តច្បាប់បាន នោះលោកថា ជាប្រសើរ។ ប៉ុន្តែមិនធ្វើចែងដូចនេះទេ លោកថាអ្នកនយោបាយនឹងនូវតែយករដ្ឋធម្មនុញ្ញធ្វើជារនាំងសម្រាប់ប្រយោជន៍បក្ខពួកដដែល។

លោកថា៖ «*បើសិនជាអត់មានកំនត់ច្បាស់លាស់ទេ និយមន័យក្នុងរដ្ឋធម្មនុញ្ញ គ្រាន់តែជាពាក្យលំអរតែអត់មានន័យអត់មានខ្លឹមសារអីទាំងអស់ ហើយនឹងអាចធ្វើឲ្យអ្នកនយោបាយហ្នឹងគាត់ បំពានបន្តិចម្ដងៗៗអញ្ចឹងទៅ ធ្វើឲ្យនិយមន័យរដ្ឋធម្មនុញ្ញហ្នឹងអត់មានន័យអីទេ*»។

បើតាមរបាយការណ៍ ការធ្លាក់ចុះនៃប្រសិទ្ធភាពរបស់សភានេះទាំងការអនុម័តច្បាប់បែបពហុបក្ស ទាំងការឡើងសម្ដែងមតិក្នុងសភារបស់តំណាងរាស្ត្រ និងសកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភា បានធ្លាក់ចុះដូចគ្នានៅឆ្នាំ២០១៦នេះ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដូចជារបៀវារៈចំនួន៣២ ក្នុងឆ្នាំ២០១៦នេះ មាន២១ហើយដែលត្រូវតំណាងរាស្ត្របក្សកាន់អំណាច អនុម័តដោយឯកបក្ស។

របាយការណ៍ដដែលឲ្យដឹងថា តំណាងរាស្ត្រ១២៣រូប មានតែ១៨រូបប៉ុណ្ណោះដែល បានឡើងបញ្ចេញមតិយោបល់ក្នុងសភា ក្រៅពីនោះបន្តនៅស្ងាត់ស្ងៀម។ ចំនួននេះបានថយចុះបើប្រៀបធៀបនឹងឆ្នាំ២០១៥។

ចំណែកគណៈកម្មការជំនាញវិញ របាយការណ៍បង្ហាញថា ក្នុងឆ្នាំ២០១៦ បានកោះហៅមន្ត្រីរដ្ឋាភិបាលតែម្នាក់ប៉ុណ្ណោះមកសាកសួរគឺ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ដោយឡែកការចុះមូលដ្ឋានវិញ ខុមហ្វ្រែល រកឃើញថាតំណាងរាស្ត្របក្សប្រឆាំងបានចុះច្រើនជាងបក្សកាន់អំណាច តែថាបក្សប្រឆាំងបានចុះពង្រឹងសមត្ថភាពរបស់សកម្មជនរបស់ខ្លួន ខណៈបក្សកាន់អំណាចនិយាយពីការចែកអំណោយ៕

## អ្នកនាំពាក្យ៖ ការចុះមូលដ្ឋានរបស់ក្រុមតំណាងរាស្ត្រ គណបក្សកាន់អំណាច មិនចាំបាច់រាយការណ៍ជូន COMFREL

http://www.freshnewsasia.com/index.php/en/localnews/47769-comfrel.html

(ភ្នំពេញ) ៖ លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានចាត់ទុកថា របាយការណ៍របស់អង្គការ COMFREL បានផ្ដល់ភាពអយុត្តិធម៌ ដល់គណបក្សប្រជាជនកម្ពុជា ហើយមានលក្ខណៈលម្អៀង ទៅរកគណបក្សប្រឆាំង។ ទន្ទឹមនឹងគ្នានេះ លោកបានអះអាងថា រាល់ការចុះមូលដ្ឋានរបស់ក្រុមតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា មិនចាំបាច់រាយការណ៍ជូនអង្គការ នេះឡើយ។

ប្រតិកម្មរបស់អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានធ្វើឡើងបន្ទាប់ពីគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) បានចេញរបាយការណ៍មួយ កាលពីម្សិលមិញ ដោយប្រកាសថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចុះទៅកាន់មូលដ្ឋានជួបពលរដ្ឋតិចតួចជាង តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។

អង្គការខុមហ្វ្រែល បានអះអាងថា តំណាងរាស្ត្របក្សប្រឆាំងចំនួន៤៥រូប ចុះមូលដ្ឋានបានច្រើនជាងគេរហូតដល់ជាង ១ពាន់ដង បើធៀបនឹងតំណាងរាស្ត្រមកពីបក្សកាន់អំណាចចំនួន ៥៦រូប ចុះបានត្រឹមតែជាង ៦០០ដងប៉ុណ្ណោះ។

លោក សុខ ឥសាន បានលើកឡើងថា ការវាយតម្លៃរបស់អង្គការ COMFREL នេះ វាមិនយុត្តិធម៌ទេ ហើយការធ្វើការរបស់តំណាង រាស្ត្រគណបក្សមិនមែនដើម្បីរាយការណ៍ ទៅអង្គការខុមហ្វ្រែលឲ្យជ្រាបនោះដែរ ហើយក៏មិនមែនធ្វើតម្រូវចិត្តរបស់អង្គការខុមហ្វ្រែល នោះដែរ។ លោកលើកឡើងយ៉ាងដូច្នេះថា «ការចុះទៅនេះដើម្បីសួរសុខទុកប្រជាពលរដ្ឋនៅមូលដ្ឋាន និងដើម្បីដោះស្រាយរាល់បញ្ហា ដែលជួបប្រទះនៅមូលដ្ឋាន ត្រង់គាត់ដឹងឬមិនដឹង យើងមិនដឹងទេ»។

ដោយឡែកទាក់ទងនឹងការលើកឡើងថា បក្សកាន់អំណាចបានបំពានអភ័យឯកសិទ្ធិ និងបន្ថយតួនាទីរបស់តំណាងរាស្ត្រ គណបក្សប្រឆាំងនោះ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានលើកឡើងថា ការចាប់ខ្លួនតំណាងរាស្ត្របក្សប្រឆាំងនោះ មិនមែនរំលោភលើរដ្ឋធម្មនុញ្ញ ឬអភ័យឯកសិទ្ធិនោះទេ ប៉ុន្តែគឺជាបទល្មើសជាក់ស្ដែង។ លោកបញ្ជាក់ថា អភ័យឯកសិទ្ធិមិនអាច ការពារតំណាងរាស្ត្រដែលប្រព្រឹត្តបទល្មើសជាក់ស្ដែងនោះទេ៕

## របាយការណ៍ខុមហ្វ្រែល បង្ហាញថា CPP អនុម័តច្បាប់ឯកបក្សច្រើន ដោយគ្មានការចូលរួមពី CNRP

21, Feb 2017 , 10:39 pm 1913

https://thmeythmey.com/?page=detail&id=49767

ដោយ: ធឿន បញ្ញាឫទ្ធិ

**ភ្នំពេញ៖ អង្គការឃ្លាំមើលការបោះឆ្នោត ហៅកាត់ថា ខុមហ្វ្រែល បានបង្ហាញរបាយការណ៍ថា សកម្មភាពរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជានៅក្នុងរដ្ឋសភា បានអនុម័តច្បាប់ឯកបក្សច្រើន ដោយមិនមានការចូលរួមសម្រេចនិងផ្តល់យោបល់ពីខាងគណបក្សសង្គ្រោះជាតិ។ គណបក្សប្រជាជន ថា ការអនុម័តច្បាប់ឯកបក្សនេះ គឺអនុវត្តត្រឹមត្រូវតាមច្បាប់ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។**

របាយការណ៍សង្កេតនយោបាយ ដែលខុមហ្វ្រែលបានចេញផ្សាយនៅថ្ងៃទី២១ កុម្ភៈនេះ បានឲ្យដឹងថា ក្នុងសម័យប្រជុំវិសាមញ្ញចំនួន៣លើកក្នុងឆ្នាំ២០១៦នោះ គណបក្សកាន់អំណាច បានសម្រេចអនុម័តលើសេចក្តីព្រាងច្បាប់ និងរបៀបវារៈ ចំនួន៣២ ដោយមិនបានការចូលពិភាក្សាជាមួយគណបក្សប្រឆាំងឡើយ។ ចំពោះរបៀបវារៈទាំង៣២ ដែលគណបក្សកាន់អំណាចអនុម័តដោយសំឡេងឯកបក្សនោះរួមមាន៖ សេចក្តីព្រាងច្បាប់ចំនួន១៦,ការបោះឆ្នោតជ្រើសតាំងចំនួន២លើក , ការអនុម័តសេចក្តីសម្រេចចំនួន២លើក និងការឆ្លើយបំភ្លឺចំនួន១លើក។ ចំណែកខ្លឹមសារច្បាប់ចំនួន១១ទៀត ក៏ត្រូវបានគណបក្សកាន់អំណាច អនុម័តដោយមិនមានការសួរដេញដោលខ្លឹមសារច្បាប់ពីខាងតំណាងរាស្ត្រគណបក្សប្រឆាំងដែរ។ ជាក់ស្តែងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលគណបក្សប្រជាជន ទើបតែអនុម័តកាលពីថ្ងៃទី២០ កុម្ភៈនេះ។

ត្រង់ចំណុចនេះអង្គការខុមហ្វ្រែល សង្កេតឃើញថា មូលហេតុដែលមានការអនុម័តសេចក្តីព្រាងច្បាប់នានា ដែលមិនមានការពិភាក្សាសួរដេញដោលផុសផុល ដូចនៅពេលមានការចូលរួមប្រជុំពីគណបក្សសង្គ្រោះជាតិនោះឡើយ ពោលគឺបន្ទាប់ពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ពហិការក្នុងកិច្ចប្រជុំរដ្ឋសភា នៅពាក់កណ្តាលឆ្នាំ២០១៦មក ។ បើតាមខុមហ្វ្រែល ការពហិការរបស់គណបក្សប្រឆាំងនេះ ដោយសារតែគណបក្សកាន់អំណាច បានទម្លាក់អំណាចរដ្ឋសភា ហើយបានបំពានដកអភ័យឯកសិទ្ធិ និងបើកផ្លូវឲ្យអាជ្ញាធរចោទប្រកាន់ ចាប់ខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំងជាដើម។

ឆ្លើយតបនឹងរបាយការណ៍នេះ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាលោក សុខ ឥសាន បាននិយាយថា រដ្ឋសភាគឺអនុវត្តតាមច្បាប់ប៉ុណ្ណោះ ក្នុងការដកអភ័យឯកសិទ្ធិ និងចាប់ខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំងនេះ ព្រោះពួកគេទាំងនោះប្រព្រឹត្តខុសច្បាប់ខ្លួនឯង ដែលមិនអាចលើកលែងទោសឲ្យបានឡើយ។ងាកមកការអនុម័តច្បាប់ដោយឯកបក្សនោះវិញ លោក សុខ ឥសាន បានបកស្រាយយ៉ាងដូច្នេះថា៖«យើងមិនបានបិទសិទ្ធិគណបក្សប្រឆាំងមិនឲ្យចូលរួមអនុម័តនោះទេ ប៉ុន្តែគណបក្សប្រឆាំងទេដែលតែងតែយកវប្បធម៌ពហិការមិនចូលប្រជុំសភា ឬសិក្ខាសាលាសភាដោយខ្លួនឯង។ សូម្បីតែប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំសភាពេញអង្គ ព្រោះបើពួកគាត់គ្រាន់តែចូលមកប្រជុំ បើទោះជាពួកគាត់មិនលើកដៃអនុម័ត ក៏គ្មានអ្នកណាទៅបង្ខំឲ្យលើកដៃដែរ។ ដូច្នេះគណបក្សយើងអនុម័តច្បាប់ដោយខ្លួនឯងនេះ អត់ខុសច្បាប់ និងខុសបទបញ្ជាផ្ទៃក្នុងរដ្ឋសភាទេ»។

តែយ៉ាងណាគណបក្សសង្គ្រោះជាតិ ធ្លាប់បានអះអាងថា ខ្លួនមិនមែនធ្វើពហិកា និងបោះបង់ចោលភារកិច្ចខ្លួនក្នុងរដ្ឋសភានោះទេ។ គណបក្សសង្គ្រោះជាតិ បានបញ្ជាក់ដូច្នេះថា«គណបក្សនៅតែបន្តការងារក្នុងតួនាទីជាសមាជិករដ្ឋសភាជាធម្មតា ហើយនឹងសម្រួលចូលរួមកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា និងអនុម័តលើករណីណាដែលមានការសម្រេចមិនប៉ះពាល់ដល់ផលប្រយោជន៍ជាតិ ពលរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ»។

ប៉ុន្តែការលើកឡើងរបស់គណបក្សសង្គ្រោះជាតិនេះ ត្រូវបានលោក សុខ ឥសាន តបវិញដូច្នេះថា៖«គ្មានការងារណាដែលគណបក្សប្រជាជនធ្វើហើយគ្មានប្រយោជន៍នោះទេ ហើយច្បាប់ទាំងនោះគឺសុទ្ធតែមានប្រយោជន៍ដល់ប្រជាពលរដ្ឋ និងប្រទេសជាតិ»។

ប៉ុន្តែសម្រាប់អ្នកវិភាគវិញ ការអនុម័តច្បាប់មានតែសមាជិកគណបក្សកាន់អំណាចក្នុងរដ្ឋសភា តែឯកបក្សនោះ វាអាចធ្វើឲ្យច្បាប់ទាំងនោះមិនសូវមានប្រសិទ្ធិភាព ក្នុងការបម្រើផលប្រយោជន៍ដល់ប្រជាជនឡើយ។ អ្នកវិភាគ ស្នើឲ្យអ្នកនយោបាយទាំងនោះ គប្បីរកដំណោះស្រាយរៀបចំច្បាប់ណា ដែលបម្រើផលប្រយោជន៍ជូនពលរដ្ឋ និងប្រទេសជាតិ ល្អជាងការបង្កើតច្បាប់បម្រើផលប្រយោជន៍បក្សខ្លួន ដើម្បីយកឈ្នះគ្នាទៅវិញទៅមក ស្របពេលដែលការបោះឆ្នោតខិតជិតមកដល់នាពេលខាងមុខនេះឡើយ៕

## ខុមហ្វ្រែលរកឃើញថាប្រសិទ្ធភាពការងាររដ្ឋសភាធ្លាក់ចុះក្នុងឆ្នាំ២០១៦

ដោយ ម៉ម មុនីរតន៍

2017-02-21

http://www.rfa.org/khmer/news/politics/Comfrel-found-down-effectiveness-of-NA-02212017043823.html

RFA/Morm Moniroth

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (COMFREL) រកឃើញថា នៅក្នុងឆ្នាំ២០១៦ កន្លងទៅនេះ សកម្មភាពការងារនានារបស់រដ្ឋសភា ត្រូវបានអ្នកជំនាញលើកិច្ចការបោះឆ្នោតចាត់ទុកថា បានធ្លាក់ចុះប្រសិទ្ធភាព។ ការធ្លាក់ចុះនូវអព្យាក្រឹតភាពនៃរដ្ឋសភានេះ ត្រូវបានអ្នកជំនាញយល់ឃើញថា កំពុងធ្វើឲ្យប្រជាធិបតេយ្យដែលបានដុះពន្លកនេះ ត្រូវធាក់ថយទៅក្រោយវិញ ដែលបញ្ហានេះនឹងជះឥទ្ធិពលកាន់តែអាក្រក់ទៅលើការគោរពសិទ្ធិមនុស្ស។

ការប្រឈមដែលក្រុមអ្នកឃ្លាំមើលដំណើរការនៃរដ្ឋសភា ចាត់ទុកថា កំពុងតែវិវឌ្ឍន៍ទៅរកភាពជុនដាបនៃប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពនៃការបញ្ចេញមតិនេះ ស្របពេលរដ្ឋសភាអនុម័តច្បាប់ស្ដីពីគណបក្សនយោបាយដោយឯកបក្សមួយជាន់បន្ថែមទៀត ទៅតាមការចង់បានរបស់លោក ហ៊ុន សែន។

លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល ឲ្យដឹងនៅព្រឹកថ្ងៃទី២១ កុម្ភៈ ថា រដ្ឋសភាបានបាត់បង់ប្រសិទ្ធភាពការងារនៅក្នុងឆ្នាំទី៣ នៃនីតិកាលទី៥ នេះ។ លោកបន្តថា ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ រដ្ឋសភាធ្វើកិច្ចការរបស់ខ្លួនបានតិចតួចប៉ុណ្ណោះ។ លោកបន្តថា *«នៅក្នុងឆ្នាំនេះឆ្នាំទី៣ នេះ ឆ្នាំ២០១៦ កន្លងទៅនេះ ប្រសិទ្ធភាព*

*របស់រដ្ឋសភានឹងធ្លាក់ចុះ ឬក៏ត្រូវបានគេធ្វើឲ្យធ្លាក់ចុះ។ ប្រសិទ្ធភាពរដ្ឋសភាធ្លាក់ចុះហ្នឹង យើងសំដៅទៅលើស្ថានការណ៍មួយចំនួន ជាពិសេសប៉ះពាល់ទៅលើការបំពារបំពានអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រ*»។

របាយការណ៍សង្ខេបដែលនិយាយអំពីការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រឆ្នាំទី៣ នៃនីតិកាលទី៥ ដែលគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា រកឃើញ បានសរសេរថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានទម្លាក់ ជាពិសេសក្រុមមតិភាគច្រើនដែលកាន់កាប់អំណាច បានបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្របក្សប្រឆាំង និងបានបន្ថយតួនាទីបក្សប្រឆាំងនៅក្នុងសភា។ លើសពីនេះ បានលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិចនៅក្នុងសភា។

មិនត្រឹមតែប៉ុណ្ណោះ អង្គការខុមហ្វ្រែល រកឃើញទៀតថា តំណាងរាស្ត្របក្សកាន់អំណាចបានបើកផ្លូវឲ្យអាជ្ញាធរចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្របក្សប្រឆាំងថែមទៀតផង។ ផ្ទុយទៅវិញ បែរជាមានការលើកទឹកចិត្ត និងដំឡើងឋានន្តរស័ក្តិដល់មន្ត្រីយោធា និងកងអង្គរក្សរបស់លោក ហ៊ុន សែន ដែលចេះវាយតប់ប្រឆាំងតំណាងរាស្ត្រក្រុមមតិភាគតិចទៅវិញ ជាដើម។

ក្រៅពីនេះវិញ គណៈកម្មការជំនាញទាំង១០ របស់រដ្ឋសភា នៅក្នុងឆ្នាំ២០១៦ គឺធ្វើការបានតិចតួច បើធៀបក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៥។ តួលេខសរុបដែលគណៈកម្មការសភាធ្វើការឆ្នាំ២០១៦ មានចំនួន ៦០លើក បើធៀបឆ្នាំ២០១៥ វិញ សកម្មភាពការងារមានរហូតដល់ ១០៥លើក ក្នុងនោះគណៈកម្មការជំនាញដឹកនាំដោយបក្សប្រឆាំង ធ្វើសកម្មភាពចំនួន ៣១លើក បើធៀបនឹងគណៈកម្មការជំនាញដែលដឹកនាំបក្សកាន់អំណាចបានចំនួន ២៩ លើក។

លោក សុក សំអឿន ប្រធានការិយាល័យមេធាវីក្រុមអ្នកច្បាប់អមរិន្ទ្រ យល់ឃើញថា មូលហេតុខ្លះដែលនាំឲ្យកម្ពុជាចេះតែមានបញ្ហាមិនចប់ពីមួយអាណត្តិទៅមួយអាណត្តិ គឺអាចដោយសារប្រព័ន្ធនៃការបោះឆ្នោតជាប្រព័ន្ធសមាមាត្រ ហើយគិតមធ្យមភាគជាធំ។ ក្រៅពីនេះ ការកំណត់និយមន័យច្បាប់មិនបានច្បាស់លាស់ ជាមូលហេតុធ្វើឲ្យអ្នកបកស្រាយច្បាប់ម្ខាងទៀតចេះតែមានឱកាសយកប្រៀបលើភាគីម្ខាងទៀត។ លោកបន្តថា «*ការអស់សង្ឃឹមមួយទៀត គឺប្រព័ន្ធតុលាការយើងតាំងពីក្រុមប្រឹក្សាធម្មនុញ្ញ និងទាំងតុលាការ បើយើងនិយាយពីក្រុមប្រឹក្សាធម្មនុញ្ញមិនដែលបដិសេធថាអ្វីណាមួយហ្នឹង គឺវាឥតមានរដ្ឋធម្មនុញ្ញ ឬក៏ផ្ទុយរដ្ឋធម្មនុញ្ញអីឥតមានទេ។ រាល់ពេលរដ្ឋាភិបាលស្នើសុំ គឺស្របៗ*»។

ទាក់ទងនឹងការចុះមូលដ្ឋានរបស់ក្រុមតំណាងរាស្ត្រនៅក្នុងនីតិកាលទី៥ នេះវិញ អង្គការខុមហ្វ្រែល រកឃើញថា គឺជាចំនួនដែលចុះច្រើនបំផុតពុំធ្លាប់មាន។ តំណាងរាស្ត្របក្សប្រឆាំងចំនួន ៤៥រូប ចុះមូលដ្ឋានបានច្រើនជាងគេរហូតដល់ជាង ១ពាន់ដង បើធៀបនឹងតំណាងរាស្ត្រមកពីបក្សកាន់អំណាចចំនួន ៥៦រូប ចុះបានជាង ៦០០ដង។ ប៉ុន្តែអ្នកវិភាគមើលឃើញថា ការចុះមូលដ្ឋានភាគច្រើនរបស់ក្រុមតំណាងរាស្ត្រ គឺចុះពង្រឹងបក្ស និងសកម្មជនច្រើនជាងប្រមូលបញ្ហានៅក្នុងសហគមន៍មកដោះស្រាយ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកវិភាគឯករាជ្យ មានប្រសាសន៍ថា ការប្រឈមមិនចេះចប់ដល់សព្វថ្ងៃនេះ ព្រោះតែកម្អែលនៃមរតកកុម្មុយនិស្ត។ មិនតែប៉ុណ្ណោះ ច្បាប់កុម្មុយនិស្ត គឺជាឧបករណ៍អំណាចដ៏មានប្រសិទ្ធភាពក្នុងការ

កម្ចាត់គូប្រកួតរបស់ខ្លួន។ លោកបន្តថា «*យើងនេះគឺយ៉ាងម៉េច? យើងនេះប្រកាន់បក្ខពួកហ្នឹងខ្លាំងណាស់ ហើយមិនត្រឹមតែប្រកាន់បក្ខពួកប៉ុណ្ណឹងទេ នេះគឺជាមរតកប្រព័ន្ធកុម្មុយនិស្ត ហើយជាពិសេសប្រព័ន្ធច្បាប់កុម្មុយនិស្ត*»។

អាស៊ីសេរី ពុំអាចទាក់ទងអ្នកនាំពាក្យនៃរដ្ឋសភា ដើម្បីបំភ្លឺបន្ថែមជុំវិញរឿងនេះបានទេ នៅថ្ងៃទី២១ កុម្ភៈ។

បើទោះជាបែបណា ក្រុមអ្នកវិភាគឲ្យដឹងថា ប្រទេសដែលអនុវត្តរបបប្រជាធិបតេយ្យ សេរី ពហុបក្ស ពិតប្រាកដ គឺបារម្ភបំផុតចំពោះការអនុវត្តច្បាប់មិនបានត្រឹមត្រូវ ហើយត្រូវរងការរិះគន់ ព្រោះការរំលោភច្បាប់នេះវានឹងធ្វើឲ្យប៉ះពាល់ទៅដល់សន្លឹកឆ្នោត៕

### របាយការណ៍ Comfrel រកឃើញការធ្លាក់ចុះនៃប្រសិទ្ធភាពការងាររបស់រដ្ឋសភា

21 កុម្ភៈ 2017

http://khmer.voanews.com/a/comfrel-report-found-a-drop-in-parliament-work-efficiency/3733443.html

ហ៊ុល រស្មី

របាយការណ៍របស់អង្គការ ខុមហ្វ្រែល ត្រូវបានចេញផ្សាយ នៅចំពេលដែលស្ថានការណ៍នយោបាយក្នុងប្រទេសកម្ពុជា កំពុងស្ថិតក្នុងភាពតានតឹង ក្រោយសភាជាតិខ្មែរដែលមានតែតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា អនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។

ភ្នំពេញ —

ក្រុមអ្នកតំណាងរាស្ត្រនៅក្នុងរដ្ឋសភា ពុំសូវមានភាពសកម្មក្នុងកិច្ចការជំនាញរបស់ខ្លួន ក៏ដូចជាការជជែកដេញដោលអំពីសេចក្តីព្រាងច្បាប់នានា នៅពេលមានការរំលោភលើសិទ្ធិ និងតួនាទីជាច្រើនរបស់អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង ដែលធ្វើឡើងដោយក្រុមមតិភាគច្រើនដែលកាន់អំណាច។

នេះបើយោងតាមរបាយការណ៍របស់ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា អង្គការខុមហ្វ្រែល (Comfrel) ។

របាយការណ៍របស់អង្គការ ខុមហ្វ្រែល ត្រូវបានចេញផ្សាយ នៅចំពេលដែលស្ថានការណ៍នយោបាយក្នុងប្រទេសកម្ពុជា កំពុងស្ថិតក្នុងភាពតានតឹង ក្រោយសភាជាតិខ្មែរដែលមានតែតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា អនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។

ក្រុមអង្គការសិទ្ធិមនុស្សក្នុងស្រុក និងក្រៅប្រទេស បានចេញសេចក្តីថ្លែងការណ៍ ជាបន្តបន្ទាប់គ្នា រិះគន់ខ្លាំងៗចំពោះការអនុម័ត សេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលនឹងផ្តល់សិទ្ធិអំណាចដល់រដ្ឋាភិបាល និងស្ថាប័នតុលាការ ក្នុងការរឹតបន្តឹងសកម្មភាពនិងរំលាយចោល គណបក្សនយោបាយ ហើយថា ការអនុម័តនេះ ជាប្រផ្នូលមួយនៃការស្លាប់របស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

យោងតាមរបាយការណ៍សង្កេតរដ្ឋសភាក្នុងឆ្នាំ ២០១៦ របស់អង្គការខុមហ្វ្រែល បានឲ្យដឹងថា ក្រុមមតិភាគច្រើន ដែលកាន់អំណាច បានបំពារបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រគណបក្សប្រឆាំង និងបន្ថយតួនាទី របស់តំណាងរាស្ត្រគណបក្សប្រឆាំង ព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិចនៃ គណបក្សប្រឆាំងទៀតផង។

របាយការណ៍របស់អង្គការខុមហ្វ្រែល បានបន្តថា តំណាងរាស្ត្រគណបក្សកាន់អំណាចនៃរដ្ឋសភា បានបើកផ្លូវឲ្យ អាជ្ញាធរ មានសមត្ថកិច្ច ធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំង។

របាយការណ៍បញ្ជាក់បន្តថា៖«មានការលើកទឹកចិត្ត ដំឡើងឋានន្តរសក្តិដល់អ្នកដៃដល់ដែលជាមន្ត្រីនៃកងកម្លាំង ប្រដាប់អាវុធ កងអង្គរក្ស ដែលបានប្រើអំពើហិង្សាប្រឆាំងតំណាងរាស្ត្រគណបក្សមតិភាគតិច»។

នៅក្នុងឆ្នាំ២០១៥ សមាជិករដ្ឋសភាមកពីគណបក្សប្រឆាំងពីររូប ត្រូវបានអ្នកគាំទ្រគណបក្សកាន់អំណាចវាយយ៉ាង ដំណំនៅមុខរដ្ឋសភាជាតិ។

នៅក្នុងឆ្នាំ២០១៦ អ្នកវាយសមាជិកសភាគណបក្សប្រឆាំងទាំងនោះដែលគេស្គាល់ថាជាកងអង្គរក្សលោកនាយករដ្ឋ មន្ត្រី ហ៊ុន សែន ត្រូវបានក្រសួងការពារជាតិដំឡើងដំណែង។

លោក គល់ បញ្ញា នាយកប្រតិបត្តិរបស់អង្គការ ខុមហ្វ្រែល ថ្លែងក្នុងពិធីបង្ហាញរបាយការណ៍សង្កេតសភាក្នុងឆ្នាំ ២០១៦ ដែលធ្វើឡើងនៅក្នុងរាជធានីភ្នំពេញថា ក្រុមតំណាងរាស្ត្រនៃគណបក្សធំៗពីរនៅក្នុងសភា ពុំសូវជជែកគ្នាផុ លផុស ក្នុងពេលពិនិត្យលើសេចក្តីព្រាងច្បាប់នានានោះទេ។

«បុគ្គលអ្នកតំណាងរាស្ត្រមួយៗ ជាការពិត ភាគច្រើន គាត់ដើរតាម គឺថាបក្សមានជំហរអីទៅលើសេចក្តីព្រាងច្បាប់ ហ្នឹង គាត់យកតាមជំហរហ្នឹងហើយ។ អញ្ចឹងហើយ យើងឃើញចំនួន ១២៣ ក៏ប៉ុន្តែពេល ពេលដាក់ស្តែងរបៀបការ ដេញដោលពិភាក្សា បើយើងមើលតួលេខអស់នេះ យើងឃើញដូចជាពីរនាក់ទេ អ្នកប្រជែង»។

លោកមានប្រសាសន៍បន្ថែមថា ការជជែកដេញដោលលើសេចក្តីព្រាងច្បាប់ គឺត្រូវបានធ្វើឡើង ដោយការបញ្ចេញ មតិតទល់គ្នាដើម្បីយកឈ្នះចាញ់ ជាជាងការផ្តោតលើផលប៉ះពាល់ដែលអាចកើតចេញពីខ្លឹមសារនៃសេចក្តីព្រាង ច្បាប់ទាំងឡាយនោះ។

«បើមិនតតាំងប្រឆាំងទេ គឺវិជ្ជមានទាំងអស់ទៅលើអាសេចក្តីព្រាងច្បាប់ហ្នឹង។ ប៉ុន្តែបើសួរថា តើអាសេចក្តីព្រាងច្បាប់ ហ្នឹង វាប៉ះពាល់លើមណ្ឌល លើប្រជាពលរដ្ឋ នៅតាមមណ្ឌលរបស់ខ្លួនយ៉ាងដូចម្តេច អត់មានការដេញដោលគ្នាស៊ី ជម្រៅទេ»។

របាយការណ៍អង្គការខុមហ្វ្រែល ក៏បានឲ្យដឹងបន្តទៀតថា រដ្ឋសភាបានអនុម័តដោយសំឡេងឯកបក្សលើរបៀបវារៈ សំខាន់ៗ ចំនួន ២១។ របៀបវារៈទាំងនោះ រួមមាន សេចក្តីព្រាងច្បាប់ចំនួន ១៦ ការបោះឆ្នោតជ្រើសតាំងចំនួនពីរ លើក ការអនុម័តសេចក្តីសម្រេចចំនួន ពីរលើក និងការឆ្លើយបំភ្លឺចំនួនមួយលើក។

ក្រុមអ្នកវិភាគ ដែលបានចូលរួមក្នុងពិធីបង្ហាញរបាយការណ៍នេះ ថ្លែងថា ការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នៅកម្ពុជា នៅមិនទាន់ដំណើរការទៅដោយរលូននៅឡើយ ព្រោះមានការចែងមិនច្បាស់ពីអំណាចទាំងបីក្នុងរដ្ឋាភិបាលកម្ពុជា និងការសង្កត់សង្កិនពីក្រុមតំណាងរាស្ត្រគណបក្សកាន់អំណាចមកលើគណបក្សប្រឆាំង។

លោក ឡៅ ម៉ុងហៃ អ្នកវិភាគនយោបាយ បានលើកឡើងអំពីការរារាំងរបស់សភា ក្នុងការសួរនាំមន្ត្រីរដ្ឋាភិបាល ទាក់ទិនបញ្ហារសើបមួយចំនួន ដូចជាករណីឃាតកម្មលើលោកកែម ឡី អ្នកវិភាគសង្គម និងនយោបាយដ៏ល្បីល្បាញមួយរូប។

លោក មេធាវី សុក សំអឿន អតីតប្រធានក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានថ្លែងថា រដ្ឋធម្មនុញ្ញកម្ពុជា បានចែងអំពីលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តែពុំមានការកំណត់និយមន័យច្បាស់លាស់ថា អ្វីទៅជាលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនោះទេ ខណៈដែលរដ្ឋសភាបានសម្រេចលើកិច្ចការធ្វើច្បាប់ជាច្រើន ដោយតំណាងរាស្ត្រមកពីគណបក្សតែមួយនោះ។

លោក សុក សំអឿន មានប្រសាសន៍ថា គណបក្សកាន់អំណាច ពេលខ្លះបានផ្តល់សិទ្ធិសេរីភាពចូលរួមក្នុងកិច្ចការរដ្ឋសភាដល់ក្រុមតំណាងរាស្ត្រគណបក្សប្រឆាំង ប៉ុន្តែ ជារឿយៗសមាជិកគណបក្សប្រឆាំង បានធ្វើពហិការមិនចូលប្រជុំសភា ដើម្បីពិភាក្សាលើការអនុម័តសេចក្តីព្រាងច្បាប់នានា។ លោកពន្យល់ថា៖

«តាមខ្ញុំយល់អញ្ចេះ ពេលដែលគណបក្សត្រូវរ៉ូវគ្នា គេបង្កើតឲ្យមានស្ពីក្រុមភាគតិច ភាគច្រើន។ដូច្នេះ បើយើងមើលអាទំនោរហ្នឹងគឺមានន័យថា គណបក្សកាន់អំណាចហាក់ដូចឲ្យសិទ្ធិទៅគណបក្សសង្គ្រោះអាចមានលទ្ធភាពច្រើន។ ដូច្នេះ បើយើងមើលមានន័យថា សិទ្ធិសេរីភាពហ្នឹងវារាងឡើង ក៏ប៉ុន្តែដល់ពេលគេថា គេលុបវិញដូច្នេះ វាចុះមកវិញ»។

លោក សុក សំអឿន ក៏បានលើកឡើងថា ការកំណត់ច្បាប់មិនច្បាស់លាស់ ពាក់ព័ន្ធនឹងការចាប់ចង ធ្វើឲ្យស្ថាប័នតុលាការត្រូវបានគេប្រើសម្រាប់គាបសង្កត់លើសកម្មភាពសំដែងមតិ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ប្រាប់VOA ថា របាយការណ៍របស់អង្គការខុមហ្វ្រែល ត្រូវបានចងក្រងឡើងដើម្បីគាំទ្រគណបក្សប្រឆាំង។ លោកបញ្ជាក់ថា៖

«គាត់និយាយនេះ ការពារគណបក្សប្រឆាំងយ៉ាងផ្តាច់មុខ ពីព្រោះការចាប់ខ្លួន ហុង សុខហួរ អ៊ុំ សំអាន ក៏ដូចជាមនុស្សមួយចំនួនហ្នឹងវាអាស្រ័យទៅលើលទ្ធផលនៃអំពើប្រព្រឹត្តល្មើសច្បាប់របស់ជនទាំងនោះទេ មិនមែនរំលោភច្បាប់ទេ។ ពេលដែលចាប់យើងហ្នឹង យើងឃើញហើយថា ជាអំពើប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង»។

លោក សុខ ឥសាន បានថ្លែងការពារបក្សកាន់អំណាចថា ប្រទេសកម្ពុជាមានរដ្ឋាភិបាល ហើយអំណាចទាំងបីត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា។

របាយការណ៍របស់អង្គការខុមហ្វ្រែល ក៏បានឲ្យដឹងបន្ថែមទៀតថា ក្រុមតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះទៅបំពេញការងារនៅតាមមូលដ្ឋាន ដែលភាគច្រើនសំដៅសំខាន់លើតែការចុះសួរសុខទុក្ខ ការចែកអំណោយ និងការសម្ពោធសមិទ្ធផល ការចុះអន្តរាគមន៍ និងការចុះពង្រឹងគណបក្សប៉ុណ្ណោះ។

លោកបន្តថា សកម្មភាពចូលរួមរបស់តំណាងរាស្ត្រក្នុងវេទិកាសាធារណៈ ជាមួយប្រជាជន នៅតែមិនសូវមាននៅឡើយ។

ក្នុងពេលថ្មីៗនេះ ក្រុមអង្គការសិទ្ធិមនុស្សក្នុងស្រុក និងក្រៅប្រទេស បានចេញសេចក្តីថ្លែងការណ៍ ជាបន្តបន្ទាប់គ្នា ដោយរិះគន់ខ្លាំងៗចំពោះការអនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលនឹងផ្តល់សិទ្ធិអំណាចដល់រដ្ឋាភិបាល និងស្ថាប័នតុលាការ ក្នុងការរឹតបន្តឹងសកម្មភាពនិងរំលាយចោល គណបក្សនយោបាយ ហើយថា ការអនុម័តនេះ ជាប្រផ្នូលមួយនៃការស្លាប់របស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា៕

## Comfrel រកឃើញភាពអវិជ្ជមានមួយចំនួនរបស់រដ្ឋសភាកម្ពុជា ឆ្នាំទី៣ នៃនីតិកាលទី៥

ដោយ សរ ពិសី21/02/201721/02/2017

http://km.rfi.fr/cambodia-comfrel-found-some-negativenesses-of-assembly-in-2016-21-02-2017

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា Comfrel បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយអះអាងថា រកឃើញភាពអវិជ្ជមានមួយចំនួនរបស់រដ្ឋសភាកម្ពុជា នៅឆ្នាំទី៣ នៃរដ្ឋសភានីតិកាលទី៥ កន្លងទៅ។ ភាពអវិជ្ជមានទាំងនោះរួមមាន៖ ការអនុម័តវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលធ្វើឡើងដោយ បក្សកាន់អំណាច ការបើកផ្លូវរបស់តំណាងរាស្ត្រគណបក្សកាន់អំណាចឲ្យអាជ្ញាធរចោទ ប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និង ឃុំខ្លួន តំណាងរាស្ត្រគណបក្សប្រឆាំង រួមទាំងការថយចុះចំនួនតំណាងរាស្ត្របញ្ចេញមតិក្នុងការពិភាក្សា អនុម័តច្បាប់ និង បរិមាណនៃការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំរបស់រដ្ឋសភា ។ យ៉ាងណាក៏ដោយ អ្នកនាំពាក្យរដ្ឋសភា អះអាងថា រដ្ឋសភា នៃនីតិកាលទី៥ គឺអនុវត្តទៅតាមច្បាប់។

នៅក្នុងសេចក្តីប្រកាសព័ត៌មានស្តីពីការសង្កេតរដ្ឋសភា និង តំណាងរាស្ត្រឆ្នាំទី៣ នៃនីតិកាលទី៥ របស់ ខុមហ្រ្វែល បញ្ជាក់ថា ប្រសិទ្ធិភាពរបស់រដ្ឋសភា ត្រូវបានទម្លាក់ ពិសេសក្រុមមតិភាគច្រើន ដែលកាន់អំណាចបានបំពានដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្របក្សប្រឆាំង និង បន្ថយតួនាទីរបស់តំណាងរាស្ត្រ គណបក្សប្រឆាំង ព្រមទាំងការលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និង ប្រធានក្រុមមតិភាគតិច។

ស្របពេលជាមួយគ្នានេះ ខុមហ្រ្វែលតាមរយៈសេចក្តីប្រកាសព័ត៌មានដដែល រកឃើញទៀតថា បន្ទាប់ពីពហិការមិនចូលរួមកិច្ចប្រជុំ ក្នុងរដ្ឋសភាពីតំណាងរាស្ត្របក្សសង្គ្រោះជាតិ នៅពាក់កណ្តាលឆ្នាំ ២០១៦ គឺក្រោយការវាយដំអ្នកតំណាងរាស្ត្រខ្លួន ២ រូប នៅមុខរដ្ឋសភា ការអនុម័តសេចក្តីព្រាងច្បាប់នានា គឺ មិនមានការពិភាក្សាសួរដេញដោលផុសផុល ដូចពេលមានការចូលរួមប្រជុំពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ នោះទេ។

យ៉ាងណាក៏ដោយ លោក ឡេង ប៉េងឡុង អ្នកនាំពាក្យរដ្ឋសភា វិញបានលើកឡើងថា រដ្ឋសភា នៅនីតិកាលទី ៥ បានអនុវត្តទៅតាមច្បាប់ ហើយគណបក្សសង្គ្រោះជាតិឯណោះវិញទេ ដែលបោះបង់យន្តការ រដ្ឋសភា តាមរយៈការមិនចូលប្រជុំសភា ជាដើម។

របាយការណ៍របស់ខុមហ្វ្រែលដែលចេញផ្សាយកាលពីម្សិលមិញ បញ្ជាក់ទៀតថា សកម្មភាពរបស់គណៈកម្មាការជំនាញរបស់រដ្ឋសភា នៅក្នុងឆ្នាំទី ៣ នេះ មានការថយចុះបើធៀបនឹងឆ្នាំ ២០១៥។ កាលពីឆ្នាំ ២០១៥ គណៈកម្មា

ការជំនាញនៃរដ្ឋសភា បានធ្វើសកម្មភាពសរុបចំនួន ១០៥ លើក ក៏ប៉ុន្តែ នៅក្នុងឆ្នាំ ២០១៦ មានតែ ១០០ លើកតែប៉ុណ្ណោះ។

ព្រមជាមួយគ្នានេះ ចំនួនសន្ទនារបស់គណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ ក៏ត្រូវបាន អង្គការខុមហ្វ្រែលរកឃើញទៀតថា មានការធ្លាក់ចុះ ខណៈដែលការសន្ទនារវាងគណបក្សទាំងពីរនៅក្នុងរដ្ឋសភាក៏មិនបានពេញលេញដូចគ្នា។ នេះបើតាមអង្គការខុមហ្វ្រែល។

ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ មកពីគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ មានការកើនឡើងគួរឲ្យកត់សម្គាល់ ខណៈដែលការបោះឆ្នោត កំពុងខិតជិតមកដល់។ នៅក្នុងនោះ មានតំណាងរាស្ត្រ ១០ រូប ដែលសកម្មជាងគេ ដោយ តំណាងរាស្ត្រ ចំនួន ៧ រូប មកពីគណបក្សសង្គ្រោះ និង ៣ រូប មកពីគណបក្សប្រជាជនកម្ពុជា។

បើទោះបីជាសកម្មភាពសរុបរបស់អ្នកតំណាងរាស្ត្រទៅមូលដ្ឋានមានចំនួនច្រើនក៏ពិតមែន ប៉ុន្តែការប្រើប្រាស់ច្បាប់ និង ការកែបទបញ្ជា ផ្ទៃក្នុង នៃរដ្ឋសភា ដើម្បីបង្ក្រាប គៀបសង្កត់ និង សិទ្ធិចំពោះអ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បាននាំមកនូវការធ្លាក់ចុះប្រសិទ្ធិភាពរបស់ រដ្ឋសភា និង ទម្លាក់ការអនុវត្តគោលនយោបាយ គោលការណ៍ប្រជាធិបតេយ្យសេរី ពហុបក្ស និង នីតិរដ្ឋនៅកម្ពុជា៕

## ខុមហ្វ្រែល ថា ប្រសិទ្ធភាពការងារស្ថាប័នរដ្ឋសភាបានធ្លាក់ចុះ

Wed, 22 February 2017

http://www.postkhmer.com/

ឡាយ សាមាន

**ភ្នំពេញៈ** អង្គការខុម ហ្វ្រែល បានរកឃើញថាប្រសិទ្ធភាពការងាររបស់រដ្ឋសភាបានធ្លាក់ចុះ ដោយក្រុមតំណាងរាស្ត្រមតិភាគច្រើននៃគណបក្សកាន់អំណាចមានការបំពារបំពានទៅលើតំណាងរាស្ត្រគណបក្សប្រឆាំង ហើយស្របពេលជាមួយគ្នានេះក្រុមតំណាងរាស្ត្រគណបក្សប្រឆាំងបានចុះមូលដ្ឋានច្រើនជាងក្រុមតំណាងរាស្ត្រគណបក្សប្រជាជនរហូតដល់ជិតពីរដង។

នៅក្នុងរបាយការណ៍របស់អង្គការខុម ហ្វ្រែល ដែលបានធ្វើការសង្កេតរដ្ឋសភា និងសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងឆ្នាំទី ៣ នៃនីតិកាលទី ៥ គិតចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០១៥ ដល់ខែតុលា ឆ្នាំ ២០១៦ ដែលបានចេញផ្សាយពីថ្ងៃម្សិលមិញបានរកឃើញថាសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានការកើនឡើង ខណៈដែលគោលបំណងចុះមូលដ្ឋានភាគច្រើនផ្ដោតលើការសំណេះសំណាល ពង្រឹងបណ្ដាញផ្ទៃក្នុងបក្ស និងដើម្បីទាក់ទាញប្រជាប្រិយភាព ខណៈការបោះឆ្នោតខិតជិតមកដល់នៅឆ្នាំ ២០១៧ នេះ។

របាយការណ៍បន្តថាសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានចំនួន ១ ៨០១ លើកច្រើនជាងឆ្នាំមុន ដែលក្នុងនោះមានតំណាងរាស្ត្រ ១០២ រូបបានចុះធ្វើសកម្មភាព។ ក្នុងនោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ៥៦ រូប

បានចុះមូលដ្ឋានចំនួន ៦១៧ លើក ខណៈតំណាងរាស្ត្រ ៤៥ រូបមកពីគណបក្សសង្គ្រោះជាតិចុះមូលដ្ឋានបានចំនួន ១១៨៤ លើក។ ក្នុងនោះតំណាងរាស្ត្រ ១០ រូបដែលសកម្មជាងគេក្នុងការចុះមូលដ្ឋានមានពីគណបក្សប្រឆាំងចំនួន ៧ រូប និងគណបក្សកាន់អំណាចចំនួន ៣ រូប។

របាយការណ៍បានបន្ថែមទៀតថាភាគច្រើននៃការចុះមូលដ្ឋាននៃអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជន គឺផ្តោតទៅលើការសំណេះសំណាល សាកសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធផលនានា ខណៈដែលការចុះមូលដ្ឋានរបស់តំណាងរាស្ត្របក្សសង្គ្រោះជាតិភាគច្រើនផ្តោតលើការពង្រឹងបណ្តាញផ្ទៃក្នុងបក្ស សំណេះសំណាល និងសួរសុខទុក្ខដូចគ្នា។

ទាក់ទងនឹងការងារក្នុងរដ្ឋសភាវិញ ខុម ប្រែ្វល បានរកឃើញថាប្រសិទ្ធភាពការងាររបស់រដ្ឋសភាត្រូវបានធ្លាក់ចុះពិសេសក្រុមមតិភាគច្រើនដែលកាន់អំណាចបានបំពារបំពានដកអភ័យឯកសិទ្ធិសភា និងបន្ថយតួនាទីរបស់តំណាងរាស្ត្របក្សប្រឆាំង និងព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិច។

របាយការណ៍បន្តថា តំណាងរាស្ត្របក្សកាន់អំណាចក៏បានបើកផ្លូវឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្របក្សប្រឆាំងដូចជាការចាប់ខ្លួនលោក អ៊ុំ សំអាន និងបណ្តឹងលើ លោក កឹម សុខា។

របាយការណ៍ថា៖ «ជាមួយគ្នានេះគណបក្សកាន់អំណាចជាឯកបក្សបានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាលុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់មានការលើកទឹកចិត្ត ដំឡើងឋានន្តរស័ក្តិដល់អ្នកដៃដល់ដែលជាមន្ត្រីនៃកងកម្លាំងប្រដាប់អាវុធ កងអង្គរក្សដែលបានប្រើអំពើហិង្សាប្រឆាំងតំណាងរាស្ត្រគណបក្សមតិភាគតិច»។

របាយការណ៍ដែលមានកម្រាស់ ៣៥ ទំព័រ បន្តលើកឡើងថាចំណែកការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភាឆ្នាំ ២០១៦ និងឆ្នាំ ២០១៧ នេះវិញគឺមិនមានភាពផុសផុលដូចទៅនឹងសម័យប្រជុំរដ្ឋសភាក្នុងឆ្នាំ ២០១៥ ទេខណៈរបៀបវារៈ និងច្បាប់មួយចំនួនត្រូវបានអនុម័តដោយឯកបក្ស និងមិនមានការដេញដោលឡើយពោលការបញ្ចេញមតិរបស់តំណាងរាស្ត្រហាក់បីដើរលើបន្ទាត់នយោបាយនៃគណបក្សរៀងៗខ្លួន។

ប៉ុន្តែអ្នកនាំពាក្យគណបក្សប្រជាជនលោក សុខ ឥសាន ថ្លែងថាលោកមិនចាប់អារម្មណ៍ទៅនឹងរបាយការណ៍នេះទេ និងចាត់ទុកថាអង្គការដែលចេញរបាយការណ៍នេះបម្រើឱ្យបក្សប្រឆាំង។

លោកថា៖ «ការចុះមូលដ្ឋានរបស់បក្សប្រជាជនកម្ពុជាគឺធ្វើតាមកម្មវិធីរបស់ខ្លួន មិនបានរាយការណ៍ជូន ខុម ប្រែ្វល ហើយមិនចាត់ទុក ខុមប្រែ្វល ជាថៅហ្វាយនាយរបស់ខ្លួនដែលចាំបាច់ត្រូវរាយការណ៍ជូនទេ គាត់សរសេរយ៉ាងម៉េចទៅតាមការគិតឃើញរបស់គាត់ តែគាត់មាននិន្នាការមិនឯករាជ្យកាន់ជើងបក្សប្រឆាំងផ្កាប់មុខទៅហើយ...អ៊ីចឹងគាត់ចង់លើកកម្ពស់បក្សប្រឆាំង ហើយជាន់ពន្លិចបក្សកាន់អំណាច»។

យ៉ាងនេះលោកថាចំណាត់ការកន្លងមកលើតំណាងរាស្ត្រដែលមានអភ័យឯកសិទ្ធិគឺធ្វើឡើងតាមច្បាប់។

លោកថា៖ «ការមានវិធានការផ្លូវច្បាប់ចំពោះ អ៊ុំ សំអាន និយាយឱ្យចំ ហុង សុខហួរ មិនមែនជាការរំលោភរដ្ឋធម្មនុញ្ញទេ ឬច្បាប់ទេ គឺសាមីជនជាអ្នករំលោភច្បាប់ គាត់ចោទបក្សប្រជាជនចុះហត្ថលេខាជាមួយវៀតណាម...អ៊ុំ សំអាន ថា រដ្ឋាភិបាលប្រើប្រាស់ផែនទីក្លែងក្លាយ»។

ដោយឡែកការស្នើធ្វើវិសោធនកម្មច្បាប់ស្ដីគណបក្សនយោបាយវិញ លោក សុខ ឥសាន បានថ្លែងថា៖ «វាជារឿងធម្មតាពេលច្បាប់មួយរៀបនឹងចេញតែងតែមានព្យុះភ្លៀង ជាក់ស្ដែងច្បាប់ស្ដីពីប្រឆាំងអំពើពុករលួយ ច្បាប់អង្គការសហជីព សុទ្ធតែមានការទប់ស្កាត់មិនឱ្យចេញតែឥឡូវច្បាប់ទាំងអស់ចេញហើយ អ៊ីចឹងខ្ញុំជឿជាក់ថាច្បាប់នេះទោះបីមានឧបសគ្គយ៉ាងណាក៏មិនអាចទប់ស្កាត់បានដែរ»។

អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិលោក យឹម សុវណ្ណ បានថ្លែងថាការខកខានរបស់តំណាងរាស្ត្របក្សសង្គ្រោះជាតិក្នុងការចូលប្រជុំសភា ដោយសារតែច្បាប់ដែលសភាយកមកពិភាក្សាគឺបានប្រឆាំងនឹងគោលការណ៍ប្រជាធិបតេយ្យ។ លោកថា៖ «កន្លងទៅយើងបានចូលប្រជុំសភាដើម្បីពិភាក្សាច្បាប់ដែលមានប្រយោជន៍ដល់ប្រទេសជាតិ ប៉ុន្តែយើងមិនចូលប្រជុំពិភាក្សាលើច្បាប់ដែលប្រឆាំងនឹងគោលការណ៍ប្រជាធិបតេយ្យឡើយ»។

លោក សុវណ្ណ បញ្ជាក់ថាកាលពីមុនតំណាងរាស្ត្រគណបក្សប្រឆាំងត្រូវបានអនុញ្ញាតឱ្យនិយាយនៅក្នុងកិច្ចប្រជុំរដ្ឋសភា ប៉ុន្តែក្នុងអំឡុងពេលកិច្ចប្រជុំចុងក្រោយនេះជាពិសេសនៅក្នុងឆ្នាំ ២០១៦ តំណាងរាស្ត្រគណបក្សប្រឆាំងភាគច្រើនមិនត្រូវបានរដ្ឋសភាអនុញ្ញាតឱ្យនិយាយទេ។

ប្រធានគណបក្សខេមរៈពន្លឺជាតិ លោក ព្រំម ពិសិដ្ឋ ដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ខុម ហ្វ្រែល កាលពីម្សិលមិញបានថ្លែងថាការធ្វើវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយដែលរដ្ឋសភាទើបអនុម័តគឺជារឿងដែលគួរឲ្យព្រួយបារម្ភ។

លោកបានបញ្ជាក់ទៀតថា៖ «យើងបារម្ភមែនទែនគឺច្បាប់ហ្នឹងកំពុងតែរុញឱ្យប្រជាធិបតេយ្យធ្លាក់ចុះ...បានន័យថាស្ទើរតែប្រធានបក្សទាំងអស់ជាប់បទល្មើសទាំងអស់លោក ខឹម វាសនា ក៏ជាប់បទល្មើស លោក សួន សេរីរដ្ឋា អ៊ីចឹងអំណាចតុលាការនៅលើគាត់ (នាយករដ្ឋមន្ត្រី)»។

អ្នកវិភាគនយោបាយលោក ឡៅ ម៉ុងហៃ មើលឃើញថាកម្ពុជាកំពុងឆ្ពោះទៅរកការដឹកនាំតាមបែបរបបផ្ដាច់ការដោយសារធ្វើអ្វីៗត្រូវបានធ្វើទៅតាមបញ្ជារបស់មនុស្សម្នាក់ ខណៈរដ្ឋាភិបាលកំពុងធ្វើច្បាប់រំលាយគណបក្សបន្ថែមទៀត។

លោកថា៖ «បច្ចុប្បន្នរបបនេះទៅជារបបផ្ដាច់ការគឺបានលុបបំបាត់យន្តការប្រជាធិបតេយ្យ យកច្បាប់ដើម្បីបង្ក្រាបអ្នកប្រឆាំងផង អ្នកទិតៀនផង មាត់គាត់ (ហ៊ុន សែន )មាត់ទិព្វ គាត់ថាមាត្រា ៤៨ ថ្មី ត្រូវលុបចោល គេលុបចោលទៅអត់ចេញពីប្រជាពលរដ្ឋទេ ដូចជាច្បាប់ស្ដីពីគណបក្សនយោបាយធ្វើតាមសម្ដីគាត់ ហើយតំណាងរាស្ត្របានផ្ដិតមេដៃដាក់សំណើទៅតាមគំនិតចេញពីមនុស្សម្នាក់ដូចមាត់ទិព្វអ៊ីចឹង ដូចគាត់ប្ដឹងគេរឿងបរិហារកេរ្តិ៍ក៏អ៊ីចឹងដែរ គាត់ស្រែករ៉ាប់ គេចាត់ការ និងចាប់បានមនុស្សភ្លែត»៕

**NA ‘more dictatorial’: Comfrel chides legislature in report on Cambodia’s democracy**

Wed, 22 February 2017

http://www.phnompenhpost.com/national/na-more-dictatorial-comfrel-chides-legislature-report-cambodias-democracy

Lay Samean and Erin Handley

Cambodian electoral watchdog Comfrel has released a damning new report on the state of democracy in the Kingdom, saying political dialogue has dwindled to detrimental levels and describing the National Assembly as “dysfunctional”.

Comfrel executive director Koul Panha said the report, which analysed political activity between November 2015 and October 2016, said the parliamentary body was “more dictatorial than the previous year”.

“The National Assembly is very much a majority rule, but they do not respect the rights of the minority to have a voice to be heard, to have access to information and their [parliamentary] protection,” he said, citing the arrest of opposition members despite their constitutionally mandated parliamentary immunity.

“This majority controls all, everything; there is no multi-party spirit.”

The timely report comes a day after the National Assembly swiftly passed widely criticised amendments to the Law on Political Parties – ones that could theoretically empower the ruling party to dissolve the opposition – in a session boycotted by the Cambodia National Rescue Party on Monday.

He added that the slew of legislation passed without debate was also cause for concern – of 32 agenda items, 11 were passed without discussion and 21 were passed unilaterally by the ruling Cambodian People’s Party.

However, CPP spokesman Sok Eysan said he was not interested in Comfrel’s findings.

“The CPP has never considered that Comfrel is the boss who needs to be reported to,” he said. “They are not independent, and they take the opposition’s side completely . . . They want to raise up the opposition party and discredit the ruling party.”

Eysan further defended the legal measures taken against opposition lawmakers Um Sam An and Hong Sok Hour – both of whom were jailed, despite their parliamentary immunity, for remarks made on social media – saying their arrests were “not a violation of the national constitution, but [because] the individual violated the law”.

CNRP spokesman Yim Sovann, however, agreed parliamentary debate had been stifled.

“Before, we were allowed to speak when we submitted names to the National Assembly, but . . . since the beginning of 2016, most of us submitted to the National Assembly, but we were not allowed to speak. This is the reality.”

Sovann acknowledged that his party had been a no-show for votes on contentious laws, but maintained it was because they were not permitted to debate potential changes.

“Sometimes we did not attend the National Assembly when the law is against the democratic principle,” he said.

Comfrel’s report also found a spike in the number of visits to local communes made by parliamentarians – CPP lawmakers made 617 field trips, compared with 1,184 by 45 CNRP lawmakers.

Panha said the “remarkably high” number of visits was no doubt to galvanise support heading into commune elections in June.

Political analyst Lao Mong Hay, a former adviser to opposition leader Kem Sokha, said the current situation boiled down to the will and word of Prime Minister Hun Sen.

Referring to several recent speeches in which the premier's seemingly off-hand remarks were quickly acted upon by others in the party – including his suggestion to amend the Political Party Law and his calls for the arrest of analyst Kim Sok – Mong Hay said "Hun Sen's mouth is the magic mouth".

"Recently when he screamed out, [authorities] carried out the task and managed to arrest the person," he said

## ខុមហ្វ្រែល រកឃើញថា ប្រសិទ្ធភាពរដ្ឋសភាត្រូវបានទម្លាក់

ដោយ៖ ឆេង ណាតា | ថ្ងៃទី 21 កុម្ភៈ 2017 | ម៉ោង 5:38 PM

http://wmc.org.kh/archives/38634

ភ្នំពេញ ៖ របាយការអង្កេតរបស់អង្គការខមហ្វ្រែល ដែលចេញនៅថ្ងៃនេះ បានបង្ហាញថា ប្រសិទ្ធិភាព របស់រដ្ឋសភាត្រូវទម្លាក់។ ជាមួយគ្នាការបញ្ចេញមតិរបស់តំណាងរាស្ត្រក៏មានការថយចុះផងដែរ។ តំណាងរាស្ត្រគណបក្សកាន់អំណាចមិនបដិសេធធ្វើអត្ថាធិប្បាយលើរបាយការណ៍ នេះទេ។

ប្រសិទ្ធិ ភាពរបស់រដ្ឋសភាបានធ្លាក់ចុះមួយកម្រិតដោយសារការកើនឡើងនៃ«ការ បំពានអំណាច»ពីក្រុមសភាតំណាងរាស្ត្រគណបក្សដឹកនាំប្រ ទេស។ នេះគឺជារបាយការណ៍របាយការណ៍អង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃរដ្ឋសភានីតិកាលទី ៥  នៅឆ្នាំ ២០១៦ របស់អង្គការឃ្លាំ មើលការបោះឆ្នោតខុមហ្វ្រែល ដែលចេញផ្សាយនៅថ្ងៃអង្គារទី២១ កុម្ភៈ។

ការថយចុះប្រសិទ្ធិភាពដែលស្តែងចេញតាមរយៈការធ្លាក់ចុះនៃការ អនុម័តសេចក្តីព្រាងច្បាប់នានា។ហើយការអនុម័តសេចក្តសំរេចនិង សេចក្តី ព្រាងច្បាប់ធ្វើឡើងដោយសំលេងឯកបក្ស។ ជាមួយគ្នានេះ ក៏មានរបៀបវារៈចំនួន ១១ ត្រូវបានអនុម័តដោយមិនមានការពិភាក្សាដេញដោល លើខ្លឹមសារច្បាប់ដោយអ្នកតំណាងរាស្ត្រនោះទេ។

ដោយឡែកសកម្មភាពការងាររបស់គណៈកម្មការជំនាញនៃរដ្ឋសភាវិញ គឺមានការថយចុះ ប៉ុន្តែសកម្ម ភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការកើនឡើង បើធៀបនឹងឆ្នាំ ឆ្នាំ២០១៥។

ចំណែកបរិមាណនៃចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិក្នុងការពិភាក្សា និងអនុម័តច្បាប់ និងបរិមាណនៃការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា ក៏មានការថយចុះផងដែរ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៥។ ក្នុងឆ្នាំ ២០១៦ តំណាងរាស្ត្រដែលឡើងបញ្ចេញមតិមានតែ ១៨រូប ប៉ុណ្ណោះ បើធៀបនឹងឆ្នាំ ២០១៥ មានចំនួន ៤៣រូប។ ការថយចុះនេះ ដោយសារមានការខ្វែងគំនិតគ្នា រវាងគណបក្សទាំងពីរ លើចំណាត់ការរបស់រដ្ឋសភាចំពោះតំណាងគណបក្សប្រឆាំង ដែលនាំឱ្យមានការធ្វើពហិការមិនចូលប្រជុំរបស់បក្សប្រឆាំង។

របាយការណ៍អង្កេតនេះ បន្តថា តំណាងរាស្ត្រគណបក្សកាន់អំណាច បានបើកផ្លូវឱ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្រគណបក្សប្រឆាំង។ ជាមួយគ្នានេះ គណបក្សកាន់ អំណាចជាឯកបក្សបានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃ ក្នុង នៃរដ្ឋសភាលុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់។

លោក ឈាង វុន អ្នកនាំពាក្យរដ្ឋសភាតំណាងគណបក្សប្រជាជនកម្ពុជា មិនអត្ថាធិប្បាយជុំវិញរបាយការណ៍នេះទេ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកវិភាគបញ្ហាសង្គម មានប្រសាសន៍ នៅក្នុងកិច្ចពិភាក្សានៅ ព្រឹកនេះថា រដ្ឋសភាកម្ពុជាបច្ចុប្បន្ននៅខ្វះខាតវប្បធម៌ប្រជាធិបតេយ្យ និងនៅតែប្រកាន់បក្សពួកខ្លាំងពេក។ ទន្ទឹមនឹងនេះដែរ ប្រធានរដ្ឋសភាមិនទាន់អព្យាក្រិត្យ។ លោកបន្តថា ជាទូទៅប្រធានរដ្ឋសភានៅបណ្ដាប្រទេសប្រជាធិបតេយ្យមួយចំនួន គឺជាបុគ្គលឯករាជ្យ មានតួនាទីដឹកនាំស្ថាប័នជាតិមួយ ដាច់ដោយឡែកពីរដ្ឋាភិបាល ហើយការពារផលប្រយោជន៍រដ្ឋសភា និងការពារសមាជិករដ្ឋសភា បើទោះមកពីគណបក្សណាក៏ដោយ។ «គ្មានការជជែកវែកញែកគ្នាមិនមែន មិនមែនជាសភាទេ មនុស្សម្នាក់សម្រេចតាម។ បទបញ្ជាផ្ទៃក្នុងទៀតដែលខ្ញុំឃើញថា យើងហ្នឹងធ្វើដូចចង្អៀតណាស់ អត់មានយន្តការដើម្បីជជែក ឬពិភាក្សាគ្នាឱ្យបានច្រើនទេ ខុសពីសភាជំនាន់សង្គមរាស្ត្រនិយម អាហ្នឹងបក្សតែមួយដែរ ក៏ប៉ុន្តែសភាហ្នឹងគេទម្លាក់រដ្ឋាភិបាល»។

លោកបណ្ឌិតឡៅ ម៉ុងហៃ លើកឡើងទៀតថា បុគ្គលិកដែលបម្រើការនៅក្នុងរដ្ឋសភា ចាប់ពីតំណែងអគ្គលេខាធិការត្រូវតែអព្យាក្រិត មិនត្រូវប្រកាន់បក្សពួកទេ ប៉ុន្តែជាក់ស្ដែង បុគ្គលិកទាំងនោះដែលភាគច្រើនមកពីគណបក្សប្រជាជនកម្ពុជា នៅតែប្រកាន់បក្សពួក ដែលទង្វើនេះធ្វើឱ្យរដ្ឋសភាដំណើរការមិនល្អ៕

## ខុមហ្វ្រែល៖ សកម្មភាព និងការងាររដ្ឋសភា២០១៦ ធ្លាក់ចុះ

ប៊ិច សុធារី Wednesday, 22 February 2017

http://www.khmertimeskh.com/news/35726/------------------------------------------------------------------------------------------------------------------------------------------------------------/

ភ្នំពេញ៖(ខ្មែរថាមស៍)យោង តាមរបាយការណ៍របស់អង្គការខុមហ្វ្រែលដែលសង្កេតរដ្ឋសភានិងតំណាងរាស្ត្រ បានរកឃើញថា សកម្មភាព និងប្រសិទ្ធភាពការងាររបស់រដ្ឋសភា ក្នុងឆ្នាំ២០១៦ មានការធ្លាក់ចុះ បើធៀបនឹងឆ្នាំចាស់ ខណៈដែលក្រុមមតិភាគច្រើនដែលកាន់អំណាច មានការបំពារបំពានទៅលើអភ័យឯកសិទ្ធិ បើកផ្លូវឲ្យមានការចោទប្រកាន់ និងឃុំខ្លួនទៅលើតំណាងរាស្ត្របក្សប្រឆាំង និងការអនុម័តច្បាប់មួយចំនួនធ្វើឡើងដោយឯកបក្ស ប៉ុន្តែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងពីរបក្ស មានការកើនឡើង។

ក្នុង របាយការណ៍របស់អង្គការខុមហ្វ្រែល អំពីរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៣ នៃនីតិកាលទី៥ ក្នុងឆ្នាំ២០១៦ ចេញកាលពីថ្ងៃម្សិលមិញ បានរកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភា ត្រូវបានទម្លាក់ ពិសេសក្រុមមតិភាគច្រើនដែលកាន់អំណាច បានបំពារបំពានដកអភ័យឯកសិទ្ធិសភា និងបន្ថយតួនាទីរបស់តំណាងរាស្ត្របក្សប្រឆាំង ព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិច។

របាយការណ៍ បន្តថា តំណាងរាស្ត្របក្សកាន់អំណាច ក៏បានបើកផ្លូវឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនតំណាងរាស្ត្របក្សប្រឆាំងផងដែរ ដូចជា ករណីបណ្ដឹងលើ លោក កឹម សុខា និងលោក អ៊ុំ សំអាន ជាដើម។

របាយការណ៍បានលើកឡើងទៀតថា៖ «គណបក្សកាន់អំណាចជាឯកបក្ស បានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា លុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់។ មានការលើកទឹកចិត្ត ដំឡើងឋានន្តរសក្តិដល់អ្នកដែដល់ដែលជាមន្ត្រីនៃកងកម្លាំងប្រដាប់ អាវុធកងអង្គរក្សដែលបានប្រើអំពើហិង្សាប្រឆាំងតំណាងរាស្ត្រគណបក្សមតិ ភាគតិច»។

សម្រាប់សកម្មភាព និងប្រសិទ្ធភាពការងាររបស់រដ្ឋសភា និងអ្នកតំណាងរាស្ត្រវិញ របាយការណ៍កម្រាស់ ៣៥ទំព័រនោះ បានលើកឡើងថា ការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំកាលពីឆ្នាំ២០១៦ មិនមានភាពផុសផុលដូចកាលពីឆ្នាំចាស់នោះទេ ហើយហាក់ដើរតាមបន្ទាត់នយោបាយនៃគណបក្សរៀងៗខ្លួនក្នុងនោះមាន របៀបវារៈខ្លះមិនមានការពិភាក្សាដេញដោលនិងរបៀបវារៈខ្លះទៀត អ្នកតំណាងរាស្ត្រគ្រាន់តែបង្ហាញជំហរគាំទ្រ និងសរសើរពីសេចក្តីព្រាងច្បាប់ និងកិច្ចខិតខំរបស់រដ្ឋាភិបាល ហើយរបៀបវារៈខ្លះទៀតត្រូវបានអនុម័តដោយឯកបក្ស និងមិនមានការដេញដោល ខណៈដែលក្រុមតំណាងរាស្ត្របក្សប្រឆាំងធ្វើពហិការមិនចូលរួមប្រជុំ។

មន្ត្រីផ្នែកអង្កេតអង្គការខុមហ្វ្រែល លោក ស៊ិន ទិត្យសីហា បានមានប្រសាសន៍បន្ថែមលើរបាយការណ៍ថា បើយោងតាមទិន្នន័យអំពីសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រវិញឃើញ ថាក្នុងរយៈពេលពេញមួយឆ្នាំ២០១៦មានតំណាងរាស្ត្រចំនួន១០២រូបបានចុះ ធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន១៨០១លើកដែលចំនួននេះមានការកើនឡើងជាងឆ្នាំចាស់ដែលមានតែតំណាងរាស្ត្រ៩១រូបប៉ុណ្ណោះ ដែលបានធ្វើសកម្មភាពនៅមូលដ្ឋានចំនួន ១០០៤លើក។ ក្នុងចំណោមនោះ មានតំណាងរាស្ត្រប្រជាជនកម្ពុជា ៥៦រូប បានចុះមូលដ្ឋាន ៦១៧លើក ហើយតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ៤៥រូប ចុះមូលដ្ឋានចំនួន ១១៨៥លើក ប៉ុន្តែការចុះមូលដ្ឋាននោះ ភាគច្រើនក្នុងគោលដៅស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ ខណៈការបោះឆ្នោតជិតមកដល់។

ចំណែកសកម្មភាពរបស់គណៈកម្មការជំនាញដែលកោះហៅមន្ត្រីរដ្ឋាភិបាល ទៅបំភ្លឺនៅរដ្ឋសភា វិញ គឺមានការថយចុះ ដោយនៅឆ្នាំ២០១៥មានរដ្ឋមន្ត្រីចំនួន ៨រូបដែលត្រូវបានកោះហៅតែឆ្នាំ២០១៦មានតែរដ្ឋមន្ត្រីមួយរូបទេដែលបានកោះហៅចូលបំភ្លឺ។ លោក ស៊ិនទិត្យសីហាបានបញ្ជាក់ថា៖«យើងឃើញថាប្រសិទ្ធភាពរបស់សភារបស់ គណៈកម្មការជំនាញហ្នឹងមានការថយចុះដោយសារសកម្មភាពដែលយើងសង្កេតឃើញ មានការថយចុះ»។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន្ត យល់ថា របាយការណ៍របស់អង្គការខុមហ្វ្រែល មាននិន្នាការមិនឯករាជ្យ ដោយលម្អៀងទៅរកបក្សប្រឆាំង។លោកបានបញ្ជាក់ថាការចុះមូលដ្ឋានរបស់ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាគឺធ្វើទៅតាមកម្មវិធីការងាររបស់ ខ្លួនជាក់ស្តែងដោយមិនចាំបាច់ទៅរាយការណ៍ប្រាប់អង្គការណាមួយទេ។ ចំណែកការមានវិធានការផ្លូវច្បាប់ចំពោះតំណាងរាស្ត្រគណបក្សប្រឆាំង ដែលប្រព្រឹត្តខុស មិនមែនជាការរំលោភរដ្ឋធម្មនុញ្ញ ឬរំលោភច្បាប់នោះទេ គឺសាមីជនរូបនោះទេ ដែលជាអ្នករំលោភច្បាប់។

លោក ថា៖ «គាត់ [ខុមហ្វ្រែល] សរសេរយ៉ាងម៉េច ក៏សរសេរទៅ ទៅតាមការគិតឃើញរបស់គាត់តែគាត់មាននិន្នាការមិនឯករាជ្យ កាន់ជើងគណបក្សប្រឆាំងផ្ទាប់មុខទៅហើយខ្ញុំហ៊ាននិយាយអុីចឹងគាត់មើល តែពីរឿងសេរីភាពអត់មើលរឿងព្រំដែនគេដែលហាមមិនឲ្យនិយាយលើសទេ គេ[តំណាងរាស្ត្របក្សប្រឆាំង]និយាយលើសព្រំដែនគាត់អត់ចាប់អារម្មណ៍ទេ គាត់គិតតែបន្ថែមគាត់»។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក យឹម សុវណ្ណ បានថ្លែងថា របាយការណ៍នេះបានឆ្លុះបញ្ចាំងពីការពិតនៃទិដ្ឋភាពដែលបានកើតឡើង ខណៈដែលសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនេះ តែងធ្វើឡើងជាប់លាប់ ដើម្បីដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ពុំមែនដោយសារតែការបោះឆ្នោតខិតជិតមកដល់នោះទេ។

លោកថា៖ «យើងទទួលស្គាល់ថា ការពិតវាអ៊ីចឹងមែន ព្រោះអង្គការនេះជាអង្គការអព្យាក្រឹត្យ»។

អ្នកនាំពាក្យរដ្ឋសភា លោក ឡេង ប៉េងឡុង មិនអាចសុំការអធិប្បាយបានទេ។

សមាជិកសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត លោក សុក សំអឿន បានលើកឡើងថា រដ្ឋសភា គួរតែមានការកែសម្រួលបទបញ្ជាផ្ទៃក្នុង ដោយត្រូវមានការចូលរួមកិច្ចប្រជុំពីគ្រប់គណបក្សដែលមានអាសនៈ ហើយការអនុម័តច្បាប់ត្រូវមានសំឡេងភាគតិចចូលរួម នោះទើបប្រសើរ បើពុំនោះទេអ្នកនយោបាយនឹងនៅតែយករដ្ឋធម្មនុញ្ញធ្វើជារនាំងសម្រាប់ផលប្រយោជន៍គណបក្សខ្លួន៕

## Failures at assembly pile up

Khmer Times/Pech Sotheary Wednesday, 22 February 2017 1064 views

http://www.khmertimeskh.com/news/35719/failures-at-assembly-pile-up/

National Assembly effectiveness declined last year with prosecutions of opposition lawmakers, partisan passing of laws and many assembly members visiting constituents only to shore up their vote, an election watchdog claimed yesterday.

A Committee for Free and Fair Elections in Cambodia (Comfrel) report yesterday found the assembly to be ineffective after the ruling CPP, in their opinion, violated the parliamentary immunity of other lawmakers, shrunk the roles of opposition politicians and abolished the positions of majority and minority leaders.

The NGO, in a biased report said the CPP’s actions paved the way for the authorities to indiscriminately detain and charge opposition lawmakers such as acting CNRP president Kem Sokha and outspoken CNRP lawmaker Um Sam An.

“The ruling party has passed a law and amended the National Assembly’s internal regulations to abolish the minority group which was recognized before the law,” the 35-page report says. “There were also the promotions of members of the armed forces and bodyguards who used violence against opposition lawmakers.”

The CPP on Monday unilaterally passed highly contentious amendments to the Law on Political Parties which allows for parties to be dissolved if their leaders have been convicted of a crime.

The vote passed with 66 CPP member votes after the opposition chose to boycott proceedings, saying its attendance would not have made a difference to the outcome.

Opposition lawmakers regularly face civil and criminal charges, which many have decried as being politically motivated.

Former CNRP president Sam Rainsy last week announced his resignation from the party for fear that his being slapped with multiple convictions would jeopardize the party’s position.

Mr. Rainsy in September was convicted of defamation for claiming the “likes” on Prime Minister Hun Sen’s Facebook were purchased through “click farms.”

In December, he was sentenced in absentia to five years in prison for posting what has since been deemed a fake treaty about the Cambodia-Vietnam border.

Mr. Sokha, who currently heads the opposition party, was last year sentenced to five months in prison for failing to appear as a witness in a case related to his purported affair with a hairdresser. He was eventually pardoned by King Norodom Sihamoni in December after a request from Prime Minister Hun Sen.

Comfrel also found that parliamentarians from both the major parties were less active in 2016 compared with the year before, with some agendas left undebated or unilaterally approved by one party as other parties chose to boycott sessions.

Visits to local constituencies, however, saw an increase last year as 102 lawmakers made 1,801 local visits, an increase from 91 lawmakers making 1,004 visits in 2015.

From the CPP, 56 lawmakers conducted 617 local visits while 45 CNRP lawmakers made 1,185 local visits.

However the report points out that most of the trips to their respective constituencies were merely to shore up support for the party ahead of the upcoming election.

There were also fewer activities conducted by expert commissions last year, with there being only one minister who was summoned to the assembly, compared with eight ministers in 2015.

“We found that the effectiveness of parliament and the expert commission decreased,” Comfrel monitor Sin Tithseiha said.

CPP spokesperson Sok Eysan rubbished the report, saying the NGO was biased in favor of the opposition and did not have a track record of being independent.

He also insisted that the CPP has conducted many off-the-books local visits and that any legal actions against opposition lawmakers were constitutional after the politicians were found to have violated the law.

“[Comfrel] can write whatever they want. But they don’t have a trend of being independent,” Mr. Eysan said.

“The opposition may say something over the line but Comfrel doesn’t notice that.”

The CNRP’s Yim Sovann noted that local visits were not conducted purely to gain support from voters.

But he said, “We recognize that the facts in the report are from a neutral organization.”

Assembly spokesperson Leng Peng Long could not be reached for comment.

Electoral Reform Alliance senior member Sok Sam Oeun urged the assembly to modify internal regulations to ensure that all parliamentarians may participate in proceedings.

“The adoption of the law should have the participation of minority groups. Otherwise, politics will see the constitution as a barrier in pursuit of the party’s interest,” he said

# ឧបត្ថម្ភដោយ

diakonia
PEOPLE CHANGING THE WORLD

NORWEGIAN PEOPLE'S AID

Oxfam

OPEN SOCIETY FOUNDATIONS

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

ខុមហ្វ្រែល COMFREL


**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@online.com.kh ; comfrel@comfrel.org

គេហទំព័រ: www.comfrel.org